

ព្រឹត្តិបត្រប្រចាំខែ

*Monthly Newsletter*

# ការអប់រំ និង បច្ចេកវិទ្យា

# Education & Technology

Android iOS







ឆ្នាំទី១ លេខ០០២ ចេញផ្សាយប្រចាំខែឧសភា-សីហា ឆ្នាំ២០២១



Android iOS

ការិយាល័យៈ សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម
ប្រអប់សំបុត្រៈ P.O Box ១៦២១ ភ្នំពេញ កម្ពុជា 042-941-481 / 042-941-918
kape@kapekh.org www.kapekh.org www.facebook.com/kapeaction
www.youtube.com/TheKapeCambodia www.linkedin.com/in/kapecambodia/
www.twitter.com/KAPECambodia

# មាតិកា


ទំព័រ

១-២ អំពីអង្គការ ខេប ចំនួនគម្រោងកំពុងប្រតិបត្តិ អ្នកទទួលផល សាលាគោលដៅ ម្ចាស់ជំនួយក្នុងឆ្នាំ២០២១ និងតំបន់គោលដៅ

## ១. ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ (NGS)

៤ កិច្ចប្រជុំលើកទី១ជាមួយក្រុមអ្នកគ្រប់គ្រងសាកលវិទ្យាល័យតិចសាស់

៥ ការប្រើប្រាស់ទម្រង់សំណួរសម្រាប់បង្កើតតេស្តប្រឡង

៦ កិច្ចសម្ភាសន៍តំណាងម្ចាស់ជំនួយជាមួយក្រុមប្រឹក្សាភិបាល និងអ្នកពាក់ព័ន្ធរបស់គម្រោង

៦ ពិធីបិទបញ្ចប់គម្រោងសាលារៀនជំនាន់ថ្មី សាលាបឋមសិក្សាស្វាយព្រហូត និងវិទ្យាល័យគោកព្រីងក្នុងខេត្តស្វាយរៀង

## ២. ព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាសម្រាប់ការអប់រំ

៩ កម្មវិធី (Apps) សម្រាប់ធ្វើទំនាក់ទំនងក្នុងបរិបទជំងឺកូវីដ-១៩

១០ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌បានជំរុញការសិក្សាបែបចម្រុះក្នុងបរិបទជំងឺកូវីដ-១៩

## ៣. ការអភិវឌ្ឍគ្រូបង្រៀន

១២ សន្និសីទជាតិលើកទី១ ស្ដីពី ការប្រឹក្សាគរុកោសល្យ ក្រោមប្រធានបទ ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូប្រឹក្សាគរុកោសល្យ

១៥ គ្រូបង្រៀនទទួលបានវគ្គបណ្ដុះបណ្ដាលពីកម្មវិធីសាលារៀនជំនាន់ថ្មី

១៥-១៦ កម្មវិធីបំប៉នគ្រូបង្រៀនកិច្ចសន្យា

១៦ សិក្ខាសាលាស្ដីពី ការបំប៉នសមត្ថភាពគ្រូបង្រៀនកិច្ចសន្យា

១៧ សិក្ខាសាលាតម្រង់ទិស ស្ដីពី ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀន

១៨ សិក្ខាសាលា ស្ដីពី ការបង្កើតតេស្ដដែលមានសុពលភាព

១៩ កម្មវិធីបំប៉នសមត្ថភាពគ្រូបង្រៀនអំពីការប្រើប្រាស់ធនធានសម្បូរបែបក្នុងថ្នាក់រៀន និងការរៀបចំបរិស្ថានថ្នាក់រៀន

២០ ការរៀនបណ្ដុំតាមផ្ទះក្នុងបរិបទជំងឺកូវីដ-១៩

## ៤. កម្មវិធីអប់រំបរិយាប័ន្ន

២២ យុវតីណាវិនមានការងារធ្វើបន្ទាប់ពីបានអាហារូបករណ៍អង្គការ ខេប

២៣ ការប្រជុំធ្វើបច្ចុប្បន្នភាពសកម្មភាពជាមួយនាយកសាលាគោលដៅ

២៤ ការប្រជុំស្ដីពីការអនុវត្តកម្មវិធីអាហារូបករណ៍ និងរៀបចំផែនការបន្ត

២៥ យន្តការប្រើប្រាស់ថវិកាឃុំក្នុងការគាំទ្រសកម្មភាពសាលារៀន

២៦ ការពិគ្រោះយោបល់លើការរៀនតាមបណ្ដុំ និងការជួយគាំទ្រសិស្ស

២៧ កុមារមានជំងឺស្លេកស្លាំងអស់រយៈពេលជាងបីខែត្រូវបានព្យាបាល

២៨ ក្លឹបសិក្សាសិស្សអាហារូបករណ៍ទទួលបានវគ្គបំប៉នតាមអនឡាញ

## ៥. កម្មវិធីអំណានថ្នាក់ដំបូង

៣០ សកម្មភាពសិក្សាតាមបណ្ដុំដោយប្រើប្រាស់កម្មវិធីសិក្សាអង្គការ ខេប

## ៦. កម្មវិធីមត្តេយ្យសិក្សា

៣២ សិក្ខាសាលា ស្ដីពី ការកែឯកសារផែនការប្រចាំខែសម្រាប់មត្តេយ្យសិក្សា

៣៣ វគ្គបំប៉នបច្ចេកទេសរៀបចំផែនការបង្រៀនប្រចាំថ្ងៃ លំនាំបង្រៀន និងរៀបចំកិច្ចតែងការបង្រៀនសម្រាប់ថ្នាក់មត្តេយ្យសិក្សា

៣៤ ការពង្រឹងគ្រូមត្តេយ្យអំពីបច្ចេកទេសសម្រាប់បង្រៀន និងរៀនពីចម្ងាយ

## ៧. ចេនាបថហេដ្ឋារចនាសម្ព័ន្ធ

៣៦ សម្ភារៈសម្រាប់កុមារលេងត្រូវបានដំឡើងនៅសាលារៀនគោលដៅ
៣៧ ការរៀបចំបរិស្ថានស្អាត និងបរិក្ខាទំនើបទាក់ទាញកុមារមកសិក្សាច្រើន

## ៨. ការអភិវឌ្ឍបណ្ណាល័យ

៣៩ សកម្មភាពអំណាន និងសកម្មភាពសិស្សខ្ចីសម្ភារៈសិក្សានៅបណ្ណាល័យស្តង់ដាសតវត្សរ៍ទី២១ យកទៅសិក្សានៅផ្ទះ

## ៩. កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព

៤១ ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅបំណិនជីវិតសម្រាប់កុមារីផ្លូវការ
៤៣ សៀវភៅបំណិនជីវិតទាំង៨មុខត្រូវបានផ្សព្វផ្សាយនៅទូទាំងប្រទេស
៤៥ សេវាប្រឹក្សាអាជីពធ្វើឱ្យសិស្សអភិវឌ្ឍន៍ផែនការជីវិតកាន់តែប្រសើរ
៤៦ ការប្រឹក្សាអាជីពជាយន្តការជម្រើសជំនាញត្រឹមត្រូវសម្រាប់សិស្ស
៤៦ ការប្រឹក្សាអាជីពតាមរយៈកម្មវិធីត្រីវិស័យមានភាពងាយស្រួល
៤៧ តើមានកត្តាអ្វីខ្លះដែលសិស្សត្រូវត្រៀមខ្លួនសិក្សានៅសកលវិទ្យាល័យ?
៤៧ ការនិយាយជាសាធារណៈជាមាគា៌ទំនាក់ទំនងល្អសម្រាប់យុវជនកម្ពុជា
៤៨ នីតិវិធីក្នុងការចុះបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម និងភាពជាសហគ្រិនជាមូលដ្ឋានគ្រឹះសម្រាប់សិស្សសិក្សាចង់បង្កើតអាជីវកម្មនៅថ្ងៃមុខ

## ១០. កម្មវិធីឆ្លើយតបនឹងវិស័យអប់រំក្នុងបរិបទកូវីដ១៩

៥០ ជំនួយស្បៀងអាហារធ្វើឱ្យកុមារក្រីក្រមានកំលាំងចិត្តខិតខំសិក្សាបន្ត
៥២ កម្មវិធីចែកស្បៀងអាហារជួយដោះបញ្ហារបស់កុមារងាយរងគ្រោះ
៥៣ ការពិគ្រោះយោបល់ ស្តីពី ការប្រើប្រាស់កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមសម្រាប់ដាក់បញ្ចូលទៅក្នុងការបង្រៀន និងរៀន
៥៣ ការផ្តល់សម្ភារៈសិក្សាបន្ថែមដល់កុមារនៅសាលារៀនគោលដៅ

## ១១. ព្រឹត្តិការណ៍ ការស្រាវជ្រាវចំណេះដឹង និងការកំសាន្តផ្សេងៗ

៥៥ អង្គការ ខេបចូលរួមថវិកាជួយគ្រួសាររងគ្រោះដោយសារភ្លើងឆេះផ្ទះ
៥៥ កុមារ ម៉ាន់ត្រា បានរងគ្រោះថ្នាក់ចរាចរណ៍ក្នុងស្រុកអូរជុំ
៥៦ ការធ្វើផែនការយុទ្ធសាស្រ្តសម្រាប់រយៈពេល៥ឆ្នាំ ២០២០-២០២៤
៥៧ កុំចាំខ្ចីស្មាគេផ្អែក
៥៧ ជំនួបជាមួយ លោក W. Partick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក
៥៨ រឿងតម្លៃនៃការអាន
៥៩ ក្បួនណាប្រល័យការសិក្សាខ្ញុំ

**ព្រឹត្តិបត្រ "ការអប់រំ និងបច្ចេកវិទ្យា"**

**រៀបចំផលិត និងចេញផ្សាយដោយ**

| | | | |
|---|---|---|---|
| លោក អឿ សាវីន | រៀបចំផែនការ បង្កើតទម្រង់ និងរចនា | លោក ម៉ៃ សុខឃា | ជំនួយការបច្ចេកទេស |
| លោក ឈួន តារា | ជំនួយការបច្ចេកទេស | កញ្ញា ជួន ភាត់ថា | ប្រមូល និងសរសេរព័ត៌មាន |
| លោក ថាន់ សុខសារៈ | ជំនួយការផ្នែកទិន្នន័យ | | |

**ត្រួតពិនិត្យអក្ខរាវិរុទ្ធ និងកែសម្រួលខ្លឹមសារដោយ**

| | | | |
|---|---|---|---|
| លោក ឆន ឆៃយុទ្ធ | ត្រួតពិនិត្យរួម | កញ្ញា ស៊ីម ផល្លី | ត្រួតពិនិត្យអក្ខរាវិរុទ្ធ និងខ្លឹមសារ |
| លោក ពេជ្រ សុធឿន | ត្រួតពិនិត្យ និងកែសម្រួលខ្លឹមសារ | | |

# អំពីអង្គការ ខេប

ខេប គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធ នៅក្នុងប្រទេសកម្ពុជា។ ខេបបានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលនៅក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ កម្មវិធីអាហារូបករណ៍សម្រាប់សិស្សនៅសាកលវិទ្យាល័យ និងកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ។ ចំនួនកុមារទទួលផលផ្ទាល់មានជាង ១៥០០០០នាក់ និងគ្រូបង្រៀនជាច្រើនរយនាក់ដែលបង្រៀននៅជាង ៤០០សាលាក្នុង១៣រាជធានី-ខេត្ត។

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ខេប គឺផ្តល់លទ្ធភាពដល់កុមារ និងយុវជននូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្តានុពលរបស់ពួកគេតាមរយៈទទួលបានការអប់រំល្អ។

## បេសកកម្ម

បេសកកម្មរបស់អង្គការ ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់អំណាចដល់កុមារ និងយុវជនងាយរងគ្រោះក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រឌិតថ្មី។

## គុណតម្លៃ

- ការផ្តល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្តីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី ឬច្នៃប្រឌិតថ្មី
- តម្លាភាព
- ជឿជាក់

**ការអភិវឌ្ឍមនុស្ស ប្រកបដោយសេចក្តីថ្លៃថ្នូរ!**

# មុខងារគម្រោងរបស់អង្គការ ខេប តាមផ្នែកបច្ចេកទេសក្នុងឆ្នាំ២០២១

**គម្រោងខេបឆ្នាំ ២០២១**

| | ពាក្យបំព្រួញ | ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ | ICT សម្រាប់ការអប់រំ | ការអភិវឌ្ឍគ្រូបង្រៀន | កម្មវិធីអប់រំបរិយាប័ន្ន | កម្មវិធីអំណានថ្នាក់ដំបូង | កម្មវិធីមត្តេយ្យសិក្សា | វចនាបថហេដ្ឋារចនាសម្ព័ន្ធ | ការអភិវឌ្ឍបណ្ណាល័យ | កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព | កម្មវិធីឆ្លើយតបនឹងវិស័យអប់រំក្នុងបរិបទកូវីដ១៩ |
|---|---|---|---|---|---|---|---|---|---|---|---|
| ១. គម្រោង សៀវភៅសម្រាប់កម្ពុជា | BfC | | | | | | | | ✓ | | |
| ២. កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ-១៩ | CERRP | | ✓ | ✓ | ✓ | ✓ | | | | | ✓ |
| ៣. គម្រោងអប់រំកុមារី | GEI | | | | ✓ | | | | | ✓ | ✓ |
| ៤. គម្រោង វាយតម្លៃ-GPE3 (តេស្ត EGRA) | GPE3-PE | | | | | ✓ | | | | | |
| ៥. គម្រោង កុមារកម្ពុជារីករាយ | HCC | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៦. គម្រោង សកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា | KYLA | | | | ✓ | | | | | ✓ | |
| ៧. គម្រោង អប់រំបំណិនជីវិតសម្រាប់កុមារី | LSLAG | | | | ✓ | | | | | ✓ | |
| ៨. មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | NGPRC | ✓ | ✓ | ✓ | | | | | | | ✓ |
| ៩. គម្រោង សាលារៀនជំនាន់ថ្មី (កម្រិតបឋម) | NGS-P | ✓ | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ | ✓ |
| ១០. គម្រោង សាលារៀនជំនាន់ថ្មី (កម្រិតមធ្យម) | NGS-S | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| ១១. គម្រោង សាលារៀនជំនាន់ថ្មី/ស្វាយរៀង | NGS-SR | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| ១២. គម្រោង ពន្លកចំណេះ (ស្រាវជ្រាវប្រឹក្សាគរុកោសល្យ) | PC | | | ✓ | | | | | | | |
| ១៣. គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ | REACH IV | | | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ |
| ១៤. គម្រោង លើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា | SEEK | | | ✓ | ✓ | | | | | ✓ | ✓ |
| ១៥. គម្រោង វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ | TRAC III | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | ✓ |
| ១៦. គម្រោង អភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ២ | USE-SDP2 | | ✓ | ✓ | | | | ✓ | ✓ | ✓ | |
| ១៧. គម្រោង សហគ្រិនវ័យក្មេង | YEP | | | | ✓ | | | | | ✓ | ✓ |
| ១៨. គម្រោង សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម | Co-SAVED | | ✓ | ✓ | ✓ | | ✓ | ✓ | ✓ | ✓ | |
| ១៩. គម្រោង ងាយស្រួលរៀន | E2L | | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| **សរុបគម្រោងកំពុងដំណើរការក្នុងផ្នែកនីមួយៗ** | | ៤ | ៧ | ១១ | ១២ | ៦ | ៣ | ៦ | ៨ | ១១ | ១២ |

## ចំនួនអ្នកទទួលផលផ្ទាល់







**១២០៨៣១** សិស្សានុសិស្ស

**២៨០៦** គ្រូបង្រៀន/នាយក

**១៩៩៦** ភាគីពាក់ព័ន្ធ

## ចំនួនសាលាគោលដៅ





**១១០** មធ្យមសិក្សា

**១៧២** បឋមសិក្សា





**៩២** មត្តេយ្យសិក្សា

**១** ឧត្តមសិក្សា

## ម្ចាស់ជំនួយអង្គការ ខេប ក្នុងឆ្នាំ២០២១

unicef for every child

GPE Transforming Education

GVC WeWorld

This project is co-funded by the European Union

EDUCATE A CHILD – A programme of education above all

Aide et Action – Changing the world through Education

THE PHOENIX FOUNDATION

ChildFund Cambodia

ADB

The Asia Foundation – Improving Lives, Expanding Opportunities

OXFAM

lotus outreach INTERNATIONAL

lotus outreach SOCIETY CANADA

USAID FROM THE AMERICAN PEOPLE

pact building local promise.

Oaktree

UNESCO

FFF | Franks Family Foundation

Gap Inc.

P.A.C.E. Gap Inc. Advancing Women to Advance the World

## តំបន់គោលដៅអនុវត្តគម្រោងក្នុងឆ្នាំ២០២១របស់អង្គការ ខេប មានចំនួន ១៣ រាជធានី-ខេត្ត



# ១

# ការអភិវឌ្ឍ សាលារៀនធម្មនុញ្ញ

*"បង្កើតសាលារៀនរដ្ឋជាមួយនឹងស្តង់ដាសាលារៀនឯកជន"*

## Charter School Development

*"Creating Public Schools with Private School Standards"*



# កិច្ចប្រជុំលើកទី១ជាមួយគណៈគ្រប់គ្រងសាកលវិទ្យាល័យតិចសាស់

ចាប់តាំងពីបើកដំណើរការថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យនៅចុងឆ្នាំ២០១៩មក មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) បានដំណើរការរីកចម្រើនក្នុងការកៀរគរដៃគូអប់រំអន្តរជាតិសំខាន់ៗសម្រាប់លើកកម្ពស់វិស័យអប់រំ ជាពិសេសផ្នែកប្រឹក្សាគរុកោសល្យនៅកម្ពុជា ហើយធ្វើឱ្យកេរ្តិ៍ឈ្មោះវិទ្យាស្ថានជាតិអប់រំមានភាពល្បីសុសសាយនៅលើពិភពលោក។

នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ មជ្ឈមណ្ឌល NGPRC បានរៀបចំកិច្ចប្រជុំលើកទី១ តាមរយៈអនឡាញជាមួយគណៈគ្រប់គ្រងសាកលវិទ្យាល័យតិចសាស់ នៅសហរដ្ឋអាមេរិក។ កិច្ចប្រជុំនេះត្រូវបានធ្វើឡើងបន្ទាប់ពីមានការចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នានៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា រវាងមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីនៃវិទ្យាស្ថានជាតិអប់រំជាមួយនឹងសាកលវិទ្យាល័យតិចសាស់ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ដើម្បីស្វែងរកកិច្ចសហការ និងការគាំទ្រដល់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យរបស់មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ព្រមទាំងពង្រឹងភាពជាអ្នកដឹកនាំ ការស្រាវជ្រាវផ្នែកអប់រំ ជាពិសេសការស្រាវជ្រាវប្រតិបត្តិផ្នែកប្រឹក្សាគរុកោសល្យ។

នៅក្នុងអនុស្សារណៈយោគយល់គ្នានេះ បានផ្តោតទៅលើចំណុចសំខាន់ៗចំនួន៥ រួមមាន៖ (១)ការបង្កើតសក្តានុពលនៃកិច្ចព្រមព្រៀងផ្នែកអប់រំប្រកបដោយកិច្ចសហការសម្រាប់កម្មវិធីស្រាវជ្រាវ និងអភិវឌ្ឍន៍ទាក់ទងទៅនឹងឯកទេសប្រឹក្សាគរុកោសល្យ។ (២)ជំរុញឱ្យមានកម្មវិធីផ្លាស់ប្តូរបទពិសោធន៍សម្រាប់និស្សិត/គរុនិស្សិត ដើម្បីពង្រឹង/ពង្រីកបទពិសោធន៍នៅលើឆាកអន្តរជាតិ។ (៣)ការអភិវឌ្ឍកម្មវិធីអភិវឌ្ឍន៍អាជីពគ្រូបង្រៀនបែបនិម្មិត (អានបន្តទំព័រ ៥...)


MEMORANDUM OF UNDERSTANDING

Between

MINISTRY OF EDUCATION, YOUTH AND SPORT
OF THE KINGDOM OF CAMBODIA
National Institute of Education
New Generation Pedagogical Research Center (NGPRC)
Phnom Penh, Cambodia

And

EDUCATION LEADERSHIP RESEARCH CENTER (ELRC)
Department of Educational Administration and Human Resource Development
College of Education and Human Development
TEXAS A&M UNIVERSITY
College Station, Texas
United States of America

Whereas the above named institutions recognize that cooperating would be of mutual benefit and would serve as an indication of continued interest in joint activities, it is agreed the institutions will explore:

1. The potential establishment of a collaborative educational agreement for research and development programs related to mentoring,
2. Encouraging the exchange of students to enhance/broaden the international experience,
3. The potential development of virtual teacher professional development programs by ELRC for the NGPRC,
4. Avenues for strengthening partnership and furthering academic excellence in the United States and Cambodia, and
5. The potential development of a detailed Memorandum of Agreement.

This Memorandum of Understanding will become effective on the final date of signing and will have a duration of two (2) years. The parties have executed this Memorandum of Understanding on the day and year last specified on page two (2):


| TEXAS A&M UNIVERSITY | MINISTRY OF EDUCATION, YOUTH AND SPORT OF THE KINGDOM OF CAMBODIA National Institute of Education New Generation Pedagogical Research Center (NGPRC) |
| --- | --- |
| Dr. John L. Junkin, Interim President | H.E. Dr. Hang Chuon Naron, Minister |
| Date: 4/29/2021 \| 13:59:00 CDT | Date: 21 May 2021 |
| Dr. Joyce Alexander Dean, College of Education and Human Development | Dr. Chan Roath, Director, NGPRC |
| Date: 2/5/21 | Date: 20 May 2021 |
| Dr. Beverly J. Irby, Director, ELRC College of Education and Human Development | |
| Date: 4/29/2021 \| 14:38:12 CDT | |

# ការប្រើប្រាស់ទម្រង់សំណួរសម្រាប់បង្កើតតេស្តប្រឡង

នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ កម្មវិធីសាលារៀនជំនាន់ថ្មី សាលាបឋមសិក្សាអង្គរបាន បានរៀបចំសិក្ខាសាលាស្ដីពី **“ការប្រើប្រាស់ទម្រង់សំណួរសម្រាប់បង្កើតតេស្តប្រឡង”** តាមរយៈប្រព័ន្ធអនឡាញ (Google Meet) ដែលមានអ្នកចូលរួមសរុបចំនួន ៣៧ នាក់ដែលជាគ្រូបង្រៀន និងបុគ្គលិកអង្គការខេប។

សិក្ខាសាលានេះធ្វើឡើងជាលក្ខណៈពិភាក្សាក្រុមដោយមានគោលបំណងពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូក្នុងការបង្កើតតេស្តប្រឡងសម្រាប់ធ្វើការវាយតម្លៃតាមដំណាក់កាល និងប្រើប្រាស់ប្រភេទសំណួរសមស្របតាមសមត្ថភាពរបស់សិស្ស។

សិក្ខាសាលានេះផ្ដល់ឱកាសឱ្យលោកគ្រូអ្នកគ្រូបានជួបប្រជុំគ្នាពិភាក្សាអំពីចំណុចសំខាន់ៗ ដូចជា សុពលភាពប្រសិទ្ធភាពតេស្ត ប្រភេទសំណួរ សំណួរលំអៀង (សំណួរបើក) សំណួរមិនលំអៀង (សំណួរបិទ) ប្រភេទទម្រង់សំណួរមិនលំអៀង និងពិភាក្សាលើសំណួរដាក់ស្លែងដើម្បីងាយស្រួលក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាព។ ការបង្កើតសំណួរដោយពិភាក្សាក្រុម គឺជាវិធីសាស្ត្រច្នៃប្រឌិតល្អសម្រាប់ចៀសវាងការជាន់សំណួរ និងមានកំណត់ចំណុចវាយតម្លៃច្បាស់លាស់នៅក្នុងសំណួរដាក់ឱ្យសិស្សឆ្លើយ៕




---

(...តពីទំព័រ ៤) (ពីចម្ងាយ) ឱ្យមានសក្ដានុពលដល់មជ្ឈមណ្ឌល ស្រាវជ្រាវភាពជាអ្នកដឹកនាំអប់រំ (ELRC) សម្រាប់មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC)។ (៤)ការបង្កើតកន្លែងពង្រឹងភាពជាដៃគូ និងពង្រីកឧត្តមភាពការសិក្សានៅក្នុងសហរដ្ឋអាមេរិក និងព្រះរាជាណាចក្រកម្ពុជា និង (៥)ការអភិវឌ្ឍកិច្ចព្រមព្រៀង/លក្ខខណ្ឌលម្អិតនៅក្នុងអនុស្សារណៈយោគយល់ដ៏មានសក្ដានុពល។

អនុស្សារណៈយោគយល់គ្នានេះមានរយៈពេល ២ឆ្នាំ ដោយគិតចាប់តាំងពីថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២១ នេះតទៅ ដែលនេះជាមោទនភាពមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី និងការប្រឹក្សាគរុកោសល្យនៅព្រះរាជាណាចក្រកម្ពុជាកាន់តែមានការអភិវឌ្ឍប្រកបដោយចីរភាព។ ចក្ខុវិស័យមជ្ឈមណ្ឌលគឺការផ្លាស់ប្ដូរចរិតលក្ខណៈសាលារៀនទូទាំងប្រទេសឱ្យមានចលនាយន្តការពីគ្រូឧទ្ទេសដែលមានបទពិសោធន៍ អាចជួយបណ្ដុះបណ្ដាលទាំងវិជ្ជាជីវៈ និងក្រមសីលធម៌ ធ្វើឱ្យសាលារៀនរបស់ពួកគាត់មានភាពរីករាយ និងជាកន្លែងទាក់ទាញការសិក្សា។

កិច្ចប្រជុំនេះបានផ្ដល់ផ្លែផ្កាច្រើន បង្កើតបានការសហការរវាងគណៈគ្រប់គ្រងសាកលវិទ្យាល័យតិចសាស់ និងមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី នៃវិទ្យាស្ថានជាតិអប់រំក្នុងការលើកកម្ពស់វិស័យអប់រំឱ្យមានលក្ខណៈច្នៃប្រឌិតថ្មីៗ៕




*កិច្ចពិភាក្សាតាមប្រព័ន្ធអនឡាញជាមួយក្រុមអ្នកគ្រប់គ្រងសាកលវិទ្យាល័យតិចសាស់ ដើម្បីស្វែងរកកិច្ចសហការ និងការគាំទ្រដល់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យរបស់មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី។*

# កិច្ចសម្ភាសន៍តំណាងម្ចាស់ជំនួយជាមួយក្រុមប្រឹក្សាភិបាល និងអ្នកពាក់ព័ន្ធរបស់គម្រោងសាលារៀនជំនាន់ថ្មី ខេត្តស្វាយរៀង

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ មន្ត្រីជំនាញមកពីអង្គការឆាលហ្វានកម្ពុជា ដែលជាម្ចាស់ជំនួយរបស់គម្រោងសាលារៀនជំនាន់ថ្មី សាលាបឋមសិក្សាស្វាយព្រហូត និងវិទ្យាល័យគោកព្រីង ខេត្តស្វាយរៀង បានរៀបចំកិច្ចសម្ភាសន៍ជាមួយក្រុមប្រឹក្សាភិបាល នាយកសាលា គណៈកម្មាការគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូ និងអាណាព្យាបាលសិស្ស ដើម្បីប្រមូលព័ត៌មានពីការអនុវត្តសកម្មភាពគម្រោងក្នុងការលើកកម្ពស់ការអប់រំប្រកបដោយគុណភាព សកម្មភាពក្រុមប្រឹក្សាភិបាល ការកសាងសមត្ថភាពគ្រូបង្រៀន និងការថែទាំហេដ្ឋារចនាសម្ព័ន្ធសាលារៀន។ សកម្មភាពសំខាន់របស់កម្មវិធី គឺការបង្កើតសាលារដ្ឋស្វយ័តដែលសម្រេចបាននូវស្តង់ដាអប់រំខ្ពស់តាមលក្ខខណ្ឌវិនិយោគ។ ម៉្យាងទៀត អភិបាលកិច្ច គណនេយ្យភាព និងកម្រិតវិជ្ជាជីវៈខ្ពស់ គឺជាធាតុស្នូលដ៏សំខាន់របស់កម្មវិធី៕



*កិច្ចសម្ភាសន៍ជាមួយក្រុមប្រឹក្សាភិបាល នាយកសាលា គណៈកម្មាការគ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូ*

# ពិធីបិទបញ្ចប់គម្រោងសាលារៀនជំនាន់ថ្មី សាលាបឋមសិក្សាស្វាយព្រហូត និងវិទ្យាល័យគោកព្រីងក្នុងខេត្តស្វាយរៀង

កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ កម្មវិធីសាលារៀនជំនាន់ថ្មី-ខេត្តស្វាយរៀង (NGS-SV) ក្រោមជំនួយហិរញ្ញប្បទានពីអង្គការឆាលហ្វានកម្ពុជា បានរៀបចំសិក្ខាសាលាស្តីពី **"ការឆ្លុះបញ្ចាំងបញ្ចប់គម្រោង"** តាមប្រព័ន្ធអនឡាញ (Zoom) ដើម្បីពិនិត្យមើលបច្ចុប្បន្នភាពវឌ្ឍនភាពលើការអនុវត្តសកម្មភាពគម្រោងសាលារៀនជំនាន់ថ្មី និងការបិទបញ្ចប់គម្រោងក្នុងជុំទី២។ សមាសភាពអ្នកចូលរួមសរុបមានចំនួន ៥២នាក់ រួមមានៈ ក្រុមប្រឹក្សាភិបាលថ្នាក់ខេត្ត គណៈកម្មការគ្រប់គ្រងសាលារៀន តំណាងម្ចាស់ជំនួយមកពីអង្គការឆាលហ្វាន តំណាងមាតាបិតាសិស្ស លោកគ្រូអ្នកគ្រូ និងបុគ្គលិកគម្រោង។

លោក **ឌៀវ សំអុល** ប្រធានក្រុមប្រឹក្សាភិបាលសាលារៀនជំនាន់ថ្មីថ្នាក់ខេត្ត បានមានប្រសាសន៍ថា *"សាលារៀនជំនាន់ថ្មី សាលាបឋមសិក្សាស្វាយព្រហូត និងវិទ្យាល័យគោកព្រីង មានការអភិវឌ្ឍជាបន្តបន្ទាប់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ គុណភាពអប់រំល្អ សមត្ថភាពគ្រូបង្រៀនមានការរីកចម្រើនទៅមុខ មានសម្ភារៈឧបទេសគ្រប់គ្រាន់ ការគ្រប់គ្រង និងដឹកនាំរបស់គណៈនាយកមានការរីកចម្រើន។ បើគម្រោងត្រូវបានបញ្ចប់ការគាំទ្រដល់សាលារៀននៅពេលនេះ វាជាការលំបាកខ្លាំងណាស់ ពីព្រោះសាលាមិនទាន់មានថវិកាគាំទ្រគ្រូបង្រៀនដោយខ្លួនឯងនៅឡើយ"*។

លោក **សោម សំ** នាយកសាលាបឋមសិក្សាស្វាយព្រហូតបានមានប្រសាសន៍ថា *"គម្រោងសាលារៀន*

(អានបន្តទំព័រ ៧...)



*សកម្មភាពក្រុមប្រឹក្សាភិបាល នាយកសាលា គណៈកម្មាការគ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូក្នុងវគ្គសិក្ខាសាលា*

(...តពីទំព័រ ៦) *ជំនាន់ថ្មី បានផ្តួចផ្តើមសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាលារៀន ដូចជា ការជួសជុលអគារសិក្សា អភិវឌ្ឍន៍បណ្ណាល័យបែបសតវត្សរ៍ទី២១ បំពាក់គ្រឿងសង្ហារិម ក្តារខៀនកញ្ចក់ ទូតាំងសម្ភារៈស្នាដៃសិស្ស សម្ភារៈពិសោធន៍ មានកុំព្យូទ័រយួរដៃសម្រាប់គ្រូបង្រៀន និងសម្ភារៈជាច្រើនផ្សេងៗទៀត។ ជាពិសេស គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពគ្រូបង្រៀន ផ្តល់វិធីសាស្ត្របង្រៀនថ្មីៗ ការបង្កើតសំណួរតេស្ត ការប្រើប្រាស់បច្ចេកវិទ្យាជំនួយក្នុងការបង្រៀន និងរៀនក្នុងយុគសម័យឌីជីថល។ លោកបានបន្តទៀតថា បើគម្រោងសាលារៀនជំនាន់ថ្មីបញ្ចប់នៅពេលនេះ វាជាការព្រួយបារម្ភរបស់គណៈគ្រប់គ្រងសាលាក្នុងការបន្តនិរន្តភាព ដោយសារសាលាមិនមានថវិកាគាំទ្រដល់លោកគ្រូអ្នកគ្រូ និងថវិកាដើម្បីដំណើការសាលារៀនស្របតាមកម្មវិធីសាលារៀនជំនាន់ថ្មីនោះទ្បើយ*"។

លោក **គង់ ណារិន** នាយកវិទ្យាល័យគោកព្រីង បានមានប្រសាសន៍ថា "*សាលារៀនមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងមោទនភាពបំផុត ក្រោយពេលចាប់ដៃគូជាមួយគម្រោងសាលារៀនជំនាន់ថ្មី។ គម្រោងបានកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ផ្តល់អាហារូបករណ៍ជូនលោកគ្រូអ្នកគ្រូបានបន្តថ្នាក់បរិញ្ញាបត្រ មានទស្សនកិច្ចសិក្សាទៅក្រៅប្រទេសពាក់ព័ន្ធនឹងការបង្រៀន និងរៀន ធ្វើការពិសោធន៍ជាក់ស្តែងមានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ ក្លឹបសិក្សា និងផ្តល់ប្រាក់លើកទឹកចិត្តជូនគ្រូបង្រៀនតាមភារកិច្ច។ លោកបានបន្ថែមទៀតថា សាលាមានសិទ្ធិប្រមូលប្រាក់មូលនិធិសមធម៌ពីមាតាបិតាសិស្សសម្រាប់គាំទ្រដំណើការសាលារៀនក៏ពិតមែន ប៉ុន្តែថវិកានេះនៅតែមិនសមមូលនឹងការចំណាយនៅឡើយ*"។

ជាការឆ្លើយតបនឹងបរិបទនេះ និងការប្រតិបត្តិគម្រោងបន្តឱ្យបានជោគជ័យ លោក **អ៊ុល រុន** ទីប្រឹក្សាជាតិជាន់ខ្ពស់អង្គការ ខេប បានមានប្រសាសន៍ថា "*កម្មវិធីសាលារៀជំនាន់ថ្មីមានគោលនយោបាយច្បាស់លាស់ ដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបណ្តុះបណ្តាលធនធានមនុស្សនៅមជ្ឈមណ្ឌលគរុកោសល្យឱ្យមានសមត្ថភាពខ្ពស់ មានក្រមសីលធម៌ មានចំណេះដឹងផ្នែកព័ត៌មានវិទ្យា ការទំនាក់ទំនង និងបច្ចេកវិទ្យា (ICT) ការស្រាវជ្រាវ ការគាំទ្រគ្រូបង្រៀនដើម្បីបន្តនិរន្តភាពចំពោះសាលារៀនជំនាន់ថ្មីដែលបានវាយតម្លៃជាប់ ដោយទទួលស្គាល់គុណភាពអប់រំពីក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ។ ទោះបីជាអង្គការឆាលហ្វានបានបិទបញ្ចប់គម្រោងនៅថ្ងៃនេះក៏ពិតមែន តែកម្មវិធីសាលារៀនជំនាន់ថ្មីមិនត្រូវបានបញ្ចប់នោះឡើយ។ សាលារៀនខ្លួនឯងត្រូវតែចេះស្វែងរកថវិកាគាំទ្របន្ត ហើយអង្គការ ខេប នឹងបន្តជួយគាំទ្រផ្នែកបច្ចេកទេសដល់បណ្តាញសាលារៀនជំនាន់ថ្មី*"។

លោកនាយកសាលារៀនជំនាន់ថ្មីទាំងពីរ គណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូ និងអ្នកពាក់ព័ន្ធផ្សេងៗ បានសំណូមពរដល់អង្គការឆាលហ្វានកម្ពុជា ឱ្យបន្តជួយគាំទ្រថវិកាដល់សាលារៀនជំនាន់ថ្មី សាលាបឋមសិក្សាស្វាយព្រហូត និងវិទ្យាល័យគោកព្រីង ឱ្យបានយ៉ាងហោចណាស់ត្រឹមមួយឆ្នាំសិក្សាទៀត ដើម្បីធ្វើយ៉ាងណាឱ្យសាលារៀននេះមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រមូលថវិកាសម្រាប់ឆ្នាំសិក្សាថ្មីសម្រាប់គាំទ្រសកម្មភាពផ្តល់សេវាអប់រំប្រកបដោយសកម្មភាពផុសផុល និងរក្សាបាននូវនិរន្តរភាព៕

# ២

# ព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាសម្រាប់ការអប់រំ

"បច្ចេកវិទ្យានឹងមិនអាចជំនួសគ្រូដ៏ឆ្នើមៗបានទេ ប៉ុន្តែគ្រូឆ្នើមៗ
ក៏មិនអាចអត់បច្ចេកវិទ្យាសម្រាប់ផ្លាស់ប្តូរដែរ"

# Informatics, Communication and Technology (ICT) in Education

*"Technology will never replace great teachers,
but in the hands of great teachers, it's transformational"*

# កម្មវិធី (Apps) សម្រាប់ធ្វើទំនាក់ទំនងក្នុងបរិបទជំងឺកូវីដ-១៩



បច្ចុប្បន្ននេះ ជំងឺកូវីដ-១៩ នៅតែបន្តឆ្លងរីករាលដាលពាសពេញផ្ទៃប្រទេសកម្ពុជា ដែលមិនអនុញ្ញាតឱ្យមនុស្សមានការជួបជុំគ្នាច្រើន ហើយវាបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើល្បឿននៃការអភិវឌ្ឍក្នុងប្រព័ន្ធអប់រំនៅកម្ពុជា។ ទោះបីយាងនេះក្តី អង្គការ ខេប នៅតែបន្តប្រតិបត្តិសកម្មភាពជួយអន្តរាគមន៍ដល់សាលារៀនគោលដៅទាំងអស់ក្នុងខេត្តចំនួន ១៣ ដោយផ្តោតលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការប្រាស្រ័យទាក់ទងក្នុងបរិបទការងារតាមរយៈសកម្មភាពជាច្រើន ដូចជា ការរៀបចំកម្មវិធីសិក្ខាសាលា វគ្គបណ្តុះបណ្តាល វេទិកា កិច្ចប្រជុំ និងកម្មវិធីផ្សេងៗលើប្រព័ន្ធអនឡាញទាំងអស់វិញ។ ទន្ទឹមនឹងនេះដែរ កម្មវិធី (Apps) ចំនួនពីរដែលអង្គការ ខេប បានកំពុងប្រើប្រាស់ច្រើនបំផុតសម្រាប់ភ្ជាប់ទំនាក់ទំនង រួមមាន៖ កម្មវិធី Zoom និងកម្មវិធី Google Meet។

កម្មវិធីទាំងពីរនេះត្រូវបានអង្គការ ខេប ទិញអាជ្ញាប័ណ្ណត្រឹមត្រូវក្នុងការប្រើប្រាស់សម្រាប់ជួយសម្រួលដល់ការងារប្រជុំ ដំណើរការបណ្តុះបណ្តាល និងសិក្ខាសាលាយ៉ាងល្អប្រសើរ ដែលមានតួនាទីសំខាន់ៗស្រដៀងគ្នាច្រើន ដូចជា ទី១ វាមិនកំណត់រយៈពេលក្នុងការប្រជុំ មានន័យថា យើងអាចរៀបចំការប្រជុំ ឬសិក្ខាសាលាបានច្រើនម៉ោងដោយមិនបារម្ភពីការដាច់ និងរអាក់រអួលរំខាន គួបផ្សំប្រព័ន្ធអ៊ិនធឺណេតល្អ និងអាចកំណត់អ្នកចូលរួមបានយ៉ាងច្រើន គឺអាចបានពី ១០០ ដល់ ៥០០នាក់ ឬ១០០០នាក់អាស្រ័យលើអ្នកជ្រើសរើសលើកញ្ចប់កម្មវិធីរបស់វា។ ទី២ វាអាចថតវីដេអូផ្ទុកទៅកាន់ Cloud សម្រាប់ Zoom ចំណែកឯ Google Meet ផ្ទុកនៅក្នុង Google Drive។ វាមានសមត្ថភាពចាប់យកសកម្មភាពទាំងអស់បានក្នុងការប្រជុំគ្រាន់តែចុចលើឧបករណ៍ថត (Recording)។ ដូច្នេះ អ្នកអាចផ្ញើវីដេអូនៃការប្រជុំ សិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលនោះទៅកាន់អ្នកដែលមិនបានចូលរួមកម្មវិធី និងងាយស្រួលក្នុងការធ្វើរបាយការណ៍។ ទី៣ វាអាចធ្វើការផ្សព្វផ្សាយបន្តទៅកាន់បណ្តាញសង្គម អ្នកអាចភ្ជាប់ការប្រជុំទៅកាន់សាធារណៈនៅលើកម្មវិធីហ្វេសប៊ុក (Facebook) និងយូធូប (YouTube) ដើម្បីផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយទៅដល់អ្នកមើល និងទី៤ វាអាចគ្រប់គ្រងអ្នកចូលរួមក្នុងកម្មវិធីទាំងមូលបាន គឺ អ្នក Host ឬ Admin អាចមានសិទ្ធិដកអ្នកចូលរួមចេញបានក្នុងករណីចាំបាច់។ ឧទាហរណ៍ Admins អាចមានសិទ្ធិបិទសំឡេង ឬវីដេអូដែលរំខានអំឡុងពេលប្រជុំ មានសិទ្ធិថតជាវីដេអូ និងអាចបែងចែកជាក្រុមតូចៗដើម្បីពិភាក្សាក្រុមព្រមទាំងអាចគ្រប់គ្រងសកម្មភាពទាំងមូលបានដោយងាយស្រួល។

គម្រោងរបស់អង្គការ ខេប ទាំងអស់បានប្រើប្រាស់កម្មវិធីទាំងពីរនេះសម្រាប់ទំនាក់ទំនងជាមួយលោកនាយក នាយិកា លោកគ្រូអ្នកគ្រូ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ ការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ស្រុក អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងៗទៀតក្នុងការងារសហការជួយអន្តរាគមន៍ដល់សាលារៀនគោលដៅសម្រាប់ឆ្លើយតបឱ្យបានទាន់ពេលវេលា ទោះបីជាស្ថិតក្នុងបរិបទជំងឺកូវីដ-១៩ កំពុងនៅតែរីករាលដាលក្តី ប៉ុន្តែអង្គការ ខេប នៅតែរក្សាបានការប្រតិបត្តិគម្រោងដោយជោគជ័យ៕

# ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌បានជំរុញការសិក្សាបែបចម្រុះ ក្នុងបរិបទជំងឺកូវីដ-១៩

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំវគ្គបណ្តុះបណ្តាលជាស៊េរីស្តីពី **“ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌បានជំរុញការសិក្សាបែបចម្រុះ ក្នុងបរិបទជំងឺកូវីដ-១៩”** តាមប្រព័ន្ធអនឡាញ (Zoom) ដែលមានអ្នកចូលរួមសរុបចំនួន ១០០នាក់ រួមមាន៖ នាយក/នាយិកា លោកគ្រូអ្នកគ្រូ បុគ្គលិកអង្គការ ខេប និងអ្នកពាក់ព័ន្ធផ្សេងៗ។ ការបណ្តុះបណ្តាលនេះបានប្រព្រឹត្តទៅជាបន្តបន្ទាប់គ្នាចំនួន៣វគ្គ ដល់សិក្ខាកាមដែលមកពីរាជធានី-ខេត្ត ដើម្បីធ្វើការឆ្លុះបញ្ចាំងពីរបៀបអនុវត្តបំណិន និងយុទ្ធសាស្ត្រថ្មីៗ ព្រមទាំងដោះស្រាយបញ្ហាប្រឈមនានា។

វគ្គបណ្តុះបណ្តាលនេះមានគោលបំណងសំខាន់ៗមួយចំនួន ៣ ដូចជា ១-ស្វែងយល់ពីអត្ថន័យការសិក្សាបែបចម្រុះ និងរបៀបផ្តល់អត្ថប្រយោជន៍ដល់សិស្ស។ ២-ស្វែងយល់ពីភាពខុសគ្នារវាងថ្នាក់រៀន ដែលមានបច្ចេកវិទ្យាសម្បូរបែប និងថ្នាក់រៀនដែលរៀនបែបចម្រុះ។ ៣-ស្វែងយល់គំរូផ្សេងៗនៃការសិក្សាបែបចម្រុះ និង ៤-ស្វែងរកឧបករណ៍បច្ចេកវិទ្យាដែលអាចប្រើប្រាស់ក្នុងការជួយសម្រួលដល់ការសិក្សាបែបចម្រុះ។

លោក អ៊ុល រុន ប្រធានប្រតិបត្តិកម្មវិធីសាលារៀនជំនាន់ថ្មី ត្រូវបានអញ្ជើញចូលរួមជាវាគ្មិនកម្មវិធីនេះធ្វើការចែករំលែកនូវបទពិសោធន៍ថ្មីៗទាក់ទងទៅនឹងការសិក្សាបែបចម្រុះ ដើម្បីទទួលបានប្រសិទ្ធិភាពខ្ពស់ក្នុងកាបង្រៀន និងរៀន៕




*លោក អ៊ុល រុន ប្រធានប្រតិបត្តិកម្មវិធីសាលារៀនជំនាន់ថ្មី ចូលរួមធ្វើបទបង្ហាញពីការសិក្សាបែបចម្រុះ*

**“គ្រូបង្រៀនត្រូវមានបំណិនឌីជីថលដែលទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន និងចំណេះដឹងចិត្តវិទ្យាគរុកោសល្យ។ តួនាទីគ្រូក្នុងយុគសម័យឌីជីថល គឺជាអ្នកបង្ហាញផ្លូវដល់សិស្ស សួរសំណួរឱ្យសិស្សចេះគិត វិភាគរកចម្លើយ បង្រៀនសិស្សតាមបែបការរៀនដោះស្រាយបញ្ហា និងការរៀនតាមបែបត្រិះរិះ ជាពិសេសរៀបចំសកម្មភាពឱ្យសិស្សរៀនដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។”**

ដកស្រង់ចេញពីបទបង្ហាញស្តីពី គ្រូបង្រៀនឆ្លាតវៃ ដើម្បីការអប់រំឌីជីថលនៅកម្ពុជា
ដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# ៣

# ការអភិវឌ្ឍគ្រូបង្រៀន

"គ្រូដែលល្អមិនមែនគ្រាន់តែជាអ្នកប្រាប់ ជាអ្នកពន្យល់ និងបង្ហាញនោះទេ
តែជាអ្នកជំរុញលើកទឹកចិត្តសិស្ស"

# Teacher Development

*"The mediocre teacher tells. The good teacher explains.
The superior teacher demonstrates. The great teacher inspires."*



# សន្និសីទជាតិលើកទី១ ស្តីពី ការប្រឹក្សាគរុកោសល្យ ក្រោមប្រធានបទ ការបង្កើតសហាគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូប្រឹក្សាគរុកោសល្យ

សន្និសីទជាតិរយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី២៨ ដល់ទី៣០ ខែកក្កដា ឆ្នាំ២០២១ រៀបចំដោយមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) នៃវិទ្យាស្ថានជាតិអប់រំ ក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) ក្រោមប្រធានបទ: **“ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូប្រឹក្សាគរុកោសល្យ”** ដែលត្រូវបានរៀបចំឡើងតាមប្រព័ន្ធអនឡាញ(Zoom)។ អ្នកសិក្សាស្រាវជ្រាវ គ្រូបង្រៀន គ្រូឧទ្ទេស ទីប្រឹក្សាអប់រំ និងអ្នកប្រឹក្សាយោបល់ បានអញ្ជើញចូលរួមចែករំលែកចំណេះដឹង និងបទពិសោធន៍ក្នុងការឆ្លើយតបទៅនឹងការប្រឹក្សាគរុកោសល្យ និងការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈក្នុងបរិបទកំណែទម្រង់វិស័យអប់រំនៅព្រះរាជាណាចក្រកម្ពុជា ដែលមានអ្នកចូលរួមសរុបចំនួន ១០០០នាក់ ជាបុគ្គលិកអប់រំមកពីគ្រប់រាជធានីខេត្ត។

គោលបំណងសន្និសីទជាតិលើកទី១ នេះត្រូវបានរៀបចំឡើងសម្រាប់ផ្លាស់ប្តូរយោបល់តាមរយៈកិច្ចពិភាក្សាពីគំរូផ្សេងៗគ្នានៃការប្រឹក្សាគរុកោសល្យ ទស្សនៈយល់ឃើញលើការអនុវត្តវិជ្ជាជីវៈប្រឹក្សាគរុកោសល្យ និងបានផ្តល់ឱកាសដល់គ្រូប្រឹក្សាគរុកោសល្យក្នុងការរក្សាបាននូវបណ្តាញទំនាក់ទំនងជាសហគមន៍ ព្រមទាំងបានអភិវឌ្ឍន៍សមត្ថភាពចំណេះដឹង និងបទពិសោធន៍។

សកម្មភាពសំខាន់ៗនៅក្នុងសន្និសីទថ្នាក់ជាតិនេះ រួមមាន៖ ១) ការផ្តល់ជាវេទិកាសម្រាប់ការធ្វើបទបង្ហាញចែករំលែកអំពីលទ្ធផលសិក្សាស្រាវជ្រាវ។ ២) បង្ហាញគន្លឹះ និងមធ្យោបាយថ្មីៗដើម្បីជំរុញឱ្យមានឧត្តមភាពក្នុងវិស័យអប់រំតាមរយៈសកម្មភាព និងគំនិតច្នៃប្រឌិតផ្សេងៗ។ ៣) ចែករំលែកការអនុវត្តវិធីសាស្ត្របង្រៀនល្អៗ និងប្រើប្រាស់លទ្ធផលពីការសិក្សាស្រាវជ្រាវដើម្បីដោះស្រាយបញ្ហាប្រឈមនៅតាមសាលារៀន។ ៤) ចែករំលែកគំរូផ្សេងៗ បទពិសោធន៍ និងជំនាញដែលទាក់ទងទៅនឹងការប្រឹក្សាគរុកោសល្យតាមសាលារៀន។ ៥) បង្កើតឱ្យមានភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការរវាងអ្នកស្រាវជ្រាវនៅទូទាំងប្រទេស។ ៦) ផ្សព្វផ្សាយលទ្ធផលនៃនិក្ខេបបទ ឬសារណានៅថ្នាក់ឧត្តមសិក្សា។ និង ៧) បង្ហាញពីទស្សនៈថ្មីៗដើម្បីចូលរួមដោះស្រាយបញ្ហាអប់រំក្នុងក្របខណ្ឌកំណែទម្រង់អប់រំនៅកម្ពុជា។

សន្និសីទនេះបានកំណត់ប្រធានបទសំខាន់ៗជាទូទៅ ដូចជា ភាពជាគំរូនៃការប្រឹក្សាគរុកោសល្យនៅតាមគ្រឹះស្ថានសិក្សា ការបញ្ជ្រាបការប្រឹក្សាគរុកោសល្យក្នុងយុគសម័យឌីជីថល ការសិក្សាស្រាវជ្រាវអំពីការប្រឹក្សាគរុកោសល្យ និងប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា។

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា *“គ្រូបង្រៀនត្រូវតែធ្វើការសិក្សាស្រាវជ្រាវពីវិធីសាស្ត្របង្រៀន និងរៀនបំណិនថ្មីៗដើម្បីធ្វើការអភិវឌ្ឍខ្លួនជាប់ជានិច្ចឥតឈប់ឈរ ដែលធ្វើឱ្យការបង្រៀនមានការវិវឌ្ឍតាមសម័យកាលដោយប្រើប្រាស់វិធីសាស្ត្របង្រៀនបែបសតវត្សរ៍ទី២១ ដូចជា ១) វិធីសាស្ត្របង្រៀន និង* (អានបន្តទំព័រ១៣...)




*ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាបានចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងសន្និសីទជាតិលើកទី១ ដែលបានធ្វើបទបង្ហាញពី នវានុវត្តន៍ និងទិសដៅការងារនៃគោលដៅកំណែទម្រង់វិស័យអប់រំ។*

( ...តពីទំព័រ ១២ ) រៀនតាមបែបត្រិះរិះ ធ្វើឱ្យសិស្សអាចទទួលបានបំណិនចេះរៀនដោយខ្លួនឯង។ (២) វិធីសាស្ត្ររៀនដោយប្រើប្រាស់ខួរក្បាល ធ្វើឱ្យសិស្សមានការអភិវឌ្ឍខ្លួនចេះរិះរកតាមបែបវិទ្យាសាស្ត្រ យល់ដឹងពីមនោសញ្ចេតនាក្នុងការរៀន យល់ដឹងពីការចងចាំ និងអាចដោះស្រាយបញ្ហាបាន។ (៣) វិធីសាស្ត្របង្រៀនដោះស្រាយបញ្ហា ធ្វើឱ្យសិស្សរៀនបែបសកម្ម និងលើកកម្ពស់ការអនុវត្តចំណេះដឹងដើម្បីដោះស្រាយបញ្ហាជាក់ស្តែង។ (៤) វិធីសាស្ត្របង្រៀនតាមបែបសហការ ជួយឱ្យសិស្សចេះធ្វើការងារជាក្រុម។(៥) វិធីសាស្ត្របង្រៀនបញ្ចូលគ្នា ជួយឱ្យសិស្សចេះរៀនដោយឯករាជ្យតាមបែបត្រិះរិះពិចារណា ចេះវិភាគភ្ជាប់គំនិតផ្សេងៗធ្វើការសន្និដ្ឋាន។ (៦) វិធីសាស្ត្របង្រៀនតាមបែបសូក្រាត ឱ្យសិស្សចេះគិត សួរសំណួរ ចេះសំយោគ ធ្វើការតស៊ូមតិ និងសន្ទនា"។ លោកបានបន្តទៀតថា "គ្រូបង្រៀននៅក្នុងយុគសម័យឌីជីថលនេះត្រូវចេះប្រើប្រាស់បច្ចេកវិទ្យា ដើម្បីជំនួយដល់ការបង្រៀនប្រកបដោយប្រសិទ្ធភាព ដោយបូករួមការយល់ដឹងពីរបៀបរៀនរបស់សិស្ស រៀបចំកិច្ចតែងការឱ្យបានច្បាស់លាស់ស្របតាមកម្មវិធី រៀបចំសម្ភារៈ និងប្រើប្រាស់វិធីសម្បូរបែបសម្រាប់ធ្វើការវាយតម្លៃលទ្ធផលសិក្សា"។



លោកបណ្ឌិតសភាចារ្យ ច័ន្ទ រ័ត្ន ប្រធានគណៈកម្មការរៀបចំសន្និសីទជាតិ

ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ រ័ត្ន ប្រធានគណៈកម្មការរៀបចំសន្និសីទជាតិនេះ បានមានប្រសាសន៍ថា "ក្នុងបរិបទជំងឺកូវីដ-១៩នេះ ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងដំណើរការបង្រៀន និងរៀន គឺជាកត្តាចម្បងដើម្បីធានាដល់ដំណើរការអប់រំ និងផ្ទេរចំណេះដឹងនៅរក្សាបានគុណភាពនៃការអប់រំ។ សន្និសីទជាតិនេះបានចូលរួមចំណែកក្នុងការចែករំលែកចំណេះដឹង បទពិសោធន៍កិច្ចការងារប្រឹក្សាគរុកោសល្យ និងបញ្ហាបការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំ ព្រមទាំងបានឆ្លុះបញ្ចាំងពីតួនាទី និងសារៈសំខាន់នៃគ្រូប្រឹក្សាគរុកោសល្យនៅសាលារៀន។ ម៉្យាងទៀត សន្និសីទនេះ អាចជាកាលានុវត្តភាពឆ្លើយតបទៅនឹងកិច្ចខិតខំប្រឹងប្រែងបង្កើតឱ្យមានសហគមន៍សិក្សាវិជ្ជាជីវៈបណ្តាញអ្នកសិក្សាវិជ្ជាជីវៈ និងជំរុញឱ្យមានកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធលើវិជ្ជាជីវៈប្រឹក្សាគរុកោសល្យ"។

លោក **ឃីត ប្រៃជិនប៊ែក** ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់របស់អង្គការ ខេប បានមានប្រសាសន៍ថា "ការអប់រំនៅសតវត្សរ៍ទី២១ គ្រូបង្រៀនត្រូវបង្រៀនសិស្សឱ្យចេះត្រិះរិះពិចារណា រៀនបែបសកម្ម វិភាគវែកញែក ស្រាវជ្រាវ បង្កើតស្នាដៃ ចេះរៀនជាក្រុម ចេះបត់បែន និងច្នៃប្រឌិត"។ លោកបន្តទៀតថា "សាលារៀនមិនគួរមានស្តង់ដាតែមួយនោះទេ វាគួរមានភាពចម្រុះគ្នា ដូចជា ការរៀបចំកម្មវិធីសិក្សា របៀបបង្រៀន ការធ្វើ ( ...អានបន្តទំព័រ១៤ )



(...តទំព័រ ១៣) តេស្ត និងការកំណត់ជាក់ស្តែងតាមលក្ខណៈបុគ្គល។ ការធ្វើបែបនេះ សាលា



រៀននឹងមានសេរីភាព និងមានលទ្ធភាពក្នុងការផ្តល់គុណភាពអប់រំប្រកបដោយគំនិតច្នៃប្រឌិតខ្ពស់"។

ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ បានមានប្រសាសន៍ថា *"គ្រូបង្រៀនដើរតួនាទីសំខាន់ណាស់ ព្រោះពួកគាត់ជាអ្នកផលិតសម្រាប់ឱ្យទៅបម្រើការងារនៅគ្រប់វិស័យក្នុងសង្គម ហើយក៏ជាវិស្វករនៃព្រលឹងជាតិ ដែលរដ្ឋបានផ្តល់ទំនុកចិត្តឱ្យបង្រៀន និងអប់រំយុវជន យុវនារី ដែលជាសសរទ្រូងដ៏មានតម្លៃមិនអាចកាត់ថ្លៃបានចំពោះគ្រួសារ និងសង្គមជាតិទាំងមូល។ ប្រទេសជាតិទទួលបានការរីកចម្រើនអាស្រ័យទៅលើធនធានមនុស្ស ដែលគ្រូបង្រៀនគ្រប់កម្រិត និងគ្រប់វិស័យផលិតបាន"*។ លោកបានបន្តទៀតថា *"វិស្វករសំណង់ម្នាក់បំពេញភារកិច្ចរបស់ខ្លួនមិនបានល្អ ធ្វើការខ្ជីខ្ជា ការខូតខាតមានតែសម្ភារៈ ឬបើធ្ងន់ធ្ងរជាងនេះនឹងវិនាសតែគ្រួសារមួយប៉ុណ្ណោះ។ ផ្ទុយទៅវិញ បើគ្រូបង្រៀនម្នាក់ដែលខ្វះចំណេះដឹង ខ្វះសីលធម៌ ហើយបំពេញភារកិច្ចរបស់ខ្លួនមិនទទួលបានជោគជ័យ ផ្តល់ការអប់រំគ្មានគុណភាព នោះប្រទេសជាតិនឹងត្រូវទទួលផលវិបាកជាមិនខាន។ ការធ្វើកំណែទម្រង់ប្រព័ន្ធបណ្តុះ*



*បណ្តាលគ្រូបង្រៀននៅកម្ពុជាគឺជាការចាំបាច់ក្នុងការសម្រេចបាននូវកំណើនការងារ សមធម៌ និងប្រសិទ្ធភាពដែលជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នាឆ្នាំ២០៥០"*។

សន្និសីទជាតិនេះបានបង្កលទ្ធភាពច្រើនក៏ដូចជាផ្តល់ឱកាសដល់អ្នកចូលរួមចែករំលែកចំណេះដឹង គោលគំនិតផ្សេងៗ បទពិសោធន៍ល្អៗ លទ្ធផលសិក្សាស្រាវជ្រាវ និងកិច្ចពិភាក្សាលើបញ្ហាប្រឈមនានា ដែលទាក់ទងទៅនឹងការប្រឹក្សាគរុកោសល្យ ព្រមទាំងបានអនុញ្ញាតឱ្យអ្នកចូលរួមអាចអនុវត្តទៅតាមគន្លងអាជីពរបស់ខ្លួន ដើម្បីចូលរួមបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់អ្នកប្រឹក្សាគរុកោសល្យ។ សន្និសីទជាតិលើកទី២នឹងធ្វើការរៀបចំ និងជូនដំណឹងនៅពេលខាងមុខបន្តទៀត ដោយធ្វើការជ្រើសរើសប្រធានបទល្អៗ និងវាគ្មិនដែលមានបទពិសោធន៍នៅក្នុងវិស័យអប់រំយូរឆ្នាំមកធ្វើការចែករំលែកដល់សន្និសីទ ជាពិសេសប្រធានបទដែលទាក់ទងនឹងជំនាញប្រឹក្សាគរុកោសល្យនៅកម្ពុជា៕




*រូបភាពក្នុងសន្និសីទជាតិលើកទី១ ថតរូបជុំគ្នាជាមួយអ្នកចូលរួម។*

# គ្រូបង្រៀនទទួលបានវគ្គបណ្តុះបណ្តាលពីកម្មវិធីសាលារៀនជំនាន់ថ្មី

នៅមុនពេលមានគម្រោងសាលារៀនជំនាន់ថ្មីចូលមក វិទ្យាល័យ ហ៊ុន សែន ពាមជីកង ដែលស្ថិតក្នុងស្រុកកងមាស ខេត្តកំពង់ចាម មានបញ្ហាប្រឈមជាច្រើន ដូចជា ខ្វះខាតសម្ភារៈបរិក្ខារក្នុងបន្ទប់រៀន មិនបានប្រើប្រាស់បច្ចេកវិទ្យាទំនើប បញ្ហាចំនួនសិស្សច្រើនពេកក្នុងថ្នាក់រៀននីមួយៗ គឺលើសស្តង់ដា ជាពិសេសគ្រូបង្រៀនមិនសូវទទួលបានវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រថ្មីៗក្នុងការបង្រៀន និងរៀននោះឡើយ។

ក្រោយពីមានការអន្តរាគមពីគម្រោងសាលារៀនជំនាន់ថ្មីមក អ្វីៗទាំងអស់នៅក្នុងសាលានេះមានការប្រែប្រួលវិជ្ជមានច្រើន ជាពិសេសការបង្រៀនរបស់គ្រូ។



*អ្នកគ្រូ សុខ លីណា (ឯកទេសភូមិវិទ្យា) បានចូលរួមសិក្ខាសាលានៅប្រទេសម៉ាឡេស៊ីស្តីពីការប្រើប្រាស់បច្ចេកវិទ្យាដើម្បីពង្រឹងវិធីសាស្ត្រក្នុងការបង្រៀន ក្នុងឆ្នាំ២០២១*

អ្នកគ្រូ **សុខ លីណា** ជាគ្រូបង្រៀននៅសាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន ពាមជីកង មានបទពិសោធន៍បង្រៀនអស់រយៈពេល១៧ឆ្នាំ និងបានដាក់ពាក្យស្នើសុំចូលរួមបង្រៀននៅក្នុងកម្មវិធីសាលារៀនជំនាន់ថ្មីចាប់តាំងពីឆ្នាំ២០១៨មក។ អ្នកគ្រូបានលើកឡើងថា"*នាងខ្ញុំទទួលបានចំណេះដឹងបន្ថែមជាច្រើនរួមមាន៖ វិធីសាស្ត្របង្រៀនថ្មីៗ ចេះបង្កើតតេស្ត វិភាគតេស្ត ការចេះប្រើប្រាស់បច្ចេកវិទ្យាជំនួយដល់ការបង្រៀន ការធ្វើតេស្តតាមប្រព័ន្ធអនឡាញ និងការស្រាវជ្រាវតាមអ៊ីនធឺណិត។ លទ្ធផលទាំងនេះពិតជាបានពង្រឹងសមត្ថភាព និងអភិវឌ្ឍន៍វិជ្ជាជីវៈជាគ្រូបង្រៀនដើម្បីដើរឱ្យទាន់យុគសម័យឌីជីថលក្នុងសតវត្សរ៍ទី២១នេះ។ នាងខ្ញុំសូមសំណូមពរឱ្យអង្គការ ខេបបន្តគម្រោងសាលារៀនជំនាន់ថ្មីឱ្យបានច្រើនសាលានៅក្នុងប្រទេសកម្ពុជា ព្រោះកម្មវិធីសាលារៀនជំនាន់ថ្មីបានពង្រឹងការអនុវត្តការងាររបស់សាលាឱ្យមានតម្លាភាព គណនេយ្យភាព និងបានជួយដោះស្រាយបញ្ហាផ្សេងៗ ជាពិសេសសជួយអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន*ប្រកបដោយប្រសិទ្ធភាពសម្រាប់កសាងធនធានមនុស្សនៅកម្ពុជា៕

---

# កម្មវិធីបំប៉នគ្រូបង្រៀនកិច្ចសន្យា




*ការប្រជុំតាម Google meet ក្រុមទី៣ មានអ្នកចូលរួម៤១នាក់*

គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (REACH IV) បានរៀបចំកម្មវិធី **"បំប៉នគ្រូកិច្ចសន្យា"** វគ្គ១ មានរយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី៩ ដល់ទី១១ ខែមិថុនា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ (Google Meet) ដល់សាលារៀនគោលដៅក្នុងខេត្តស្វាយរៀង និងព្រៃវែង។ កម្មវិធីបំប៉ននេះត្រូវបានបែងចែកជាបីក្រុមដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១០០នាក់ រួមមាន៖ នាយកសាលា និងគ្រូកិច្ចសន្យា ព្រមទាំងបុគ្គលិកគម្រោង។

កម្មវិធីនេះមានគោលបំណងបណ្តុះបណ្តាលគ្រូកិច្ចសន្យាដើម្បីឱ្យពួកគាត់ក្លាយទៅជាគ្រូបង្រៀននៅសាលាបឋមសិក្សារដ្ឋប្រកបដោយគុណភាពខ្ពស់។

លោកគ្រូអ្នកគ្រូបានទទួលបានចំណេះដឹងថ្មីៗបន្ថែមលើវិធីសាស្ត្របង្រៀន និងរៀនបច្ចុប្បន្ន រួមមាន៖ ១) ស្គាល់ពីតួនាទី និងភារកិច្ចរបស់គ្រូបង្រៀននៅក្នុងសាលាបឋមសិក្សារដ្ឋ។ ២) អាចអនុវត្តទ្រឹស្តីនៃការសិក្សា និងការរីកចម្រើនលូតលាស់របស់កុមារនៅក្នុងការបង្រៀនក្នុងថ្នាក់រៀន។ ៣)ពង្រឹងប្រសិទ្ធភាពនៃការបង្រៀន និងរៀនយកទៅអនុវត្តក្នុងថ្នាក់ឱ្យឆ្លើយតបនឹង (**សូមអានបន្តទំព័រ ១៦...**)

# សិក្ខាសាលាស្តីពី ការបំប៉នសមត្ថភាពគ្រូបង្រៀនកិច្ចសន្យា




*សកម្មភាពប្រជុំតាម Google meet ជាមួយសាលារៀនគោលដៅក្នុងខេត្តត្បូងឃ្មុំ*

គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំសិក្ខាសាលាស្តីពី ***"ការបំប៉នសមត្ថភាពគ្រូបង្រៀនកិច្ចសន្យា"*** តាមប្រព័ន្ធអនឡាញ (Google Meet) មានរយៈពេលចំនួន ៥ថ្ងៃ ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ដល់លោកគ្រូអ្នកគ្រូក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ២៨នាក់ បូករួមទាំងមន្ត្រីគម្រោង។

ទោះបីជាសាលារៀនត្រូវបានបិទទ្វារដោយសារការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ ក៏គម្រោងនៅតែបន្តសកម្មភាពរៀបចំសិក្ខាសាលាដល់សាលារៀនគោលដៅរបស់ខ្លួន។ សិក្ខាសាលានេះមានគោលបំណងពង្រឹងសមត្ថភាពគ្រូបង្រៀនកិច្ចសន្យាឱ្យក្លាយទៅជាគ្រូមានវិជ្ជាជីវៈក្នុងការបង្រៀននៅតាមសាលាបឋមសិក្សារដ្ឋប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

សិក្ខាកាមទាំងអស់ទទួលបានវិធីសាស្ត្របង្រៀន និងរៀនបន្ថែម រួមមាន៖ ១) ស្គាល់ពីតួនាទី និងភារកិច្ចជាគ្រូបង្រៀន ២) អាចអនុវត្តទ្រឹស្តីនៃការសិក្សា និងរៀនស្វែងយល់ពីការរីកចម្រើនលូតលាស់របស់កុមារក្នុងការបង្រៀននៅក្នុងថ្នាក់រៀន ៣) ពង្រឹងប្រសិទ្ធភាពបង្រៀន និងរៀនដើម្បីយកទៅអនុវត្តក្នុងថ្នាក់បានល្អឱ្យឆ្លើយតបនឹងប្រសិទ្ធភាព និងគុណភាពដល់សិស្ស ៤) យល់ដឹងពីខ្លឹមសារនៃកម្មវិធីសិក្សានៅសាលាបឋមសិក្សា ៥) អាចប្រើប្រាស់សៀវភៅសិស្ស និងសៀវភៅសិក្សាគោលគ្រូរបស់ក្រសួងក្នុងការធ្វើកិច្ចតែងការបង្រៀន និងការវាយតម្លៃការសិក្សារបស់សិស្សនៅក្នុងថ្នាក់រៀន និង ៦) យល់ដឹងពីទំនាក់ទំនងរវាងសាលារៀន និងសហគមន៍។

វគ្គសិក្ខាសាលានេះ លោកគ្រូអ្នកគ្រូនឹងទទួលបានវិធីសាស្ត្របង្រៀនល្អៗយកទៅអនុវត្តក្នុងថ្នាក់ស្តែងកាន់តែល្អប្រសើរ។

---

(...តពីទំព័រ ១៥) ប្រសិទ្ធភាព និងគុណភាពដល់សិស្សានុសិស្ស។ ៤)យល់ដឹងពីខ្លឹមសារនៃកម្មវិធីសិក្សានៅបឋមសិក្សា។ ៥) អាចប្រើប្រាស់សៀវភៅសិស្ស និងសៀវភៅគ្រូរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធ្វើកិច្ចតែងការបង្រៀន និងការវាយតម្លៃការសិក្សារបស់សិស្សនៅក្នុងថ្នាក់រៀន និង ៦) យល់ដឹងពីទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ ។

គម្រោង REACH IV ផ្តោតសំខាន់លើការប្រើវិធីសាស្ត្រអភិវឌ្ឍន៍ចម្រុះ ដើម្បីបង្កើតទិដ្ឋភាពសិក្សារៀនសូត្រផ្សេងៗជាច្រើនដល់កុមារ ដូចជា ការពង្រឹងអក្ខរកម្ម បង្កើតភាពងាយស្រួលចូលសាលារៀន បរិស្ថានអប់រំ ការចូលរួមរបស់សហគមន៍ និងការគាំពារកុមារ ដែលឈរលើគោលនយោបាយកម្មវិធីសាលារៀនកុមារមេត្រី។ ទោះបីជាជំងឺកូវីដ-១៩នៅតែបន្តកើនឡើងនូវការរីករាលដាលយ៉ាងណាក៏ដោយ ក៏គម្រោង REACH IV នៅតែបន្តដំណើរការសកម្មភាពផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបង្រៀនដល់គ្រូកិច្ចសន្យាសម្រាប់ជាទុនជំនួយដល់ការបង្រៀន និងរៀនពីចម្ងាយ។



អ្នកគ្រូ **ហ៊ាន គង្គា** បង្រៀនថ្នាក់ទី៤ នៅសាលាបឋមសិក្សាថ្មី បានចូលរួមកម្មវិធីបំប៉នរយៈពេលបីថ្ងៃ ធ្វើឱ្យអ្នកគ្រូយល់ដឹងបានច្រើនអំពីការបង្រៀនបែបច្នៃប្រឌិតញាណ វិធីសាស្ត្របង្រៀន និងរៀនថ្មីៗ ចេះគ្រប់គ្រងថ្នាក់ឱ្យបានល្អ ព្រមទាំងយល់ពីដំណើរការរៀបចំកម្មវិធីសិក្សាដោយខ្លួនឯង ជាពិសេសយល់ដឹងពីការលូតលាស់ និងការគិតរបស់សិស្ស។ កាលពីមុន ចំពោះការបង្រៀន អ្នកគ្រូចាំតែនាយកដាក់ឱ្យធ្វើ ដែលពេលខ្លះធ្វើទៅទាំងមិនយល់ពីគោលបំណងរបស់វាផង។ ប៉ុន្តែឥឡូវ កម្មវិធីនេះពិតជាមានអត្ថប្រយោជន៍ជួយឱ្យអ្នកគ្រូចេះរៀបចំសកម្មភាពបង្រៀនសិស្សប្លែកថ្មីៗប្រកបដោយភាពច្នៃប្រឌិត និងមិនចាំតែលោកនាយកដាក់ឱ្យធ្វើនោះទេ។ អ្នកគ្រូបានថ្លែងអំណរអរគុណដល់គម្រោង REACH IV ដែលបានរៀបចំកម្មវិធីបំប៉ននេះ។

# សិក្ខាសាលាតម្រង់ទិស ស្តីពី ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀន




*សកម្មភាពពង្រឹងជំនាញទន់ដល់នាយក នាយករងដល់សាលាគោលដៅក្នុងខេត្តសៀមរាប កំពង់ចាម និងរតនគិរី។*

នៅថ្ងៃទី២៩-៣០ ខែមិថុនា ឆ្នាំ២០២១ គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំសិក្ខាសាលាតម្រង់ទិសស្តីពី "**ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀន**" វគ្គទី៣ ដោយដំណើរការសកម្មភាពតាមរយៈប្រព័ន្ធអនឡាញ Zoom ក្រោមជំនួយហិរញ្ញប្បទានពីមូលនិធិ គីនធាន់ ស្ទីហ្វទុង ដែលមានសិក្ខាកាមចូលរួមសរុបមានចំនួន៣០នាក់ ជាមន្ត្រីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាស្រុកក្រឡាញ់ និងវ៉ារិន នាយក និងនាយករង មកពីខេត្តសៀមរាប កំពង់ចាម និងរតនគិរី។

សិក្ខាសាលាមានគោលបំណង៖ ១) រំឭកឡើងវិញនូវប្រធានបទទាំងបួនដែលបានសិក្សាហើយក្នុងភាពជាអ្នកដឹកនាំវគ្គទី១ ២) យល់កាន់តែស៊ីជម្រៅអំពីភាពជាអ្នកដឹកនាំ ដើម្បីកែលម្អការបង្រៀន និងរៀន និងស្គាល់វិធីអនុវត្ត ៣) យល់ច្បាស់លាស់អំពីសារៈសំខាន់នៃចក្ខុវិស័យ និងវិធីបង្កើតផែនការដើម្បីធ្វើឱ្យសម្រេចចក្ខុវិស័យ ៤) បង្កើនភាពច្នៃប្រឌិត និងមានឆន្ទៈក្នុងការប្រថុយ និង ៥) ឱ្យមានសមត្ថភាពកាន់តែខ្ពស់ក្នុងការធ្វើការងារ ការសង្កេតថ្នាក់រៀន ដើម្បីជួយទ្រទ្រង់ឱ្យកាន់តែមានប្រសិទ្ធភាព និងការផ្តល់ព័ត៌មានត្រឡប់ជូនគ្រូបង្រៀនពោរពេញទៅដោយការជួយគាំទ្រដែលនឹងធ្វើឱ្យការបង្រៀន និងរៀនកាន់តែបានល្អប្រសើរឡើង។

**លោក ស៊ាង ទីន** ជានាយកសាលាបឋមសិក្សាប្លូរ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរីបានមានប្រសាសន៍ថា **"សិក្ខាសាលានេះពិតជាមានអត្ថប្រយោជន៍ខ្លាំងណាស់សម្រាប់ខ្ញុំ ព្រោះវាធ្វើឱ្យខ្ញុំមានភាពជឿជាក់លើការដឹកនាំសាលារៀន និងអាចស្គាល់ច្បាស់ពីតួនាទី និងភារកិច្ចដែលខ្ញុំកំពុងអនុវត្តជាប្រចាំនៅក្នុងសាលារៀនរបស់ខ្ញុំឱ្យមានការរីកចម្រើនទៅថ្ងៃអនាគត ហើយជាទុនបន្ថែមទៀតសម្រាប់សិក្ខាកាមទាំងអស់គ្នាយកទៅប្រើប្រាស់ក្នុងមុខវិជ្ជាជីវៈរបស់ខ្លួន"**។

លោកស្រី **ឈាន់ សុភា** ជាមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាស្រុកក្រឡាញ់ ខេត្តសៀមរាប បានមានប្រសាសន៍ថា **"សិក្ខាសាលានេះពិតជាផ្តល់ចំណេះដឹងល្អៗដែលមានអត្ថប្រយោជន៍ដល់រូបនាងខ្ញុំ ក៏ដូចជាលោកនាយក និងនាយិកាសាលាផ្សេងៗទៀតដែរ បានចែករំលែកបទពិសោធន៍ និងបានរៀនសូត្រនូវមេរៀនថ្មីល្អៗ ជាពិសេសវាបានជួយពង្រឹងបន្ថែមលើសមត្ថភាពក្នុងពេលបច្ចុប្បន្នសម្រាប់ធ្វើការអភិវឌ្ឍការអប់រំកុមារ និងយុវជននៅកម្ពុជា"**។

លោកស្រី **សង សា** ជានាយិកានៃសាលាបឋមសិក្សាគោកស្រុក ស្រុកវ៉ារិន ខេត្តសៀមរាប បានមានប្រសាសន៍ថា **"នាងខ្ញុំទទួលបានចំណេះដឹងជាច្រើនទាក់ទងនឹងមេរៀនថ្មីៗ និងរំលឹកមេរៀនចាស់ៗស្តីពីការគ្រប់គ្រង និងការដឹកនាំសាលារៀន រួមទាំងទទួលបាននូវបទពិសោធន៍ល្អៗពីការគ្រប់គ្រងរបស់សាលារៀនដទៃៗទៀត ព្រមទាំងការបណ្តុះគំនិតច្នៃប្រឌិតថ្មីៗបន្ថែមសម្រាប់យកទៅអនុវត្តន៍នៅនៅសាលារៀនរបស់ខ្លួនជាក់ស្តែងនៅមូលដ្ឋាន"**។

គម្រោងកុមារកម្ពុជារីករាយផ្តោតលើការគាំទ្រដល់កុមារនៅតាមសហគមន៍ជនបទ និងតំបន់ដាច់ស្រយាលបំផុតក្នុងខេត្តចំនួន ៥ ដែលមានបញ្ហាប្រឈមជាច្រើន ដែលត្រូវធ្វើការពង្រឹងប្រសិទ្ធភាពបង្រៀន និងរៀនឱ្យមានលក្ខណៈល្អប្រសើរឡើងតាមរយៈការអភិវឌ្ឍ និងការអនុវត្តកម្មវិធីសាលារៀនកុមារមេត្រីក្នុង និងក្រៅថ្នាក់តាមរបៀបដែលពាក់ព័ន្ធនឹងតម្រូវការរបស់កុមារ ជាពិសេសកុមារងាយរងគ្រោះ។

# សិក្ខាសាលា ស្តីពី ការបង្កើតតេស្តដែលមានសុពលភាព




*កម្រងរូបភាពអនុស្សាវរីយ៍បន្ទាប់ពីបញ្ចប់សិក្ខាសាលា*




នៅថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) បានរៀបចំសិក្ខាសាលាស្តីពី **“ការបង្កើតតេស្តដែលមានសុពលភាព”** តាមរយៈប្រព័ន្ធអនឡាញ (Zoom) ក្រោមជំនួយហិរញ្ញប្បទានពីក្រសួងអប់រំ យុវជន និងកីឡា។ សិក្ខាកាមចូលរួមកម្មវិធីសរុបមានចំនួន ៣៦នាក់ ដែលជាគ្រូឧទ្ទេស និងគ្រូប្រឹក្សាអាជីពរបស់គម្រោងសាលារៀនជំនាន់ថ្មី។

សិក្ខាសាលានេះមានគោលបំណងឱ្យសិក្ខាកាមចេះ៖ ១) វាយតម្លៃសិស្សតាមរបៀបមួយដែលធានាបាននូវភាពសុខដុមរវាងគោលបំណង និងយុទ្ធសាស្ត្រនៃការវាយតម្លៃ។ ២) ដឹងពីគុណសម្បត្តិ និងគុណវិបត្តិនៃប្រភេទសំណួរបិទ (មិនលំអៀង) និងសំណួរបើក (លំអៀង)។ ៣) ចងក្រងវត្ថុបំណងមេរៀន/លទ្ធផលសិក្សាដើម្បីសម្រួលដល់ការបង្កើតសំណួរសម្រាប់ការវាយតម្លៃ។ ៤) វាយតម្លៃលើឧបករណ៍វាយតម្លៃ/វិញ្ញាសាប្រឡងដែលពួកគេបង្កើតដោយឈរលើពាក្យសុពលភាព។ ៥) ប្រើគោលការណ៍បង្កើតតេស្តឱ្យមានប្រសិទ្ធភាពតាមរយៈការប្រើតារាងផែនការតេស្ត។ ៦) ដឹងពីកម្រិតភាពលំបាក និងកម្រិតញែកនៃសំណួរដើម្បីកំណត់ពីភាពត្រឹមត្រូវនៃសំណួរ និង ៧) បង្កើត និងអាចគាំទ្រគ្រូលើការបង្កើតធនាគារសំណួរសម្រាប់រក្សាទុកធ្វើជាវិញ្ញាសាប្រឡងតាមកម្រិតថ្នាក់ និងមុខវិជ្ជាបន្ទាប់ពីបានវិភាគអំពីប្រសិទ្ធភាពនៃសំណួរនីមួយៗ។

សិក្ខាសាលានេះ បានជួយពង្រឹងសមត្ថភាពគរុនិស្សិតលើការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្កើតេស្តសម្រាប់តាមដានការសិក្សារបស់សិស្សានុសិស្ស ជាពិសេសជួយពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូដែលជាគរុនិស្សិតនៅពេលបញ្ចប់ការសិក្សាក្នុងរយៈពេលដ៏ខ្លីខាងមុខ និងត្រូវចុះបំពេញភារកិច្ចជាគ្រូប្រឹក្សាគរុកោសល្យនៅតាមសាលារៀនគោលដៅនីមួយៗ៕

# កម្មវិធីបំប៉នសមត្ថភាពគ្រូបង្រៀនអំពីការប្រើប្រាស់ធនធានសម្បូរបែបក្នុងថ្នាក់រៀន និងការរៀបចំបរិស្ថានថ្នាក់រៀន

នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRACIII) បានរៀបចំកម្មវិធីបំប៉នសមត្ថភាពគ្រូបង្រៀនលើការប្រើប្រាស់ធនធានសម្បូរបែបក្នុងថ្នាក់រៀន និងការរៀបចំបរិស្ថានថ្នាក់រៀន តាមរយៈប្រព័ន្ធអនឡាញ (Zoom)។ សិក្ខាកាមចូលរួមសរុបមានចំនួន ៦៣នាក់ រួមមាន៖ នាយកសាលា នាយករង និងគ្រូបង្រៀនមកពីសាលារៀនគោលដៅចំនួន៦ (ជុំទី៣) របស់គម្រោងក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។

កម្មវិធីបំប៉ននេះធ្វើឱ្យលោកគ្រូអ្នកគ្រូដឹងអំពីរបៀបកែលម្អបរិស្ថានរៀនសូត្រក្នុងថ្នាក់ ដែលនេះគឺជាសកម្មភាពជំនួយដល់ការបង្រៀន និងរៀនប្រកបដោយគុណភាពខ្ពស់ ព្រមទាំងមានបំណិនប្រើប្រាស់ធនធានក្នុងថ្នាក់រៀនយ៉ាងសម្បូរបែប។

អ្នកគ្រូ **ង៉ែន សុផារី** ជាគ្រូបង្រៀនថ្នាក់ទី៣ នៅសាលាបឋមសិក្សាថ្កូវ បាននិយាយថា **"កម្មវិធីបំប៉ននេះបានធ្វើឱ្យនាងខ្ញុំទទួលបានចំណេះដឹងថ្មីពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានសម្បូរបែបក្នុងថ្នាក់រៀន និងដឹងពីការរៀបចំថ្នាក់រៀនតាមបែបសតវត្សរ៍ទី២១។ វាពិតជាមានអត្ថប្រយោជន៍ច្រើនណាស់ ពីព្រោះបានធ្វើឱ្យនាងខ្ញុំយល់ដឹងពីការកែច្នៃ និងការបង្កើតសម្ភារៈឧបទេសមួយចំនួនដោយងាយៗនៅជុំវិញខ្លួនដើម្បីយកមកបង្រៀនសិស្ស។ ម្យ៉ាងទៀត កម្មវិធីនេះបានធ្វើឱ្យនាងខ្ញុំចេះពីរបៀបរៀបចំកៀនសិក្សាបានត្រឹមត្រូវតាមមុខវិជ្ជា។ នាងខ្ញុំពេញចិត្តនឹងកម្មវិធីបំប៉ននេះណាស់ ពីព្រោះបានផ្តល់ចំណេះដឹងជាច្រើនជួយពង្រឹងសមត្ថភាពក្នុងការបង្រៀន ហើយនាងខ្ញុំសំណូមពរឱ្យមានសិក្ខាសាលាបែបនេះជាច្រើនបន្តទៀតសម្រាប់បង្កើត និងពង្រឹងសមត្ថភាពបង្រៀនសិស្សឱ្យកាន់តែមានលក្ខណៈច្នៃប្រឌិតសម្បូរបែប"។**

លោកគ្រូ **ឈុំ វីរៈ** ជាគ្រូបង្រៀនថ្នាក់ទី៣ នៅសាលាបឋមសិក្សាជៀស បាននិយាយថា **"ខ្ញុំបាទទទួលបានចំណេះដឹងជាច្រើន ដូចជាការយល់ដឹងពីរបៀបតាំងរូបភាពឱ្យមានរបៀបតាមកៀននីមួយៗទៅតាមកម្រិតថ្នាក់ ចេះប្រើប្រាស់រូបភាពឱ្យសិស្សមានការចងចាំល្អ និងចេះរៀបចំថ្នាក់រៀនតាមបែបសម័យថ្មី"។**

អ្នកគ្រូ **ជាង វួចលី** ជាគ្រូបង្រៀនថ្នាក់ទី២ នៅសាលាសិក្សាស្បាបឹងវែង បានមានប្រសាសន៍ថា **"បន្ទាប់ពីចូលរួមវគ្គបំប៉នរួចនាងខ្ញុំបានយល់ដឹងច្រើនលើរបៀបប្រើប្រាស់ផ្ទាំងរូបភាព ការតុបតែងថ្នាក់រៀន ការប្រើប្រាស់ផែនទីសិក្សា និងការប្រើប្រាស់ធនធានសម្បូរបែប។ កម្មវិធីនេះបានផ្តល់ប្រយោជន៍ច្រើនសម្រាប់នាងខ្ញុំ ដោយសារវាងាយស្រួលក្នុងការប្រើប្រាស់ក្នុងថ្នាក់សម្រាប់ការសិក្សា"។**

កម្មវិធីបំប៉ននេះបានរួមចំណែកលើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀននៅក្នុងសតវត្សរ៍ទី២១ និងលើកទឹកចិត្តលោកគ្រូអ្នកគ្រូរៀបចំបែងចែកពេលវេលាសម្រាប់សិក្សាស្រាវជ្រាវរកព័ត៌មានថ្មីៗបន្ថែមទៀតស្តីពីវិធីសាស្ត្របង្រៀនថ្មីៗ និងការប្រើប្រាស់បច្ចេកទេសជំនួយក្នុងការបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល៕




*សាលារៀនគោលដៅចំនួនប្រាំមួយ(ជុំទី៣)នៃគម្រោង(ត្រាក់/TRAC III) ចូលរួមវគ្គសិក្ខាសាលាបំប៉នសមត្ថភាពគ្រូ*

# ការរៀនបណ្តុំតាមផ្ទះក្នុងបរិបទជំងឺកូវីដ-១៩

កាលពីថ្ងៃទី២៤ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ គម្រោងកុមារកម្ពុជារីករាយ(HCC) បានរៀបចំសិក្ខាសាលាស្តីពី **"ការរៀនបណ្តុំតាមផ្ទះក្នុងអំឡុងពេលកូវីដ-១៩"** ធ្វើឡើងតាមប្រព័ន្ធអនឡាញ (Google Meet និង Zoom) ក្នុងពេលតែមួយដល់សាលារៀនគោលដៅចំនួន ១១ ក្នុងខេត្តកំពង់ចាម រតនគិរី ក្រចេះ និងត្បូងឃ្មុំ។ សិក្ខាកាមចូលរួមសរុបមានចំនួន ១៦៤នាក់ គឺជាតំណាងមន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក-ខេត្ត នាយកសាលា គ្រូបង្រៀន បណ្ណារក្ស គ្រូកិច្ចសន្យា អ្នកស្ម័គ្រចិត្តបង្រៀនបណ្តុំ និងបុគ្គលិកគម្រោង។

សិក្ខាសាលានេះមានគោលបំណង៖ ១) បណ្តុះបណ្តាលលោកគ្រូអ្នកគ្រូអំពីនីតិវិធីនៃការរៀនបណ្តុំតាមខ្នងផ្ទះក្នុងភូមិ ដើម្បីយកទៅអនុវត្តបន្តនៅតាមសាលារៀនគោលដៅ។ ២) ពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូលើការប្រើប្រាស់កញ្ចប់ឯកសារបង្រៀនបន្ថែមថ្នាក់ទី ២ ដល់ទី៦ ក្នុងបរិបទជំងឺកូវីដ-១៩ ឱ្យចំគោលដៅប្រកបដោយគុណភាព និងមានប្រសិទ្ធភាពក្នុងការបង្រៀន និងរៀន។ ៣) ផ្តល់ឱកាសដល់គ្រូបង្រៀនដើម្បីចែករំលែកបទពិសោធន៍ និងអនុវត្តធ្វើកិច្ចតែងការបង្រៀនអំពីការរៀនបណ្តុំតាមផ្ទះ។

លោក **ឌុច ឡេក** ជានាយកសាលាបឋមសិក្សា ហាន់ជ័យ បានមានប្រសាសន៍ថា **"សិក្ខាសាលានេះមានអត្ថប្រយោជន៍សម្រាប់ខ្ញុំក៏ដូចជាថ្នាក់ដឹកនាំ លោកគ្រូអ្នកគ្រូដទៃទៀតពីការបង្រៀនសិស្សក្នុងបរិបទជំងឺកូវីដ-១៩ ដែលកំពុងឆ្លងរីករាលដាលនៅឡើយ ឱ្យយល់ដឹងពីការរៀនតាមបណ្តុំ ការចែកសន្លឹកកិច្ចការដល់សិស្ស និងការរៀនតាមប្រព័ន្ធអេឡិចត្រូនិក។ ចំណេះដឹងល្អៗទាំងនោះ រួមមាន៖ ការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែម លំនាំកិច្ចតែងការបង្រៀន និងវិធីសាស្ត្របង្រៀនសិស្សតាមបណ្តុំ។ ខ្ញុំសូមសំណូមពរឱ្យគម្រោងបន្តជួយគាំទ្រគ្រូបង្រៀនស្ម័គ្រចិត្តនៅសាលាបន្តទៀត"**។

លោក **ភ្លាន ជាតិ** ជាគ្រូបង្រៀនថ្នាក់ទី១ នៅសាលាបឋមសិក្សាឡាំ បានមានប្រសាសន៍ថា **"ខ្ញុំទទួលបានចំណេះដឹងជាច្រើនពាក់ព័ន្ធនឹងការប្រើប្រាស់កញ្ចប់ឯកសារទាំងប្រាំពីរវិធីសាស្ត្រសំខាន់ៗសម្រាប់ជួយសិស្សដែលមានត្រូវការក្នុងអំឡុងពេលកូវីដ-១៩ និងរបៀបធ្វើរបាយការណ៍ ការដាក់ពិន្ទុតេស្តសិស្ស។ សិក្ខាសាលានេះមានប្រយោជន៍ខ្លាំងណាស់ ព្រោះវាបានផ្តល់នូវចំណេះដឹងថ្មីៗល្អៗសម្រាប់គ្រូយកទៅជួយបង្រៀនសិស្សដែលមានតម្រូវការដើម្បីបំប៉នបន្ថែម ឬសិស្សដែលត្រូវរំលឹកឡើងវិញ។ ខ្ញុំសូមសំណូមពរដល់គម្រោងបន្តផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់វិធីសាស្ត្របង្រៀនគ្រប់មុខវិជ្ជា ការផលិតសម្ភារៈឧបទេស ការតុបតែងថ្នាក់ ការរៀបចំកិច្ចតែងការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀន"**។

សិក្ខាសាលានេះបានដំណើរការទៅយ៉ាងរលូនដោយមានការចូលរួមសហការយ៉ាងល្អជាមួយមន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក-ខេត្ត លោកគ្រូអ្នកគ្រូ និងអ្នកពាក់ព័ន្ធទាំងអស់របស់គម្រោង ហើយវាបានផ្តល់ចំណេះដឹងថ្មីៗដល់លោកគ្រូអ្នកគ្រូបានស្វែងយល់ពីនិតិវិធីក្នុងការអនុវត្តការបង្រៀន និងរៀនបណ្តុំតាមផ្ទះក្នុងអំឡុងពេលជំងឺកូវីដ-១៩ ដែលកំពុងនៅតែរីករាលដាល ក៏ដូចជាបានចែករំលែកបទពិសោធន៍ទៅវិញទៅមកអំពីវិធីសាស្ត្របង្រៀនចម្រុះ និងដកស្រង់មេរៀនល្អៗទាំងអស់ពីសិក្ខាសាលានេះយកទៅបង្រៀននៅតាមសាលារៀនក្នុងតំបន់រៀងៗខ្លួន៕




*សកម្មភាពលោកគ្រូអ្នកគ្រូចូលរួមសិក្ខាសាលាស្តីពីការរៀនបណ្តុំតាមផ្ទះ*

# ៤

# កម្មវិធីអប់រំបរិយាប័ន្ន

"ភាពចម្រុះ និងការអប់រំបរិយាប័ន្នផ្តល់តម្លៃដល់មនុស្សគ្រប់រូប
មិនថាយើងមានភាពគ្លាយ៉ាងណាក៏ដោយ"។

## Inclusive Education

*"Diversity and Inclusion are about giving value to every human being, no matter our differences."*



# យុវតីណារិនមានការងារធ្វើបន្ទាប់ពីបានអាហារូបករណ៍អង្គការ ខេប




កញ្ញា ថន ណារិន មានអាយុ ២២ឆ្នាំ ជាអតីតនិស្សិតអាហារូបករណ៍របស់គម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា (CTSP)។ ណារិនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រពាណិជ្ជកម្ម ឯកទេសគ្រប់គ្រង ចុងឆ្នាំ ២០២០ពីសាខាសាកលវិទ្យាល័យវេស្ទើនក្នុងក្រុងកំពង់ចាម។ ណារិនរស់នៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម។ នាងមានបងប្អូនចំនួន ៣នាក់ ដែលកំពុងរស់នៅជាមួយឪពុកម្តាយជាកសិករ។ គ្រួសាររបស់នាងមានការខ្វះខាត និងមិនមានលទ្ធភាពឱ្យនាងបានបន្តការសិក្សានៅសាកលវិទ្យាល័យនោះទេ បន្ទាប់ពីបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ។

ក្នុងឆ្នាំ២០១៦ ណារិនបានដាក់ពាក្យប្រឡងយកអាហារូបករណ៍ពីអង្គការ ខេប ដើម្បីបន្តការសិក្សារយៈពេលបួននៅឧត្តមសិក្សាក្រោមជំនួយហិរញ្ញប្បទានពីអង្គការមូលនិធិអាស៊ី (The Merali Foundation)។ ស្ថិតក្រោមការជួយគាំទ្រពីគម្រោង CTSP នាងមានការផ្លាស់ប្តូរ និងអភិវឌ្ឍខ្លួនបានយ៉ាងឆាប់រហ័សតាមរយៈចូលរួមវគ្គសិក្សាខ្លីៗ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ការងារស្ម័គ្រចិត្តក្នុងសង្គម ចេះដឹកនាំគម្រោង និងក្លឹបសិក្សា។ ណារិនបានក្លាយជាយុវតីគំរូដ៏ល្អនៅក្នុងសហគមន៍របស់នាង ជាពិសេសនាងមានសមត្ថភាពអាចស្វែងរកការងារធ្វើសម្រាប់ចិញ្ចឹមជីវិតខ្លួនឯង គ្រួសារ និងអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិឱ្យមានការរីកចម្រើន។ បច្ចុប្បន្ននេះ ណារិនកំពុងបម្រើការងារនៅក្នុងអង្គការក្រៅរដ្ឋាភិបាលមួយក្នុងក្រុងកំពង់ចាម ហើយនាងបានប្រើប្រាស់ចំណេះដឹង ជំនាញ និងសមត្ថភាពដែលមានក្នុងការបំពេញការងារបានយ៉ាងល្អប្រសើរ។

គម្រោង CTSP ពិតជាបានជួយដល់នាង និងក្មេងស្រីៗទៃទៀតដែលបាត់បង់ឱកាស និងងាយរងគ្រោះឱ្យទទួលបានការអប់រំខ្ពស់ និងជួយសង្គមទាំងមូលបាន៕

# ការអភិវឌ្ឍសមត្ថភាពរបស់ស្ត្រីក្នុងវិស័យឯកជន


*កញ្ញា ថៃ លក្ខិណា បម្រើការងារនៅធនាគារ ហ្វីលីព (Phillip) ស្រុកមេមុត ខេត្តត្បូងឃ្មុំ*

កញ្ញា ថៃ លក្ខិណា មានអាយុ ២២ឆ្នាំ ជាអតីតនិស្សិតអាហារូបករណ៍របស់គម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា (CTSP) រស់នៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម។ នាងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រពាណិជ្ជកម្ម ឯកទេសគណនេយ្យ ពីសាខាសាកលវិទ្យាល័យវេស្ទើនក្នុងក្រុងកំពង់ចាម ចុងឆ្នាំ២០២០។ នាងមានប្អូនស្រីម្នាក់រស់នៅជាមួយម្តាយដែលជាកសិករ។

មុនពេលទទួលបានអាហារូបករណ៍ពីគម្រោង CTSP ជីវភាពគ្រួសាររបស់នាងមានការលំបាកព្រោះមានតែម្តាយម្នាក់ដែលជាអ្នករកស៊ីចិញ្ចឹមកូនៗ និងគ្មានលទ្ធភាពគ្រប់គ្រាន់សម្រាប់ផ្តល់ឱ្យនាងបានបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សាឡើយ។ បន្ទាប់ពីទទួលបានការគាំទ្រពីគម្រោងរយៈពេលបួនឆ្នាំ នាងមានភាពក្លាហាន រីកចម្រើនភាសាអង់គ្លេស ចេះពីរបៀបប្រើប្រាស់កុំព្យូទ័រ ចេះរស់នៅចុះសម្រុងជាមួយមិត្តផ្សេងៗគ្នា ចេះបែងចែកពេលវេលា ចេះធ្វើការងារជាក្រុម ចេះកំណត់គោលដៅរបស់ខ្លួន ចេះសម្រេចចិត្តដោយខ្លួនឯង និងទទួលបានការបណ្តុះបណ្តាលជំនាញទន់ជាច្រើនទៀតតាមរយៈគម្រោង CTSP របស់អង្គការ ខេប។

នៅពេលបច្ចុប្បន្ននេះ នាងទទួលបានការងារមួយទទួលបន្ទុកផ្នែកគណនេយ្យនៅនៅក្នុងធនាគារមួយក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ នាងត្រូវបានគេលើកសរសើរចំពោះការខិតខំពុះពង្រឹងសមត្ថភាព និងបានធ្វើឱ្យការងារមានការរីកចម្រើនរហ័ស៕

# ការប្រជុំធ្វើបច្ចុប្បន្នភាពសកម្មភាពជាមួយនាយកសាលាគោលដៅ

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា (KYLA) ក្រោមជំនួយហិរញ្ញប្បទានពីមូលនិធិអូកទ្រី បានរៀបចំកិច្ចប្រជុំបើកដំណើរការបន្តប្រតិបត្តិគម្រោងដែលធ្វើឡើងតាមរយៈប្រព័ន្ធអនឡាញ (Google Meet) ដោយមានអ្នកចូលរួមជាបុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡាស្រុក នាយកសាលា គ្រូបង្រៀន បុគ្គលិកគម្រោង និងក្រុម Secretariat របស់គម្រោង KYLA។

កិច្ចប្រជុំនេះមានគោលបំណងសំខាន់ៗចំនួន៣គឺៈ១) ផ្តល់ព័ត៌មានសង្ខេបរបស់អង្គការ ខេប ២) ផ្តល់ព័ត៌មានសង្ខេបរបស់គម្រោង (KYLA) និង ៣) អនុវត្តផែនការរបស់គម្រោងសម្រាប់ឆ្នាំ២០២១។

កិច្ចប្រជុំនេះបានប្រព្រឹត្តិទៅយ៉ាងរលូន និងមានការគាំទ្រពីការិយាល័យអប់រំ យុវជន និងកីឡាស្រុក នាយកសាលា និងគ្រូបង្រៀនជំរុញឱ្យគម្រោងបង្កើនសកម្មភាពបន្តបន្ថែមសម្រាប់អភិវឌ្ឍន៍យុវជន ជាពិសេសមេរៀនភាពជាអ្នកដឹកនាំដែលត្រូវចាប់ផ្តើមបណ្តុះបណ្តាលចាប់ពីខែកក្កដា ឆ្នាំ២០២១ ខាងមុខនេះតទៅ។ វត្តមានពីសាលារៀនគោលដៅចំនួន ៧ បានយល់ព្រមចូលរួមដំណើរការសកម្មភាពគម្រោង ដោយជ្រើសរើសសិស្សស្ម័គ្រចិត្តចំនួនពី ១៥ ទៅ ១៧នាក់ ក្នុងមួយសាលាដើម្បីអនុវត្តសកម្មភាព។

លទ្ធផលនៃកិច្ចសហការ និងការគាំទ្រជាវិជ្ជមាននេះបានធ្វើឱ្យគម្រោង KYLA ទទួលបានជំនួយហិរញ្ញប្បទានបន្តពីម្ចាស់ជំនួយសម្រាប់ពង្រីកបន្តសកម្មភាពនៅឆ្នាំទី៣នេះ បន្ទាប់ពីបានធ្វើបច្ចុប្បន្នភាពសកម្មភាពមួយចំនួនដែលបានឆ្លើយតបនឹងស្ថានភាពជាក់ស្តែងនៅកម្ពុជា។

គោលគំនិតចម្បងរបស់គម្រោង KYLA គឺកៀរគរអតីតនិស្សិតអាហារូបករណ៍របស់អង្គការ ខេប ជាច្រើននាក់ចូលរួមរៀបចំសកម្មភាពបណ្តុះបណ្តាល និងវេទិកាតស៊ូមតិឱ្យយុវជននៅក្នុងសាលារៀន។ សកម្មភាពសំខាន់ៗដែលគម្រោងរៀបចំសម្រាប់យុវជនដូចជា ១) ការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសិទ្ធិអំណាចស្ត្រី និងជំនាញទន់ភាពជាអ្នកដឹកនាំ ការនិយាយជាសាធារណៈ ការងារក្រុម ការដោះស្រាយបញ្ហា និងការកាត់តវីដេអូ ២) ផ្តល់ការប្រឹក្សាយោបល់អាជីពតាមអេឡិចត្រូនិក និងរៀបចំផែនការអាជីពនៅតាមសាលារៀន ៣) រៀបចំកម្មវិធីជួបជុំអតីតសិស្សអាហារូបករណ៍របស់អង្គការ ខេប និង ៤) ធ្វើបច្ចុប្បន្នភាពប្រព័ន្ធបណ្តាញទំនាក់ទំនង និងផ្សព្វផ្សាយសង្គម ដើម្បីផ្តល់ព័ត៌មានដល់យុវជនពាក់ព័ន្ធនឹងការប្រឹក្សាជ្រើសរើសអាអាជីពទៅតាមបំណិនផ្ទាល់ខ្លួន និងអាចឆ្លើយតបទៅនឹងតម្រូវការសិក្សា និងការងារជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា៕



សកម្មភាពប្រជុំតាមអនឡាញដើម្បីធ្វើបច្ចុប្បន្នភាពសកម្មភាពគម្រោងជាមួយនាយកសាលាគោលដៅក្នុងខេត្តត្បូងឃ្មុំ និងកំពង់ចាម។

# ការប្រជុំស្តីពីការអនុវត្តកម្មវិធីអាហារូបករណ៍ និងរៀបចំផែនការបន្ត




*ការប្រជុំតាមអនឡាញជាមួយនាយក និងលោកគ្រូអ្នកគ្រូដើម្បីបង្ហាញពីសកម្មភាពអនុវត្តកម្មវិធីអាហារូបករណ៍ និងសមិទ្ធផលរបស់គម្រោង។*

កាលពីថ្ងៃទី១៤ និងទី១៦ ខែកក្កដា ឆ្នាំ២០២១ គម្រោងអប់រំកុមារី (GEI) បានរៀបចំ **“ការប្រជុំស្តីពីការអនុវត្តកម្មវិធីអាហារូបករណ៍ និងការរៀបចំផែនការបន្ត”** តាមរយៈប្រព័ន្ធអនឡាញ (Google Meet) ដែលមានអ្នកចូលរួមសរុបចំនួន ៣១នាក់ រួមមាន៖ ប្រធានការិយាល័យអប់រំស្រុក ព្រៃឈរ និងអូរាំងឪ ក្រុមប្រឹក្សាឃុំ នាយកសាលា គ្រូទទួលបន្ទុកអាហារូបករណ៍ គ្រូមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងភាសាអង់គ្លេស ព្រមទាំងបុគ្គលិកគម្រោង។ ការប្រជុំនេះមានគោលបំណង៖ ១) ធ្វើបទបង្ហាញសង្ខេបពីសកម្មភាពរបស់គម្រោង។ ២) បង្ហាញអំពីរបាយការណ៍សង្ខេបរបស់គ្រូទទួលបន្ទុកកម្មវិធីអាហារូបករណ៍ និងដំណើរការសិក្សារបស់សិស្សអាហារូបករណ៍។ ៣) ពិភាក្សាជាមួយគណៈគ្រប់គ្រងសាលារៀនអំពីការប្រើប្រាស់ Tablets(ថាប្លែត) ដែលអាចជួយសិស្សអាហារូបករណ៍ ដែលមិនមានទូរសព្ទវៃឆ្លាតប្រើប្រាស់។ ៤) រៀបចំកាលវិភាគបំប៉នបន្ថែមលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងភាសាអង់គ្លេសដល់សិស្សអាហារូបករណ៍ និង ៥) បង្ហាញពីអត្ថប្រយោជន៍បង្កើតក្លឹបអំណាន ដើម្បីជំរុញទម្លាប់អានសៀវភៅដល់សិស្សអាហារូបករណ៍។

លោក **ជុំ សមសុជាតិ** ជាអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកអូរាំងឪ បានមានប្រសាសន៍ថា **“ខ្ញុំពិតជារីករាយដែលបានចូលរួមសហការជាមួយអង្គការខេប ដើម្បីជួយគាំទ្រដល់កុមារីដែលខ្វះខាតនៅក្នុងសហគមន៍របស់ខ្ញុំ។ គម្រោង GEI នេះពិតជាបានជួយកុមារីដែលមានការលំបាកទាំងនោះឱ្យទទួលបាននូវឱកាសបន្តការសិក្សា។ ដូច្នេះ ក្នុងនាមខ្ញុំជាមន្ត្រីអប់រំម្នាក់ ក៏ដូចជាតំណាងឱ្យលោកនាយក លោកគ្រូអ្នកគ្រូ និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ផងដែរ ខ្ញុំសូមចូលរួមជួយជាចំណែកក្នុងការសម្របសម្រួលកម្មវិធីអាហារូបករណ៍នៃគម្រោង GEI នេះដំណើរការបានតទៅមុខទៀតដោយរលូន”**។




នៅពេលបច្ចុប្បន្ននេះ គម្រោង GEI បានកំពុងបានអនុវត្តដល់ឆ្នាំទី២ហើយ ក្នុងការជួយគាំទ្រដល់សិស្សដែលងាយរងគ្រោះ និងបាត់បង់ឱកាសសិក្សានៅសាលារៀន។ សិស្សសរុបនៅសាលារៀនគោលដៅចំនួន៥នេះមានចំនួន ១០០នាក់។ គម្រោងបានគាំទ្រជាកញ្ចប់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភប្រចាំខែ កង់ វគ្គបណ្តុះបណ្តាលខ្លីៗ និងការរៀនបំប៉នបន្ថែម ដើម្បីផ្តល់ឱកាសឱ្យសិស្សអាចបន្តការសិក្សារហូតដល់ចប់ថ្នាក់ទី៩ និងមានលទ្ធភាព និងសមត្ថភាពបន្តឆ្ពងទៅសិក្សានៅថ្នាក់វិទ្យាល័យ ឬទៅសិក្សាជំនាញវិជ្ជាជីវៈផ្សេងៗតាមលក្ខខណ្ឌ និងតម្រូវការជាក់ស្តែងរបស់សិស្សរៀងៗខ្លួន ៕

# យន្តការប្រើប្រាស់ថវិកាឃុំក្នុងការគាំទ្រសកម្មភាពសាលារៀន

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ គម្រោងកុមារកម្ពុជារីករាយ (HCC) និងសមាគមគ្រួសារយើង (**Kr.Y**) ដែលគាំទ្រហិរញ្ញប្បទានពីមូលនិធិ គីនឆាន ស្ទីហ្វទុង (Kinchan Stiftung) បានរៀបចំកិច្ចប្រជុំមួយដើម្បីពិគ្រោះយោបល់អំពី **"យន្តការនៃប្រើប្រាស់ថវិកាឃុំក្នុងការគាំទ្រសកម្មភាពសាលារៀន"** តាមរយៈប្រព័ន្ធអនឡាញ (Google Meet) ដោយមានសមាសភាពចូលរួមសរុបចំនួន ៤០នាក់ ដែលជាប្រធានមន្ទីរផែនការខេត្តត្បូងឃ្មុំ នាយកស្តីទីចាត់ការផែនការ និងវិនិយោគខេត្តត្បូងឃ្មុំ ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ ប្រធាន/អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក (មេមត់ តំបែរ និងពញាក្រែក) មេឃុំ ស្មៀនឃុំស្រុកអូរយ៉ាដាវ តំណាងម្ចាស់ជំនួយ សមាគមគ្រួសារយើង ព្រមទាំងបុគ្គលិកគម្រោង។

កិច្ចប្រជុំនេះមានគោលបំណង៖ ១) បង្ហាញអំពីសកម្មភាពគម្រោងដែលបានអនុវត្តរយៈពេលបីឆ្នាំ។ ២) ពិភាក្សាស្វែករកដំណោះស្រាយក្នុងការប្រើប្រាស់ថវិកាឃុំក្នុងការគាំទ្រសកម្មភាពសាលារៀនទៅលើអ្នកថែទាំ និងចុងភៅ និង ៣) កំណត់ទិសដៅសកម្មភាព និងការអនុវត្តរួមគ្នាបន្តសម្រាប់ចូលរួមរៀបចំផែនការវិនិយោគឃុំនៅក្នុងឆ្នាំ២០២២ខាងមុខនេះ។

លោក **ហ៊ិន ស៊ីមហួន** នាយករងប្រតិបត្តិអង្គការ ខេប បានមានប្រសាសន៍ថា "*គម្រោងកុមារកម្ពុជារីករាយ និងសមាគមគ្រួសារយើង បានគាំទ្រដល់សាលាបឋមសិក្សា និងមត្តេយ្យសិក្សា ដើម្បីធ្វើយ៉ាងណាឱ្យសាលារៀននៅតាមជនបទដាច់ស្រយាលមានការអភិវឌ្ឍដូចនឹងទីប្រជុំជនដែរ*"។ លោកបន្តលើកឡើងពាក់ព័ន្ធនឹងថវិកាឃុំនេះថា "*ឃុំត្រូវមានថវិកាសម្រាប់គាំទ្រសកម្មភាពសាលារៀន ជាពិសេសអ្នកថែទាំ និងចុងភៅនៅសាលារៀនគោលដៅ។ យើងត្រូវស្វែងរកដំណោះស្រាយ និងកំណត់ទិសដៅក្នុងការវិនិយោគដោយមានថវិកាឃុំចូលរួមក្នុងឆ្នាំ២០២២។ ម្ចាស់ជំនួយពិតជាចង់ឃើញសាលារៀនមានការអភិវឌ្ឍប្រកបដោយនិរន្តភាព និងអាចក្លាយជាសាលារៀនគំរូនៅតាមតំបន់ជនបទ ហើយវាអាចនឹងក្លាយជាសាលារៀនជំនាន់ថ្មីកូនកាត់ប្រសិន បើមានការចូលរួមសហការយ៉ាងល្អពីគ្រប់ភាគីអ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសឪពុកម្តាយ និងអាណាព្យាបាលសិស្សនៅក្នុងតំបន់មូលដ្ឋានផ្ទាល់តែម្តង*"។

លោក **ទិត្យ សិលា** តំណាងម្ចាស់ជំនួយ បានមានប្រសាសន៍ថា "*គម្រោងកុមារកម្ពុជារីករាយត្រូវបានម្ចាស់ជំនួយ គឺមូលនីធិ គីនឆាន ស្ទីហ្វទុង បានចុះកិច្ចព្រមព្រៀងជាមួយអង្គការកុមារកម្ពុជារីករាយសម្រាប់រយៈពេល ៩៩ឆ្នាំ ក្នុងការអនុវត្តសកម្មភាពគម្រោងដែលប្រតិបត្តិការដោយអង្គការ ខេប និងសមាគមគ្រួសារយើងដោយមិនកំណត់រយៈពេល។ ទោះបីជាមានការឆ្លងរីករាលដាលជំងឺកូវីដ-១៩ យ៉ាងណាក៏ដោយ ម្ចាស់ជំនួយនៅតែបន្តគាំទ្រសកម្មភាពគម្រោងមិនមានការប្រែប្រួលនោះទេ គឺមានតែបង្វែរសកម្មភាពមួយចំនួនដូចជា ការបណ្តុះបណ្តាលបច្ចេកទេសដោយផ្ទាល់មកជាការបណ្តុះបណ្តាលតាមអនឡាញវិញ ដើម្បីធ្វើយ៉ាងណាឱ្យសាលារៀនមានការអភិវឌ្ឍប្រកបដោយនិរន្តភាព*"។

កិច្ចប្រជុំនៅក្នុងថ្ងៃនេះបានផ្តល់នូវលទ្ធផលដែលមានផ្លែផ្កាល្អច្រើន ជាពិសេសបានជំរុញឱ្យអាជ្ញាធរមូលដ្ឋានចូលរួមសហការយ៉ាងពេញចិត្ត និងផុលផុសក្នុងការជួយគាំទ្រទៅដល់សកម្មភាពរបស់គម្រោង HCC និងបានរួមចំណែកស្វែងរកថវិការបស់ឃុំយកមកគាំទ្រសកម្មភាពអភិវឌ្ឍការអប់រំកុមារសាលារៀន និងបានជួយសម្របសម្រួលឱ្យគម្រោងនេះបានដំណើរការទៅដោយរលូន មានប្រសិទ្ធភាព ប្រសិទ្ធផល និងមានការចាប់អារម្មណ៍ច្រើនពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់នៅមូលដ្ឋាន៕




*លោក ស៊ុន គីរីវណ្ឌី នាយកស្តីទីចាត់ការផែនការ និងវិនិយោគខេត្តត្បូងឃ្មុំបានបញ្ចេញមតិទៅលើថវិកាឃុំ ដើម្បីជួយដោះស្រាយបញ្ហាដែលគម្រោងកំពុងជួបប្រទះក្នុងការអនុវត្ត។*

# ការពិគ្រោះយោបល់លើការរៀនតាមបណ្តុំ និងការជួយគាំទ្រសិស្ស




កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំការប្រជុំស្តីពី "**ការពិគ្រោះយោបល់លើការរៀនតាមបណ្តុំ និងការជួយគាំទ្រសិស្សក្នុងអំឡុងពេលកូវីដ១៩**" ជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តក្រចេះ ត្បូងឃ្មុំ និងរតនគិរី ការិយាល័យអប់រំ យុវជន និងកីឡាស្រុក នាយក និងនាយិកា។

ការប្រជុំនេះធ្វើឡើងដើម្បីបង្ហាញពី៖ ១) អំពីគម្រោងកុមារកម្ពុជារីករាយ។ ២) យន្តការគាំទ្រដល់សាលារៀនគោលដៅ និងផែនការសកម្មភាពរបស់គម្រោងសម្រាប់ឆ្នាំទី៤។ ៣) បញ្ហាប្រឈមនៃការរៀនតាមអេឡិចត្រូនិក។ ៤) សាកល្បងអនុវត្តនូវវិធីសាស្រ្តរៀនបណ្តុំក្រុមតូចតាមខ្នងផ្ទះជាមួយការគាំទ្រពីគ្រូស្ម័គ្រចិត្តបង្រៀនតាមភូមិ។ ៥) ពិគ្រោះយោបល់លើម៉ោងសិក្សាបន្ថែមសម្រាប់ការរៀនបណ្តុំតាមសាលារៀនគោលដៅរបស់គម្រោង និង ៦) រៀបចំផែនការអនុវត្តគម្រោងបន្ត។

គម្រោងកុមារកម្ពុជារីករាយមានគោលដៅផ្តោតសំខាន់ទៅលើ៖ ១) ពង្រឹងលទ្ធភាពទទួលបានសេវាការអប់រំឱ្យមានភាពប្រសើរឡើងនៅតំបន់គោលដៅ ជាពិសេសសម្រាប់កុមារី និងកុមារងាយរងគ្រោះ។ ២) ពង្រឹងប្រសិទ្ធភាពបង្រៀន និងរៀនឱ្យមានភាពប្រសើរឡើងតាមរយៈការអភិវឌ្ឍ និងការអនុវត្តកម្មវិធីសាលារៀនកុមារមេត្រីក្នុង និងក្រៅថ្នាក់រៀនតាមរបៀបដែលពាក់ព័ន្ធនឹងតម្រូវការរបស់កុមារ។ ៣) ពង្រឹងសកម្មភាពអំណានថ្នាក់ដំបូងរបស់កុមាររៀនថ្នាក់ទី១ ទី២ និងទី៣ ឱ្យបានប្រសើរឡើង។ ៤) កែលម្អសមត្ថភាពគ្រប់គ្រងអ្នកពាក់ព័ន្ធសាលារៀនដើម្បីបង្កើនលទ្ធភាពទទួលបានសេវាអប់រំ និងគុណភាពបង្រៀន និងរៀន និង ៥) កែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀន។

លោកស្រី **ម៉ន សុខណាន** ជាមន្រ្តីអប់រំ យុវជន និងកីឡា ខេត្តក្រចេះ បានមានប្រសាសន៍ថា "*បើកាលណាលោកគ្រូអ្នកគ្រូបានសហការជាមួយអាណាព្យាបាលនៅតាមសហគមន៍ ឬគណៈគ្រប់គ្រងសាលារៀនបានល្អ យើងឃើញថា ដំណើរការរៀនតាមបណ្តុំនេះ មានសកម្មភាពល្អ ដោយសារលោកគ្រូអ្នកគ្រូបានបែងចែកម៉ោងក្នុងការបង្រៀនបានច្បាស់លាស់ មានការទទួលខុសត្រូវចំពោះកន្លែងដែលពួកគាត់បង្រៀន។ នាងខ្ញុំគាំទ្រសកម្មភាពគម្រោងដែលបានធ្វើឡើងឆ្លើយតបទៅនឹងបរិបទជំងឺកូវីដ-១៩នេះ* "។

លោក **ហៅ សុផានិច្ច** នាយកសាលាបឋមសិក្សា១០៥ បានមានប្រសាសន៍ថា "*ការបង្រៀន និងរៀនតាមខ្នងផ្ទះ លោកគ្រូអ្នកគ្រូត្រូវបែងចែកសិស្សជាបណ្តុំ ឬក្រុមទៅតាមចំនួនសិស្សក្នុងថ្នាក់នីមួយៗ។ ចំណែកការចែកសន្លឹកកិច្ចការវិញ សិស្សត្រូវមកយកពីសាលារៀនទៅធ្វើនៅផ្ទះរួច ប្រគល់សន្លឹកកិច្ចការទាំងនោះទៅសាលារៀនតែម្តងគត់ក្នុងមួយសប្តាហ៍តាមកាលកំណត់។ បញ្ហាប្រឈមក្នុងការបង្រៀន និងរៀនតាមបណ្តុំ ដោយសារអាណាព្យាបាលសិស្សមិនអនុញ្ញាតិឱ្យកូនមករៀន ពិបាកក្នុងការប្រមូលផ្តុំសិស្ស ពិបាករកកន្លែងបង្រៀន សិស្សមករៀនមិនទៀងទាត់ គ្រូមិនមានពេលច្រើនសម្រាប់ចុះសម្របសម្រួលសិស្សក្នុងក្រុម និងមិនមានសុវត្ថិភាពពេលគ្រូធ្វើដំណើរចុះតាមភូមិ។ ដូច្នេះ ការបង្រៀន និងរៀនតាមបណ្តុំ ការចែកសន្លឹកកិច្ចការ ការធ្វើតេស្តដំណាក់កាល ការចែកវេណឱ្យសិស្សចូលអានសៀវភៅនៅបណ្ណាល័យ និងខ្ចីសៀវភៅយកទៅរៀន ឬអាននៅផ្ទះ យើងឃើញថា សិស្សដែលបានមករៀនតាមបណ្តុំមានប្រមាណជា ៥៦% ប៉ុណ្ណោះ*"។

ដំណើរការប្រជុំនេះបានប្រព្រឹត្តទៅយ៉ាងរលូន និងមានការចូលរួមចែករំលែកបទពិសោធន៍ពីខាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យ អប់រំ យុវជន និងកីឡាស្រុក លោគ្រូអ្នកគ្រូ និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើឱ្យការអនុវត្តសកម្មភាពគម្រោងទទួលបានលទ្ធផលល្អ ដែលអាចឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្សជាក់ស្តែង និងការអភិវឌ្ឍសាលារៀនឱ្យរីកចម្រើនឆ្ពោះទៅសម្រេចគោលដៅគម្រោង។ លទ្ធផលបន្ទាប់ពីការប្រជុំនេះ គម្រោងកុមារកម្ពុជារីករាយនឹងធ្វើការរៀបចំវគ្គសិក្ខាសាលាបណ្តុះបណ្តាលជូនដល់ នាយក/នាយិកា លោកគ្រូអ្នកគ្រូ និងអ្នកព័ន្ធទាំងអស់ស្តីពីការរៀនតាមបណ្តុំបន្ថែមទៀត ដើម្បីបង្កើនល្បឿនអភិវឌ្ឍការអប់រំនៅកម្ពុជា។

# កុមារមានជំងឺស្លេកស្លាំងអស់រយៈពេលជាងបីខែត្រូវបានព្យាបាល

កុមារី សុភឿ ជាសិស្សថ្នាក់ទី៥ សិក្សាសាលាបឋមសិក្សា ស៊ាន់បារ៉ាយ ស្ថិតនៅក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ នាងមានជំងឺស្លេកស្លាំងអស់រយៈពេលជាងបីខែមកហើយ ដែលបណ្តាលឱ្យនាងមានរាងកាយស្គមស្គាំងជាខ្លាំង ជាហេតុធ្វើឱ្យនាងនិយាយមិនបាន ដើរមិនរួច និងកម្រើកខ្លួនមិនបាន។ នាងមិនត្រូវបានបញ្ជូនទៅព្យាបាលនោះទេ ដោយសារតែគ្រួសាររបស់នាងគ្មានលទ្ធភាព។ មើលឃើញស្ថានភាពបែបនេះ គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (រីក/REACHIV) ក្រោមជំនួយហិរញ្ញប្បទានពីអង្គការវីវើល បានសហការជាមួយនាយកសាលា និងអាជ្ញាធរមូលដ្ឋានចុះជួបពិភាក្សាជាមួយអាណាព្យាបាលសិស្ស ដើម្បីស្វែងរកដំណោះស្រាយរួមមួយ រហូតដល់ពួកគាត់ព្រមបញ្ជូននាងទៅសម្រាកព្យាបាល។ គម្រោងបានរៀបចំដឹកយកអ្នកជំងឺទៅព្យាបាលនៅមន្ទីរពេទ្យបង្អែកក្នុងខេត្តកំពង់ឆ្នាំង ព្រមទាំងបានផ្តល់ថ្លៃអាហារដល់នាង និងអ្នកថែទាំបន្ថែមទៀត។ បច្ចុប្បន្ននេះ សុភឿកំពុងសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យបង្អែកខេត្ត និងមានសុខភាពល្អប្រសើរជាងមុនច្រើន ព្រោះនាងអាចញ៉ាំអាហារបាន និងបានចាប់ផ្តើមកម្រើកបានបណ្តើរៗ។

កុមារក្រីក្រ និងគ្មានលទ្ធភាពព្យាបាលជំងឺនៅតាមសាលារៀនគោលដៅគឺជាក្រុមគោលដៅដែលគម្រោងត្រូវជួយធ្វើយ៉ាងណាបង្កលក្ខណៈឱ្យពួកគាត់ទទួលបានឱកាសសិក្សាគ្រប់ៗគ្នា។ នេះមានន័យថា គម្រោងផ្តោតការយកចិត្តទុកដាក់ទៅលើកុមារងាយរងគ្រោះដែលគ្មានលទ្ធភាពទទួលបានការសិក្សា មិនថាកុមារនោះស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ ពួកគាត់ត្រូវតែទទួលបានការអប់រំ និងធានាឱ្យបានថា មិនមានកុមារណាម្នាក់បោះបង់ការសិក្សាដោយសារតែស្ថានភាពលំបាកនោះឡើយ។

អាណាព្យាបាលរបស់កុមារី សុភឿ មានចិត្តរំភើបរីករាយរកអ្វីប្រៀបផ្ទឹមពុំបាន ព្រោះបានឃើញកូនរបស់គាត់មានភាពល្អប្រសើរច្រើនឡើងវិញ និងបានថ្លែងអំណរអរគុណដល់អង្គការ ខេប តាមរយៈគម្រោង REACH IV សូមឱ្យទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕



ការសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ឆ្នាំង។

# ក្លឹបសិក្សាសិស្សអាហារូបករណ៍ទទួលបានវគ្គបំប៉នតាមអនឡាញ

ក្រោយពីគម្រោងអប់រំកុមារី (GEI) បានបញ្ចប់កិច្ចពិភាក្សាជាមួយថ្នាក់គ្រប់គ្រងសាលារៀន គ្រូទទួលបន្ទុកអាហារូបករណ៍ លោកគ្រូអ្នកគ្រូតាមមុខវិជ្ជានីមួយៗលើការបង្រៀនបំប៉នក្លឹបសិក្សាដល់សិស្សនៅក្នុងសាលារៀនគោលដៅ។ គ្រូដែលទទួលបន្ទុកបង្រៀនក្លឹបសិក្សាតាមប្រព័ន្ធអនឡាញ (Google Meet, Telegram និង Messenger) បានរៀបចំការបង្រៀនដើម្បីបំប៉នដល់សិស្សអាហារូបករណ៍ក្នុងរយៈពេលបីខែ ដោយចាប់ផ្តើមពីខែកក្កដាដល់ខែកញ្ញា ឆ្នាំ ២០២១។ គម្រោង GEI បានផ្តល់ហិរញ្ញប្បទានគាំទ្រដល់សកម្ម ភាពរបស់ក្លឹបសិក្សា។ ក្លឹបនេះត្រូវបានផ្តោតលើមុខវិជ្ជាចំនួន ៣ រួមមាន៖ ភាសាខ្មែរ គណិតវិទ្យា និងភាសាអង់គ្លេស ដែលមានរយៈពេល ៦ម៉ោងក្នុងមួយមុខវិជ្ជាក្នុងមួយសប្តាហ៍។

សិស្សានុសិស្សប្រមាណជា ៦០% បានចូលរៀន ខណៈសិស្សផ្សេងទៀតមានបញ្ហាប្រឈមខ្លះៗ ដូចជា មិនមានទូរសព្ទឆ្លាតវៃ ការចំណាយថ្លៃកាតទូរសព្ទ សេវាអ៊ីនធើណែត ចំណេះដឹងប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិត និងមួយចំនួនតូចធ្វើការចំណាកស្រុក។ ចំពោះបញ្ហាទាំងអស់នេះ គម្រោងបានសហការជាមួយគ្រូទទួលបន្ទុកអាហារូបករណ៍ក្នុងការសម្របសម្រួលដល់សិស្សដើម្បីធ្វើយ៉ាងណាជួយឱ្យពួកគាត់ចូលរួមរៀនពីចម្ងាយបាន។ គម្រោងបានផ្តល់ Tablet ដល់សាលារៀនគោលដៅសម្រាប់សិស្សដែលមិនមានទូរស័ព្ទឆ្លាតវៃ។


សកម្មភាពសិស្សរៀនពីចម្ងាយនៅផ្ទះ

គម្រោងអប់រំកុមារីនៅតែបន្តកិច្ចខិតខំប្រឹងប្រែងជួយក្មេងស្រីឱ្យទទួលបានការសិក្សាបំប៉នបន្ថែម និងជំរុញស្វ័យសិក្សានៅផ្ទះតាមរយៈកម្មវិធីសិក្សាផ្សេងៗ។ សកម្មភាពទាំងនេះបានឆ្លើយតបនឹងការអប់រំនៅតាមសាលារៀនគោលដៅក្នុងបរិបទជំងឺកូវីដ-១៩ ដែលសាលារៀនមិនទាន់អាចដំណើរការបាននៅឡើយ៕







សកម្មភាពសិស្សចូលរួមសិក្សាក្លឹបបំប៉នភាសាខ្មែរតាមប្រព័ន្ធអនឡាញ


ឪ
កម្មវិធីអំណានថ្នាក់ដំបូង
“នៅពេលអ្នករៀនអាន អ្នកនឹងមានសេរីភាពរហូត”។
Early Grade Reading
"Once you learn to read, you will be forever free."

# សកម្មភាពសិក្សាតាមបណ្តុំដោយប្រើប្រាស់កម្មវិធីសិក្សាអង្គការ ខេប






កម្មវិធីរបស់អង្គការខេប សម្រាប់ជំនួយដល់កុមារក្នុងសរសេរអក្សរខ្មែរ និងពង្រឹងអំណានមាន កម្មវិធីអានខ្មែរ កម្មវិធីសៀវភៅឆ្លាត និងកម្មវិធីសរសេរខ្មែរ។

ក្នុងអំឡុងពេលគ្រឹះស្ថានសិក្សាកំពុងតែបិទទ្វារ លោកគ្រូអ្នកគ្រូក៏បានសម្របខ្លួនតាមស្ថានការណ៍ដោយបង្វែរសកម្មភាពបង្រៀនផ្ទាល់ទៅតាមប្រព័ន្ធឌីជីថលវិញ ដើម្បីជំរុញសិស្សឱ្យយកចិត្តទុកដាក់លើការសិក្សា ទោះបីជាមិនបានរៀនផ្ទាល់ជាមួយគ្នាក៏ដោយ។ តាមរយៈសេចក្តីប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការបង្រៀន និងរៀនពីចម្ងាយ ដើម្បីធានាបាននូវការបន្តការសិក្សារបស់សិស្សតាមប្រព័ន្ធអេឡិចត្រូនិក ដូចជាកម្មវិធី Google Meet, Youtube, Zoom, MoEYS E-learning និងផ្សេងៗទៀត ឬរៀនតាមបណ្តុះតូចៗ អាស្រ័យលើច្នៃប្រឌិតរបស់គ្រូ។

គម្រោងអង្គការ ខេប មួយចំនួនដូចជាគម្រោងកុមារកម្ពុជារីករាយ (HCC) គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (REACH IV) គម្រោងវិធីសាស្រ្តសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRAC III) កម្មវិធីសាលារៀនជំនាន់ថ្មីបឋមសិក្សា និងគម្រោងដទៃទៀតដែលកំពុងអនុវត្តក្នុងសាលារៀនគោលដៅរបស់ខ្លួនបានជំរុញលើកទឹកចិត្តលោកគ្រូអ្នកគ្រូចុះបង្រៀនតាមភូមិ ឬសហគមន៍ដែលជាតំបន់មានសុវត្ថិភាពជាបណ្តុំតូចៗ ចែកសន្លឹកកិច្ចការដើម្បីធ្វើយ៉ាងណាឱ្យសិស្សានុសិស្សនៅតែអាចបន្តការសិក្សានៅតាមផ្ទះបាន។ ម្យ៉ាងទៀត កុមារទាំងអស់អាចស្វ័យសិក្សាបន្ថែមដោយខ្លួនឯងបានគ្រប់ពេលវេលា និងនៅគ្រប់ទីកន្លែងដោយគ្រាន់តែអាណាព្យាបាលណែនាំកូនឱ្យចូលទៅក្នុង PlayStore ឬ AppStore ធ្វើការទាញយកកម្មវិធីសិក្សា (downloading apps) ទាំងនោះរបស់អង្គការ ខេប ដូចជា កម្មវិធីអានខ្មែរ សរសេរខ្មែរ និងសៀវភៅឆ្លាតមកប្រើប្រាស់ដោយងាយស្រួល។ កម្មវិធីទាំងអស់នេះជាកម្មវិធីល្បែងសិក្សា អប់រំភាសាខ្មែរសម្រាប់កុមាររៀនសរសេរអក្សរខ្មែរ និងពង្រឹងពិន្ទុអំណានដើម្បីឱ្យកុមារទទួលបានចំណេះដឹងក៏ដូចជាចូលរួមរៀនយ៉ាងសកម្មគ្រប់កន្លែង។ ចំណែកឯឪពុកម្តាយ និងអាណាព្យាបាលវិញ ពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការបង្រៀនពួកគាត់ដោយមិនពឹងផ្អែកតែទៅលើគ្រូទាំងស្រុងនោះទេ៕



សកម្មភាពលោកគ្រូចែកសន្លឹកកិច្ចការនៅសាលាបឋមសិក្សាវត្តស្លារបស់គម្រោង REACH IV។



សកម្មភាពបង្រៀន និងរៀនតាមបណ្តុំគម្រោងសាលារៀនជំនាន់ថ្មី ផ្នែកបឋមសិក្សា។



សកម្មភាពបង្រៀន និងរៀនតាមបណ្តុំនៅសាលារៀនគម្រោងHCC។


៦
កម្មវិធីមត្តេយ្យសិក្សា
“បង្កើនគំនិតមួយសម្រាប់កុមារមួយនាក់ក្នុងពេលតែមួយ”។
Preschool Programming
"Enriching the mind one child at a time."

# សិក្ខាសាលា ស្តីពី ការកែឯកសារផែនការប្រចាំខែសម្រាប់មត្តេយ្យសិក្សា




*សកម្មភាពប្រជុំតាម Google Meet ក្នុងការកែសម្រួលឯកសារថ្នាក់មត្តេយ្យ*

គម្រោងវិធីសាស្រ្តសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRACIII) បានរៀបចំសិក្ខាសាលាស្តីពី **"ការកែឯកសារផែនការប្រចាំខែសម្រាប់ថ្នាក់មត្តេយ្យ"** រយៈពេលពីរថ្ងៃ នៅថ្ងៃទី២៧ និងទី២៨ ខែឧសភា ឆ្នាំ២០២១ តាមរយៈអនឡាញ (Google Meet) ដោយមានសិក្ខាកាមចូលរួមមានចំនួន ១០នាក់ ដែលជាគ្រូឧទ្ទេស និងគ្រូបង្រៀនមកពីសាលារៀមគោលដៅចំនួន ៦ ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។ សិក្ខាសាលានេះមានគោលបំណងដើម្បីពិនិត្យ និងកែឯកសារលើមុខវិជ្ជាបុរេគណិតវិទ្យា វិទ្យាសាស្រ្ត ចិត្តចលនា សិក្សាសង្គម និងភាសាខ្មែរសម្រាប់ទុកជាជំនួយក្នុងការបង្រៀនសិស្សឱ្យកាន់តែល្អប្រសើរឡើង។

អ្នកគ្រូ **គង់ សូរីយ៉ា** ជាគ្រូមត្តេយ្យបឋមសិក្សា រកាពប្រាំ បាននិយាយថា **"សិក្ខាសាលានេះពិតជាល្អសម្រាប់ខ្ញុំ ដែលជាគ្រូទើបតែចេញបង្រៀនថ្មី។ ដូច្នេះ ខ្ញុំអាចរៀបចំមេរៀន និងបង្រៀនឱ្យបានត្រឹមត្រូវនឹងដឹងចំណុចណាត្រូវបង្រៀនមុន និងក្រោយគេ ជាពិសេសខ្ញុំបានរៀនសូត្រនូវបទពិសោធន៍ល្អៗជាច្រើនពីការចែករំលែករបស់គ្រូផ្សេងៗទៀត"**។

សិក្ខាសាលានេះបានផ្តល់នូវចំណេះដឹង និងវិធីសាស្រ្តរៀបចំមេរៀនល្អៗដល់អ្នកគ្រូសម្រាប់បង្រៀនប្រចាំខែឱ្យបានត្រឹមត្រូវ និងច្បាស់លាស់៕

# កម្មវិធីសិក្សាលម្អិត ការងារបច្ចេកទេស

នៅថ្ងៃទី២៣-២៥ ខែមិថុនា ឆ្នាំ២០២១ គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (REACH IV) បានរៀបចំសិក្ខាសាលាស្តីពី **"ការបំប៉នគ្រូមត្តេយ្យកិច្ចសន្យាស្តីពីកម្មវិធីសិក្សាលម្អិត ការងារបច្ចេកទេស"**។ កម្មវិធីនេះធ្វើឡើងតាមប្រព័ន្ធអនឡាញ (Google Meet) ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១១នាក់ ជាគ្រូមត្តេយ្យកិច្ចសន្យាមកពីសាលារៀនគោលដៅចំនួន ៨ ក្នុងខេត្តព្រៃវែង និងស្វាយរៀង។




*គ្រូមត្តេយ្យកិច្ចសន្យាមកពីសាលារៀនគោលដៅចំនួន ៨ ក្នុងខេត្តព្រៃវែង និងស្វាយរៀងចូលរួមសិក្ខាសាលាតមប្រព័ន្ធអនឡាញ។*

សិក្ខាសាលានេះមានគោលបំណង៖ ១) ពង្រឹងសមត្ថភាពគ្រូមត្តេយ្យសិក្សាកិច្ចសន្យាពីការងារបច្ចេកទេស។ ២) ការអនុវត្តកម្មវិធីសិក្សាលម្អិត។ ៣) ការរៀបចំ និងគ្រប់គ្រងថ្នាក់រៀន។ ៤) រំលឹកតេស្តកុមារអាយុ ៥ ឆ្នាំ និង ៥) រៀបចំផែនការអនុវត្តបន្ត។

លោកស្រី **ទី គន្ធា** ជាមន្រ្តីជំនាញផ្នែកអប់រំកុមារតូចនៅការិយាល័យនៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង បានមានប្រសាសន៍ថា **"សិក្ខាសាលារយៈពេលបីថ្ងៃនេះមានអត្ថប្រយោជន៍ច្រើនដល់អ្នកគ្រូកិច្ចសន្យា ព្រោះវាបានធ្វើ** (អានបន្តទំព័រ ៣៣...)

# វគ្គបំប៉នបច្ចេកទេសរៀបចំផែនការបង្រៀនប្រចាំថ្ងៃ លំនាំបង្រៀន និងរៀបចំកិច្ចតែងការបង្រៀនសម្រាប់ថ្នាក់មត្តេយ្យសិក្សា

គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ ( TRACIII) បានរៀបចំ **“វគ្គបំប៉នបច្ចេកទេសរៀបចំផែនការបង្រៀនប្រចាំថ្ងៃ លំនាំបង្រៀន និងរៀបចំកិច្ចតែងការបង្រៀនសម្រាប់ថ្នាក់មត្តេយ្យសិក្សា”** នៅថ្ងៃទី ៧-៨ ខែកក្កដា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធអនឡាញ ( Zoom )។ សិក្ខាកាមចូលរួមសរុបមានចំនួន ១៤នាក់ ដែលជាគ្រូឧទ្ទេសគ្រូមត្តេយ្យ និងបុគ្គលិកគម្រោងមកពីការិយាល័យអប់រំកុមារតូចខេត្តកំពង់ចាម និងសាលាគោលដៅចំនួន ៦ ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។




សកម្មភាពគ្រូមត្តេយ្យកំពុងពិភាក្សាលើផែនការបង្រៀន

គោលបំណងក្នុងវគ្គបំប៉ននេះផ្តល់ឱ្យសិក្ខាកាមនូវ៖ ១) ការយល់ដឹងច្បាស់អំពីខ្លឹមសារទម្រង់ផែនការបង្រៀនប្រចាំថ្ងៃ ២) យល់ពីលំនាំបង្រៀនតាមសកម្មភាពគោលនីមួយៗតាមមុខវិជ្ជា និង ៣) មានសមត្ថភាពក្នុងការរៀបចំកិច្ចតែងការបង្រៀនដោយផ្អែកលើផែនការបង្រៀនប្រចាំថ្ងៃ។

លោកស្រី **សុក គឹមហ៊ាង** ជាអ្នកសម្របសម្រួលផ្នែកមត្តេយ្យសិក្សានៃគម្រោង TRAC III នៅអង្គការ ខេប បានមានប្រសាសន៍ **“វគ្គបំប៉ននេះធ្វើឱ្យអ្នកគ្រូមត្តេយ្យសិក្សាទាំងអស់បានយល់ដឹងច្បាស់អំពីលំនាំបង្រៀន និងកិច្ចតែងការបង្រៀនលើមុខវិជ្ជាចំនួន ៥ រួមមាន៖ គណិតវិទ្យា ភាសាខ្មែរ សិក្សាសង្គម ចិត្តចលភាព និងវិទ្យាសាស្ត្រ ដែលអាចយកទៅអនុវត្តក្នុងថ្នាក់រៀនជាក់ស្តែង** ( **អានបន្តទំព័រ ៣៤...** )

---




*សកម្មភាពបំប៉នគ្រូមត្តេយ្យសិក្សាកិច្ចសន្យាស្តីពីកម្មវិធីសិក្សាលម្អិតតាមរយៈអនឡាញ។*

( **...តពីទំព័រ ៣២** ) **ឱ្យពួកគាត់ចេះប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ( Telegram, Messager, Zoom, Google Meet, Facebook) ចែករំលែកបទពិសោធន៍ វិធីសាស្ត្រក្នុងការបង្រៀន និងរៀនថ្មីៗ ព្រមទាំងមានពេលសម្រាប់ផ្តល់មតិយោបល់ត្រឡប់ចំពោះការបង្រៀនឱ្យគ្នាទៅវិញទៅមក។ នាងខ្ញុំពិតជាសប្បាយរីករាយនូវអ្វីដែលអង្គការ ខេប បានយកចិត្តទុកដាក់ និងមានការសហការយ៉ាងល្អជាមួយក្រសួងអប់រំ យុវជន និងកីឡា ដោយបានផ្តល់ឱកាសដល់នាងខ្ញុំ និងអ្នកគ្រូដទៃទៀតក្នុងការប្រើប្រាស់បច្ចេកវិទ្យា ជាពិសេសបានពង្រឹងសមត្ថភាពដល់អ្នកគ្រូៗក្នុងការបង្រៀនកាន់តែល្អប្រសើរឡើងក្នុងបរិបទជំងឺកូវីដ-១៩ ដែលកំពុងរីករាលដាលនេះ”**។

អ្នកគ្រូ **ឡុង ស៊ីនួន** ជាគ្រូបង្រៀននៅសាលាបឋមសិក្សាស្ទៀ ខេត្តព្រៃវែងបាននិយាយថា **“បន្ទាប់ពីបានចូលរួមក្នុងសិក្ខាសាលានេះមកខ្ញុំទទួលបានចំណេះដឹងថ្មីៗបន្ថែមជាច្រើន ដូចជា បច្ចេកទេសក្នុងការបង្រៀន បទពិសោធន៍របៀបបង្រៀនពីចម្ងាយ ល្អៗ របៀបតុបតែងថ្នាក់រៀន ហើយអ្វីដែលខ្ញុំប្រែប្រួលច្រើននោះគឺខ្ញុំដឹងវិធីសាស្ត្រ និងមានលក្ខណៈស្វាហាប់ក្នុងការបង្រៀនល្អជាងមុន”**។

សិក្ខាសាលានេះពិតជាបានអភិវឌ្ឍន៍សមត្ថភាពក្នុងការអនុវត្តកម្មវិធីសិក្សាលម្អិតរំលឹកតេស្តកុមារអាយុ ៥ឆ្នាំ ក្នុងការបង្រៀនប្រកបដោយបរិយាបន្នមានគុណភាព និងប្រសិទ្ធភាព៕

# ការពង្រឹងគ្រូមត្តេយ្យអំពីបច្ចេកទេសសម្រាប់បង្រៀន និងរៀនពីចម្ងាយ



សកម្មភាពគ្រូមត្តេយ្យសហគមន៍កំពុងពិភាក្សាលើផែនការបង្រៀនបែបបង្រួញ

នៅថ្ងៃទី១៩-២០ ខែកក្កដា ឆ្នាំ២០២១ គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំកម្មវិធីសិក្ខាសាលាស្តីពី "**បច្ចេកទេសសម្រាប់បង្រៀន និងរៀនពីចម្ងាយ**" តាមរយៈប្រព័ន្ធអនឡាញ (Google Meet) ដល់គ្រូមត្តេយ្យសិក្សាសហគមន៍ក្នុងខេត្តកំពង់ចាម ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ១១នាក់ ដែលជាគ្រូឧទ្ទេស គ្រូមត្តេយ្យ និងបុគ្គលិកគម្រោង HCC។

សិក្ខាសាលានេះមានគោលបំណងឱ្យសិក្ខាកាមទាំងមូលចេះ៖ ១) រៀបចំ និងអនុវត្តកម្មវិធីសិក្សាព្រមទាំងកាលវិភាគបែបបង្រួញ ២) រៀបចំ និងប្រើប្រាស់ផែនការបង្រៀនប្រចាំថ្ងៃបែបបង្រួញ និង ៣) បង្កើត និងប្រើប្រាស់កិច្ចការផ្ទះតាមកម្មវិធីសិក្សាបែបបង្រួញ ព្រមទាំងបង្ហាញពីវិធីសាស្ត្រផ្តល់សន្លឹកកិច្ចការដល់សិស្សានុសិស្ស។

អ្នកស្រី **សៅ ឈុនអឿង** ជាគ្រូមត្តេយ្យសហគមន៍បង្រៀនថ្នាក់មត្តេយ្យកម្រិតខ្ពស់នៅស្រុកកំពង់សៀមក្នុងខេត្តកំពង់ចាមបានមានប្រសាសន៍ថា **"បន្ទាប់ពីខ្ញុំចូលរួមសិក្ខាសាលានេះ ខ្ញុំបានកើនចំណេះដឹងមួយចំនួនធំដូចជា ការចេះរៀបចំកម្មវិធីសិក្សា និងកាលវិភាគបែបបង្រួញ ការចេះប្រើប្រាស់ផែនការ** បង្រៀនប្រចាំថ្ងៃ ការចេះបង្កើត និងប្រើប្រាស់កិច្ចការផ្ទះតាមកម្មវិធីបែបបង្រួញគ្រប់មុខវិជ្ជា ហើយសិក្ខាសាលានេះពិតជាមានអត្ថប្រយោជន៍សម្រាប់ខ្ញុំណាស់ ពីព្រោះវាជាជំនួយដល់ការបង្រៀនសិស្សនៅក្នុងអំឡុងពេលការឆ្លងរីករាលដាលជំងឺកូវីដ-១៩។ នាងខ្ញុំពេញចិត្តសិក្ខាសាលានេះខ្លាំង ដោយសារខ្ញុំទទួលបានមេរៀនល្អៗជួយឱ្យនាងខ្ញុំមានគំនិតថ្មីៗប្លែកៗ និងកាន់តែយល់ច្បាស់ពីកម្មវិធីនីមួយៗក្រោយពីការរៀនចប់។ ជាចុងក្រោយ នាងខ្ញុំសូមថ្លែងអំណរគុណដល់អង្គការ ខេប ដែលបានយកចិត្តទុកដាក់ដល់នាងខ្ញុំ និងអ្នកគ្រូផ្សេងៗទៀតក្នុងការស្វែងរកនូវវិធីសាស្ត្រថ្មីៗបន្ថែមមកបណ្តុះបណ្តាលឱ្យពួកខ្ញុំមានសមត្ថភាពកាន់តែរឹងមាំ និងមានការជឿជាក់លើ ការប្រើប្រាស់វិធីបង្រៀនថ្មីៗទាំងនោះ"។

គម្រោង HCC បានជួយអន្តរាគមន៍ និងគាំទ្រផ្នែកបច្ចេកទេសដល់សាលារៀនគោលដៅក្នុងការបង្រៀន និងរៀន ព្រមទាំងបន្តជួយផ្តល់វគ្គសិក្ខាសាលាសម្រាប់ពង្រឹងសមត្ថភាពគ្រូៗអំឡុងពេលដ៏លំបាកដែលមិនអាចជួបមុខគ្នាផ្ទាល់បាន៕

(តពីទំព័រ ៣៣...) ប្រកបដោយប្រសិទ្ធភាព"។

អ្នកគ្រូ **កិះ ស្មើ** ជាគ្រូមត្តេយ្យសិក្សាមកពីសាលាបឋមសិក្សាត្រញូង បានលើកឡើងថា **"នាងខ្ញុំទទួលបានចំណេះដឹងជាច្រើនពីអ្នកគ្រូដែលបានចែករំលែកបទពិសោធន៍ក្នុងការបង្រៀន និងរៀន ជាពិសេសទាក់ទងទៅនឹងកិច្ចតែងការបង្រៀន។ វគ្គបំប៉ននេះពិតជាមានសារៈប្រយោជន៍ណាស់សម្រាប់នាងខ្ញុំដើម្បីរៀបចំមេរៀនយកទៅបង្រៀនសិស្សឱ្យបានល្អប្រសើរ និងត្រឹមត្រូវតាមមុខវិជ្ជានីមួយៗ"**។



សម្ភារៈសិក្សាដែលគម្រោង TRAC III បានផ្តល់ដល់សាលារៀនគោលដៅសម្រាប់សិស្សានុសិស្ស

គម្រោង TRAC III បានផ្តល់សម្ភារៈសិក្សាមួយចំនួនដើម្បីគាំទ្រសកម្មភាពរៀនពីចម្ងាយដល់សាលារៀនគោលដៅ និងនៅតែបន្តផ្តល់ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូបង្រៀនអំពីវិធីសាស្ត្របង្រៀន និងរៀន របៀបចែកសន្លឹកកិច្ចការដល់សិស្សប្រកបដោយសុវត្ថិភាពក្នុងអំឡុងពេលជំងឺកូវីដ-១៩ កំពុងឆ្លងរីករាលដាល។ កិច្ចនេះគឺធ្វើឡើងធានាឱ្យបានថា សិស្សនៅតែទទួលបានការសិក្សាសមស្របមួយទោះបីជាពួកគេនៅផ្ទះក៏ដោយ ក៏នៅអាចមានឱកាសបន្តការសិក្សាបានយ៉ាងសកម្ម៕

# ៧

# រចនាបថ ហេដ្ឋារចនាសម្ព័ន្ធ

"ធ្វើឱ្យទម្រង់ការអប់រំស្របតាមតម្រូវការ និងដើរតួនាទីថ្មីៗ"។

## Infrastructure Design

"Making educational forms that follow new needs and functions."



# សម្ភារៈសម្រាប់កុមារលេងត្រូវបានដំឡើងនៅសាលារៀនគោលដៅ

នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (រីក IV/ REACH IV) ក្រោមការគាំទ្រហិរញ្ញប្បទានពីអង្គការវីវើល (WeWorld) បានរៀបចំសម្ភារៈសម្រាប់កុមារលេងត្រូវបានដំឡើងនៅសួនកុមារ (Playground) នៅសាលារៀនគោលដៅថ្មីចំនួន ៣សាលា នៅក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ សាលារៀនទាំងបីនេះ ដូចជា សាលាបឋមសិក្សាសំប៉ាន សាលាបឋមសិក្សាឯកលីផល និងសាលាបឋមសិក្សាខ្លងពពក។ ការដំឡើងសម្ភារៈទាំងនេះសម្រាប់ឆ្លើយតបនឹងតម្រូវការរបស់សិស្សនៅសាលារៀនគោលដៅបន្ថែមថ្មីដើម្បីពង្រឹងការអប់រំកុមារ។

នាយកសាលា ព្រមទាំងលោកគ្រូអ្នកគ្រូបានសាទរយ៉ាងសប្បាយរីករាយចំពោះការចូលមកអន្តរាគមន៍របស់គម្រោង ជាពិសេសបានថ្លែងអំណរគុណដល់អង្គការ ខេប និងម្ចាស់ជំនួយដែលបានជួយដល់សាលារៀនរបស់ពួកគាត់៕



*សកម្មភាពរៀបចំកន្លែងសម្រាប់កុមារលេងនៅសាលាបឋមសិក្សាឯកលីផលដែលជាសាលារៀនគោលដៅថ្មីរបស់គម្រោងក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។*

# ការរៀបចំថ្នាក់មត្តេយ្យទំនើបមានការទាក់ទាញខ្លាំងដល់កុមារមករៀន

គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRAC III) បានរចនាបន្ទប់បែបមត្តេយ្យទំនើបនឹងគ្រោងបង្កើតជាសាលាមត្តេយ្យជំនាន់ថ្មីសម្រាប់សាលារៀនគោលដៅចំនួន ៦ ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ រួមមាន៖ សាលាបឋមសិក្សាតាំងស្រី សាលាបឋមសិក្សាអ្នកតាស្នឹង សាលាបឋមសិក្សាជៀស សាលាបឋមសិក្សាកពប្រាំ សាលាបឋមសិក្សាក្រញូង និងសាលាបឋមសិក្សាបឹងត្រាវ។ គម្រោងបានធ្វើការកែលម្អបន្ទប់សិក្សាដែលមានស្រាប់ដោយបំពាក់គ្រឿងសង្ហារឹមថ្មីៗ ជួសជុល ឬកសាងបង្គន់ថ្មី។ ម៉្យាងទៀត គម្រោងក៏បានរចនាសួនកុមារដើម្បីទាក់ទាញឱ្យកុមារចង់មកសាលារៀនដែលមានឧបករណ៍សម្រាប់កុមារអាចលោតតោង យោល ឡើង ចុះ រំអិលជំនួយដល់ចលនាចិត្តចលភាព និងចលនាពាងកាយក្នុងសួន។



*បន្ទប់សិក្សាមត្តេយ្យសិក្សារចនាបែបទំនើបនៅសាលាបឋមសិក្សាតាំងស្រី ស្រុកបាធាយ ខេត្តកំពង់ចាម។*

ជាពិសេស គម្រោងបានផ្តល់ទូរទស្សន៍មួយគ្រឿង សម្ភារៈសង្គ្រោះបឋម និង Tablet មួយសម្រាប់គ្រូងាយស្រួលក្នុងការបង្រៀន និងរៀន ដើម្បីបង្ហាញសកម្មភាពមួយចំនួនទៅដល់សិស្សានុសិស្សក្នុងការអនុវត្តផ្ទាល់ ដូចជា រឿងនិទាន ចម្រៀង រាំ ហាត់ប្រាណ និងសកម្មភាពផ្សេងៗដើម្បីជំនួយដល់ការបង្រៀនប្រកបដោយប្រសិទ្ធភាព៕

# ការរៀបចំបរិស្ថានស្អាត និងបរិក្ខាទំនើបទាក់ទាញកុមារមកសិក្សាច្រើន

សាលាបឋមសិក្សាឈើខ្លឹមទទួលបានពានរង្វាន់ជាសាលាមានបរិស្ថានមេត្រី ចំណាត់ថ្នាក់លេខ១ ក្នុងខេត្តត្បូងឃ្មុំ និងលេខ៣ ប្រចាំប្រទេសពីក្រសួងបរិស្ថាននៅដើមត្រីមាសទី៣ ក្នុងឆ្នាំ២០២១។ សមិទ្ធផលដ៏ត្រចះត្រចង់នេះកើតឡើងដោយសារថ្នាក់ដឹកនាំសាលា និងគណៈកម្មការទ្រទ្រង់សាលារៀន ដែលបានព្យាយាមពុះពារគ្រប់ឧបសគ្គក្នុងការអភិវឌ្ឍសាលារហូតដល់មានការទាក់ទាញពីសប្បុរសជន ឪពុកម្តាយ សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ជាពិសេសទាក់ទាញបានការវិនិយោគការអប់រំពីគម្រោងកុមារកម្ពុជារីករាយ (HCC)។ គម្រោងនេះទទួលជំនួយហិរញ្ញប្បទានពីមូលនិធិ គីនឆាន់ស្ទីហ្វទុង ហើយសហប្រតិបត្តិដោយអង្គការខេប និងសមាគមគ្រួសារយើង (KRY) ចាប់តាំងពីចុងឆ្នាំសិក្សា ២០១៨-២០១៩ មក។

សាលាបឋមសិក្សាឈើខ្លឹមបានផ្លាស់ប្តូរពីអគារសិក្សាឈើទ្រុឌទ្រោមមកជាអគារដែកថ្មី បរិវេណសាលារៀនគ្រលីកគ្រឡុកក្លាយមកជាចាក់គ្រោះរាបស្មើ មានសួនច្បារ សួនកុមារ សួនជីវៈ អគារមត្តេយ្យសិក្សា មានកង់ទីនបង្គន់កែច្នៃថ្មី មានកញ្ចុះទទួលភ្ញៀវ តារាងបាល់ទះ និងបាល់ទាត់ រូបចម្លាក់ កន្លែងដាក់កង់ម៉ូតូ អគារច្នៃលាបពណ៌ថ្មី ក្រាលឥដ្ឋការ៉ូ បណ្ណាល័យធំស្អាតដោយមានការរៀបចំដាក់សៀវភៅតាមលំដាប់ងាយស្រួលសម្រាប់សិស្សយកអាន និងទីចាត់ការនៅជាច់ដោយឡែក លោកគ្រូអ្នកគ្រូ និងបុគ្គលិកការិយាល័យគោរពម៉ោងការងារល្អ។ ម្យ៉ាងវិញទៀត ការរៀបចំបរិស្ថាននៅជុំវិញថ្នាក់រៀនមានការរៀបចំជាការ៉ូឡាលក្ខណៈច្នៃប្រឌិត សួននៅមុខថ្នាក់រៀន រៀបចំព័ទ្ធដោយប៉ក់ឡៀលាបថ្នាំពណ៌ស្រស់ស្អាតធ្វើឱ្យមានការទាក់ទាញសិស្សមករៀនកាន់តែច្រើនទៅៗ៕



សិស្សមត្តេយ្យកំពុងសិក្សានៅក្នុងថ្នាក់រៀន។



ការរៀបចំការ៉ូឡានៅមុខបរិវេណថ្នាក់រៀនស្អាត។




ប្លង់មេសាលាបឋមសិក្សាឈើខ្លឹម

# ៨

# ការអភិវឌ្ឍបណ្ណាល័យ

“បណ្ណាល័យសាលារៀនៈ ជាសោរសម្រាប់អតីតកាល និង
ជាទ្វារសម្រាប់អនាគត”។

## Library Development

"The School Library: Key to the Past and Gateway to the Future."







# សកម្មភាពអំណាន និងសកម្មភាពសិស្សខ្ចីសម្ភារៈសិក្សានៅបណ្ណាល័យស្តង់ដាសតវត្សរ៍ទី២១ យកទៅសិក្សានៅផ្ទះ


*សកម្មភាពរបស់កុមារមកខ្ចីសៀវភៅយកទៅអាននៅផ្ទះនៅក្នុងសាលាបឋមសិក្សាបឹងត្រាវ។*

គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់/TRAC III) គឺជាគម្រោងមួយរបស់អង្គការ ខេប ដែលផ្តល់ការអន្តរាគមន៍ចម្រុះផ្តោតលើការវាយតម្លៃបន្តបន្ទាប់ផ្អែកទៅលើសៀវភៅស្តង់ដាអំណាន និងមានសកម្មភាពសំខាន់ៗជាច្រើន ដូចជាការបំប៉ន និងការជ្រើសរើសគ្រូបង្វឹកអំណាន ដើម្បីសម្របសម្រួលអំណាន អភិបាលកិច្ចល្អ ការវង្វាយតម្លៃបន្តបន្ទាប់ កម្មវិធីកុមារជួយកុមារ កម្មវិធីសុសវែរពង្រឹងអំណានផ្សាភ្ជាប់នឹង Tablets ពង្រឹងការចូលរួមពីឪពុកម្តាយក្នុងការអប់រំ ការផ្តល់ល្បែងពង្រឹងអំណាន និងផលិតសម្ភារៈបន្ថែមក្នុងថ្នាក់រៀន ជួយសិស្សស្របពេលតាមរយៈលទ្ធផលតេស្ត និងការធ្វើតេស្តតាមប្រព័ន្ធអេឡិចត្រូនិក ការបង្កើតបណ្ណាល័យសតវត្សរ៍ទី២១។

ការអភិវឌ្ឍបណ្ណាល័យក្នុងសាលារៀនគោលដៅចំនួន ១៨ ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំឱ្យក្លាយជាបណ្ណាល័យសតវត្សរ៍ទី២១ ជាសកម្មភាពយ៉ាងសំខាន់មួយក្នុងចំណោមសកម្មភាពសំខាន់ៗខាងលើរបស់គម្រោង។ បណ្ណាល័យថ្មីនេះត្រូវបានរចនាឡើងតាមបែបទំនើបដោយគម្រោង ដើម្បីផ្តល់ភាពងាយស្រួលក្នុងការនិទានរឿង និងស្វ័យសិក្សា ហើយវាបានទាក់ទាញសិស្សឱ្យចូលមកអានសៀវភៅដែលមានច្រើនបែបសម្រាប់ឱ្យកុមារខ្ចី លេងល្បែងសិក្សា រៀនតាម Tablets (ថាប់ប្លេត) និងមានកម្មវិធីសិក្សាជាច្រើនទៀតជួយពង្រឹងសមត្ថភាពអានរបស់កុមារ និងអាចឱ្យពួកគេរៀនពីចម្ងាយបានសម្រាប់កុមារមិនមានទូរសព្ទដៃឆ្លាតវៃក្នុងការប្រើប្រាស់ក្នុងអំឡុងពេលនៃការឆ្លងរីករាលដាលជំងឺកូវីដ-១៩។ ម្យ៉ាងវិញទៀត បរិយាកាសក្នុងបណ្ណាល័យមានផាសុកភាព មានកន្លែងអង្គុយច្រើនសណ្ឋានងាយស្រួលសម្រាប់កុមារផ្ទង់អារម្មណ៍លើការអាន ដែលនេះអមដោយបរិស្ថានដែលមានការបំពាក់គ្រឿងសង្ហារិមថ្មីៗល្អប្រណិត។

ទោះបីជាជំងឺកូវីដ-១៩ នៅតែកំពុងឆ្លងរីករាលដាលយ៉ាងណាក៏ដោយ គម្រោងនៅតែព្យាយាមស្វែងរកមធ្យោបាយជួយអន្តរាគមន៍ដល់សាលារៀនគោលដៅទាំងអស់ទៅតាមលទ្ធភាព និងបានជំរុញលើកទឹកចិត្តឱ្យលោកគ្រូអ្នកគ្រូនៅសាលារៀនគោលដៅទាំងអស់បើកបណ្ណាល័យទទួលសិស្សខ្ចីសៀវភៅយកទៅរៀននៅផ្ទះបាន។ ចំនួនសិស្សចូលមកក្នុងបណ្ណាល័យត្រូវបានកំណត់ដោយច្បាស់លាស់តាមថ្នាក់នីមួយៗ និងត្រូវបានគោរពតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល គឺ ៣ កុំ ៣ ការពារដោយខ្ជាប់ខ្ជួនបំផុតក្នុងការការពារជំងឺឆ្លង៕



៦
កម្មវិធីបំណិនជីវិត
និងប្រឹក្សាអាជីព
"បំណិនជីវិតទទួលបានអត្ថប្រយោជន៍ពីការអប់រំសកម្មភាពគ្រូបង្រៀន
មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកម្មវិធីសិក្សាឌីណាមិក"។
Life Skills Education & Career Counseling
"Life Skills benefit from proactive education, Qualified Instructors,
& Dynamic Curriculum.."

# ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅបំណិនជីវិតសម្រាប់កុមារីជួរការ

ក្រសួងអប់រំ យុវជន និងកីឡាបានចេញសេចក្ដីប្រកាសលេខ ៦៣៧ និង ៦៣៨ ចុះថ្ងៃសុក្រ ១រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ស្ដីពី ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅបំណិនជីវិតសម្រាប់កុមារីវ័យជំទង់ អាយុ ១១ឆ្នាំ ដល់ ១៣ឆ្នាំ (មាន៤ចំណងជើងគឺ ១) ខ្ញុំនិងបរិស្ថានជុំវិញខ្ញុំ ២) ខ្ញុំនិងរាងកាយខ្ញុំ ៣) ខ្ញុំ អារម្មណ៍ខ្ញុំ និងទំនាក់ទំនងរបស់ខ្ញុំ ៤) ខ្ញុំនិងបំណងប្រាថ្នាខ្ញុំ និងសៀវភៅបំណិនសម្រាប់កុមារីវ័យជំទង់ អាយុពី ១៤ ដល់ ១៧ឆ្នាំ (មាន៤ចំណងជើងគឺ ១) ខ្លួនឯង ២) ស្វ័យប្រសិទ្ធភាព ៣) សមត្ថភាពធ្វើការងារ និង ៤) សមត្ថភាពរកការងារ ដែលជាស្នាដៃនិពន្ធ និងរៀបរៀងដោយគណៈកម្មការនិពន្ធគម្រោង LSLAG របស់អង្គការខេប ក្រោយជំនួយហិរញ្ញប្បទានក្រុមហ៊ុន Gap Inc.។ សៀវភៅកម្មវិធីបំណិនជីវិត Gap Inc. P.A.C.E. នេះត្រូវបានដាក់ឱ្យប្រើប្រាស់ជាឯកសារជំនួយសម្រាប់ការរៀន និងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

កម្មវិធី Gap Inc. P.A.C.E. ដែលមានន័យពេញលេញថាជាការដាក់ទុនលើជំនាញថ្មីដើម្បីអនាគត (Personal Advancement and Career Enhancement) គឺជាកម្មវិធីច្នៃប្រឌិតថ្មីមួយដែលបញ្ចូលបំណិនមូលដ្ឋានយេនឌ័រសម្រាប់ក្មេងស្រីដែលមានអាយុចាប់ពី ១១ ដល់ ១៧ឆ្នាំ។ កម្មវិធីនេះមានគោលបំណងដើម្បីធ្វើឱ្យដំណើរផ្លាស់ប្ដូរប្រែកបដោយភាពរីកចម្រើនទៅជាមនុស្សពេញវ័យ ខណៈពេលដែលពួកគេអាចទទួលស្គាល់នៃការបម្រែបម្រួលរូបរាងកាយ និងអាចដោះស្រាយបញ្ហាភាពងាយរងគ្រោះផ្នែកយេនឌ័រ និងវិសមភាព ព្រមទាំងកសាងបំណិនជីវិតសម្រាប់កុមារីឱ្យមានទំនុកចិត្តលើខ្លួនឯង មានសមត្ថភាពធ្វើការសម្រេចចិត្ត ចេះរៀបចំផែនការសម្រាប់អនាគត ព្រមទាំងយល់ច្បាស់ពីការផ្លាស់ប្ដូររាងកាយ ផ្លូវចិត្ត អារម្មណ៍ក្នុងអំឡុងពេលវ័យជំទង់ ដែលជាវ័យមាន (បន្តទៅទំព័រ ៤២)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៦៣៧ **អយក.**ប្រក

**ប្រកាស**
**ស្ដីពី**
**ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ**
**សៀវភៅបំណិនជីវិតសម្រាប់កុមារីវ័យជំទង់ អាយុ ១១ឆ្នាំ ដល់ ១៣ឆ្នាំ**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញ អនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យ លេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្ដីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្ដីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងសំណើសុំអនុម័តសៀវភៅលេខ ០៤១/២១ស.ស.អ.ក ស្ដីពីសំណើសុំអនុម័តបោះពុម្ពសៀវភៅបំណិនជីវិត ដែលមានចំនួន៨ចំណងជើងថ្មី ចុះថ្ងៃអង្គារ ១រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ របស់អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE)
- យោងលិខិតលេខ ០៦៣ អគ.អរ.អកស ស្ដីពីសំណើសុំការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅបំណិនជីវិតសម្រាប់កុមារី ចំនួន ៨ចំណងជើង ចុះថ្ងៃពុធ ១២រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានអប់រំ

**សម្រេច**

**ប្រការ១.**_ អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅបំណិនជីវិតសម្រាប់កុមារីវ័យជំទង់ អាយុ ១១ឆ្នាំ ដល់ ១៣ឆ្នាំ ដែលមាន៤ចំណងជើងគឺ **១-ខ្ញុំនិងបរិស្ថានជុំវិញខ្ញុំ ២-ខ្ញុំនិងរាងកាយខ្ញុំ ៣-ខ្ញុំ អារម្មណ៍ខ្ញុំ និងទំនាក់ទំនងរបស់ខ្ញុំ ៤-ខ្ញុំនិងបំណងប្រាថ្នាខ្ញុំ** ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់គណៈកម្មការនិពន្ធនៃអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE) ដោយមានការគាំទ្រពីកម្មវិធី P.A.C.E របស់ក្រុមហ៊ុន Gap Inc. ដើម្បីប្រើប្រាស់ជាឯកសារជំនួយសម្រាប់ការរៀននិងបង្រៀន នៅតាមសាលារៀនបឋមសិក្សា និងសាលាមធ្យមសិក្សាចំណេះទូទៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.**_ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និង កីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលារៀនបឋមសិក្សា សាលារៀនមធ្យមសិក្សាចំណេះទូទៅ និងអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE) មានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ សុក្រ ១រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល:**
- គ្រប់សាលារាជធានីខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៦៣៨ អយក.ប្រក

ប្រកាស
ស្តីពី
ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
សៀវភៅបំណិនជីវិតសម្រាប់កុមារីពេញវ័យ អាយុ ១៤ឆ្នាំ ដល់ ១៧ឆ្នាំ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញ អនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យ លេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងសំណើសុំអនុម័តសៀវភៅលេខ ០៤១/២១ស.ស.អ.ក ស្តីពីសំណើសុំអនុម័តបោះពុម្ពសៀវភៅបំណិនជីវិត ដែលមានចំនួន៨ចំណងជើងថ្មី ចុះថ្ងៃអង្គារ ១រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ របស់អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(KAPE)
- យោងលិខិតលេខ ០៦៣ អគ.អ.អកស ស្តីពីសំណើសុំការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅបំណិនជីវិតសម្រាប់កុមារី ចំនួន៨ចំណងជើង ចុះថ្ងៃពុធ ១២រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានអប់រំ



សម្រេច

**ប្រការ១.**_ អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅបំណិនជីវិតសម្រាប់កុមារីវ័យជំទង់ អាយុ ១៤ឆ្នាំ ដល់ ១៧ឆ្នាំ ដែលមានចំណង៤ជើងគឺ **១-ខ្លួនឯង ២-ស្វ័យប្រសិទ្ធភាព ៣-សមត្ថភាពធ្វើការងារ ៤-សមត្ថភាពរកការងារ** ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់គណៈកម្មការនិពន្ធនៃអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(KAPE) ដោយមានការគាំទ្រពីកម្មវិធី P.A.C.E របស់ក្រុមហ៊ុន Gap Inc. ដើម្បីប្រើប្រាស់ជាឯកសារជំនួយសម្រាប់ការរៀននិងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.**_ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និង កីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលារៀនមធ្យមសិក្សាចំណេះទូទៅ និងអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(KAPE) មានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ សុក្រ ១រោច ខែ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ... ឆ្នាំ២០២១

**កន្លែងទទួល៖**
- គ្រប់សាលារាជធានីខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន




(...តពីទំព័រ ៤១) ផលប៉ះពាល់សំខាន់ៗចំពោះលទ្ធផលនៅពេលពេញវ័យ។ ជំនឿស្នូល និងសក្តានុពលកម្មវិធីសិក្សាគឺថាក្មេងស្រីអាចផ្លាស់ប្តូរជីវិតរបស់ពួកគេផ្ទាល់ជាមួយនឹងជំនាញសំខាន់ៗ ដែលត្រូវបានផ្តល់ឱ្យពួកគេនៅពេលដែលពួកគេមានវ័យជំទង់។

ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅបំណិនជីវិតសម្រាប់កុមារីវ័យជំទង់ទាំង ៨ ម៉ូឌុលនេះ គឺជាសមិទ្ធផលសម្រេចបានដ៏ធំមួយរបស់គម្រោងដែលបានខិតខំប្រឹងប្រែងអនុវត្តសកម្មភាពតាមផែនការរបស់ខ្លួនក្នុងរយៈពេល ២ឆ្នាំកន្លងមកនេះ។ នៅសាលារៀនគោលដៅទាំង ២៣ សាលា ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ មានការចូលរួមសហការយ៉ាងល្អពីក្រសួងអប់រំ យុវជន និងកីឡា មន្ទីរ-ការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ស្រុក អាជ្ញាធរមូលដ្ឋាន លោកគ្រូអ្នកគ្រូ និងអ្នកពាក់ព័ន្ធផ្សេងទៀត៕

# សៀវភៅបំណិនជីវិតទាំង៨មុខត្រូវបានផ្សព្វផ្សាយនៅទូទាំងប្រទេស

នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG) បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី **“ការផ្សព្វផ្សាយឯកសារបំណិនជីវិត”** តាមប្រព័ន្ធអនឡាញ (Zoom) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម អ៊ឹម កុច** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។ សិក្ខាសាលានេះមានសិក្ខាកាមចូលរួមចំនួន ១១៦នាក់ មកពី ២៥ រាជធានី-ខេត្ត ក្រុងរួមមាន៖ ប្រធាន និងមន្ត្រីនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ អនុប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធានការិយាល័យនៃនាយកដ្ឋានបឋមសិក្សា តំណាងនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ប្រធាន-អនុប្រធានការិយាល័យ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត នាយកវិទ្យាល័យ ក្រុមព្រះមហាលាភ, សណ្តែក, ហោណាំហុងព្រៃញា, ហ៊ុន សែន ខ្ចៅ, ហ៊ុន សែន ពាមជីកង, ហ៊ុន សែនកំពង់ចាម, ដីដុះ, សម្តេចជួនណាត, ហ៊ុន សែន ព្រៃទទឹង, ល្វា, ហ៊ុន សែនអូរាំងឪ, ក្រូចឆ្មារ, ហ៊ុន សែនអម្ពវ៉ែនជំនីក, ហ៊ុន សែន ព្រែកអាជី, និងវិទ្យាល័យសម្តេចតេជោ ហ៊ុន សែនសួង, អនុវិទ្យាល័យទួលថ្ម, អង្គរ, ហ៊ុន សែន ទួលសុភី និងអនុវិទ្យាល័យ ជាចក, គ្រូបង្រៀន និងតំណាងពីម្ចាស់ជំនួយរបស់ក្រុមហ៊ុន Gap Inc. និងអ្នកពាក់ព័ន្ធដទៃទៀត។

កម្មវិធីនេះមានគោលបំណងផ្សព្វផ្សាយឯកសារបំណិនជីវិតទាំង ៨ ម៉ូឌុលដែលក្រសួងអប់រំ យុវជន និងកីឡា បានអនុញ្ញាតឱ្យបោះពុម្ពផ្សាយសម្រាប់ប្រើប្រាស់ជាឯកសារជំនួយផ្លូវការដល់ការរៀន និងបង្រៀននៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តម អ៊ឹម កុច** បានមានប្រសាសន៍ថា **“ការអប់រំគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងវប្បធម៌ដើម្បីធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ កម្មវិធីអប់រំបំណិនជីវិតសម្រាប់កុមារីពេញវ័យ និងវ័យជំទង់នេះគឺជាជំនួយដល់សាលារៀនសហគមន៍ និងអង្គការដៃអភិវឌ្ឍន៍ក្នុងការរៀបចំឱ្យមានសៀវភៅ សម្ភារៈឧបទ្ទេសដើម្បីដំណើរការអនុវត្តកម្មវិធីបំណិនជីវិតនេះតាមមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងធានាបាននូវនិរន្តរភាព”**។

លោក សៅ វណ្ណា នាយកប្រតិបត្តិអង្គការ ខេប បានមានប្រសាសន៍ថា **“ការរៀបចំសៀវភៅកម្មវិធីបំណិនជីវិតសម្រាប់កុមារីវ័យជំទង់ និងកុមារីពេញវ័យ ដើម្បីឱ្យពួកគេមានបំណិនមួយក្នុងការរៀបចំខ្លួនទុកជាចំណេះដឹងសម្រាប់ពួកគេដែលនឹងត្រូវឆ្លងកាត់ការផ្លាស់ប្តូររូបរាងកាយ ផ្លូវចិត្ត សង្គម ក្នុងអំឡុងពេលវ័យជំទង់ ដែលជាវ័យមួយអាចប៉ះពាល់យ៉ាងសំខាន់ដល់ពេលពួកគេពេញវ័យ ជាពិសេសកុមារីវ័យជំទង់អាយុពី ១១ ដល់ ១៣ ឆ្នាំ និងក្មេងស្រីពេញវ័យអាយុពី ១៤ ដល់ ១៧ ឆ្នាំ។**

លោកបានបន្តទៀតថា ពេលណាពួកគេអាចផ្លាស់ប្តូរប្រកបដោយភាពត្រឹមត្រូវ នោះទើបជាមនុស្សពេញវ័យអាចនឹងដោះស្រាយបញ្ហាងាយរងគ្រោះផ្នែកវិសមភាពយេនឌ័របាន ហើយម៉ូឌុលទាំង (បន្តទៅទំព័រ ៤៤...)




*ឯកឧត្តម អ៊ឹម កុច រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ផ្តល់សន្ទរកថាបើកសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយឯកសារបំណិនជីវិតរបស់គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី។*

(...តពីទំព័រ ៤៤) នេះនឹងជាជំនួយដើម្បីជំរុញឱ្យក្មេងស្រីមានទំនុកចិត្ត សមត្ថភាពក្នុងការធ្វើផែនការជីវិតសម្រាប់ថ្ងៃអនាគត”។

លោកស្រី ឡុង ដានី ជានាយិការងនៃវិទ្យាល័យដីដុះ បានមានប្រសាសន៍ថា “កម្មវិធីអប់រំបំណិនជីវិតសម្រាប់កុមារីនេះពិតជាមានសារៈសំខាន់សម្រាប់យើងទាំងអស់គ្នា ជាពិសេសចំពោះសិស្សដែលជាកុមារី។ នាងខ្ញុំបានជួយផ្សព្វផ្សាយ និងរៀបចំកាលវិភាគសម្រាប់គ្រូក្នុងការបង្រៀនកម្មវិធីបំណិននេះ ដោយយកម៉ោងទំនេរបង្រៀន។ បញ្ហាដែលពួកគាត់ជួបប្រទះក្នុងការបង្រៀន ដោយសារក្នុងសៀវភៅប្រើប្រាស់ពាក្យចំៗ (អសុរោះ) ខ្លឹមសារ និងពាក្យក្នុងសៀវភៅពិបាកក្នុងការពន្យល់ ព្រមទាំងបង្ហាញរូបភាពចំៗ។ តាមការសង្កេតរបស់ខ្ញុំឃើញថា សិស្សចូលរួមបានច្រើនប្រហែលជាពី ៧០ ទៅ ៨០ភាគរយ ក្នុងកម្មវិធីភែស (P.A.C.E) នេះ។ ពួកគាត់យល់ដឹងបានច្រើនអំពីតម្លៃខុសគ្នារវាងមនុស្សប្រុស និងមនុស្សស្រី តម្លៃការងារ ការយល់ដឹងពីការចូលរួមក្នុងសង្គម ស្អប់ខ្ពើមអំពើហិង្សា ផ្លាស់ប្តូរអាកប្បកិរិយាសិស្សប្រុសចំពោះសិស្សស្រី”។

លោកស្រី វង្ស សម្ផស្ស ជាគ្រូបង្រៀននៅវិទ្យាល័យខ្ទៅបានមានប្រសាសន៍ថា “នៅក្នុងដំណើរការបង្រៀនកម្មវិធីអប់រំបំណិនជីវិតសម្រាប់កុមារីនេះ នាងខ្ញុំបានរៀបចំផែនការបង្រៀនក្នុងរយៈមួយខែម្តងជូនទៅអង្គការខេប និងកំណត់យកម៉ោងទំនេររបស់សិស្សក្នុងការបង្រៀន។ នៅពេលបង្រៀន នាងខ្ញុំបានជួបការលំបាកមួយចំនួន ដូចជា បញ្ហាបន្ទប់រៀនដោយសារសាលារៀនរបស់នាងខ្ញុំជួសជុលអគារ ទើបធ្វើឱ្យម៉ោងសិក្សាកម្មវិធីអប់រំជីវិតបានផ្អាកមួយរយៈពេលសិន។ ម្យ៉ាងទៀត នាងខ្ញុំមិនសូវយល់ខ្លឹមសារមេរៀន ក៏ដូចជាពាក្យបច្ចេកទេសមួយចំនួនតាមម៉ូឌុលនីមួយៗ។ ទោះបីជាជួបបញ្ហាលំបាកយ៉ាងក៏ដោយ នាងខ្ញុំបានព្យាយាមខិតខំប្រឹងប្រែងបង្រៀនសិស្សតាមលទ្ធភាពក្នុងម៉ូលឌុលនីមួយៗ។ បន្ទាប់ពីបង្រៀនហើយ នាងខ្ញុំសង្កេតឃើញថា សិស្សមានការប្រែប្រួលទាំងឥរិយាបថ និងចំណេះដឹងរបស់ពួកគេ ព្រមទាំងដឹងខ្លួនឯងច្បាស់អំពីការបម្រែបម្រួលរូបរាងកាយ បញ្ញាស្មារតី ចិត្តគំនិត និងអារម្មណ៍នៅពេលដែលពួកគាត់ពេញវ័យ”។

ឯកសារបំណិនជីវិតនេះត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដោយមានកិច្ចសហកាយ៉ាងរលូនជាមួយក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក នាយកសាលា លោកគ្រូអ្នកគ្រូ និងអ្នកពាក់ព័ន្ធផ្សេងទៀត៕



*លោក ទុំ ទីតូណា ប្រធានគម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី ធ្វើបទបង្ហាញអំពីសមិទ្ធផលសម្រេចបានរបស់គម្រោង។*

# សេវាប្រឹក្សាអាជីពធ្វើឱ្យសិស្សអភិវឌ្ឍន៍ផែនការជីវិតកាន់តែប្រសើរ




*សកម្មភាពផ្តល់សេវាប្រឹក្សាអាជីពដល់ថ្នាក់ទី៨ និងបានបង្ហាញពីសាលារបស់ខ្លួនបានទទួលស្គាល់ជាសាលារៀនជំនាន់ថ្មី*

នៅថ្ងៃទី១២-១៤ ខែកក្កដា ឆ្នាំ២០២១ សាលារៀនជំនាន់ថ្មី វិទ្យាល័យ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ព្រែកអញ្ចាញ បានរៀបចំការប្រជុំរវាងគណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូ និងសិស្សថ្នាក់ទី៧ ទី៨ និងទី៩ ស្តីពី **"សេវាប្រឹក្សាអាជីព"** តាមប្រព័ន្ធអនឡាញ (Google Meet និង Zoom) ក្នុងពេលតែមួយដែលមានអ្នកចូលរួមសរុបចំនួន ៣៦២នាក់។ កិច្ចប្រជុំនេះត្រូវបានរៀបចំធ្វើឡើងដោយផ្តោតលើចំណុចសំខាន់ៗមួយចំនួន រួមមាន៖ ១) ស្វែងរកបញ្ហារបស់សិស្សដែលកំពុងជួបប្រទះក្នុងការសិក្សាតាមអនឡាញ។ ២) ផ្តល់ជាដំណោះស្រាយរួមដើម្បីឱ្យដំណើរការបង្រៀន និងរៀនកាន់តែល្អប្រសើរ។ ៣) ជំរុញ និងលើកទឹកចិត្តលើការសិក្សារៀនសូត្រ។ ៤) ផ្តល់វិធីសាស្ត្រល្អៗសម្រាប់ការចូលប្រឡងនានា និង ៥) ផ្សព្វផ្សាយពីឱកាសចូលរួមការប្រកួតប្រជែងនានាដល់សិស្ស។

ការបង្កើតសេវាប្រឹក្សាអាជីពនេះ គឺដើម្បីឱ្យស្របទៅនឹងគោលនយោបាយសាលារៀនជំនាន់ថ្មីក្នុងការពង្រឹងសិទ្ធអំណាចដល់យុវជន ដែលបណ្តុះទម្លាប់ឱ្យពួកគេចេះអនុវត្តតួនាទីលើការគ្រប់គ្រងសម្ភារៈ និងសេវាថ្មីៗដែលរៀបចំឱ្យមានមណ្ឌលនៅក្នុងសាលារៀន ហើយទទួលបានសេវាប្រឹក្សាអាជីព និងប្រឹក្សាយោបល់ផ្សេងៗ។ អត្ថប្រយោជន៍ពីសេវាប្រឹក្សាអាជីពដែលសិស្សទទួលបាន រួមមាន៖ ១) ទទួលបានការប្រឹក្សាយោបល់ជាមួយគ្រូប្រឹក្សានៅបន្ទប់ប្រឹក្សាអាជីពប្រកបដោយទំនុកចិត្ត។ ២) សិស្សអាចរៀបចំផែនការអាជីពច្បាស់លាស់។ ៣) សិស្សអាចរៀបចំផែនការការសិក្សាត្រឹមត្រូវ។ ៤) សិស្សទទួលបានការជំរុញ និងលើកទឹកចិត្តឱ្យស្រលាញ់ការសិក្សាដើម្បីសម្រេចគោលដៅជីវិត។ ៥) សិស្សទទួលបានព័ត៌មានថ្មីៗដើម្បីស្វែងយល់អំពីអាជីពតាមរយៈការបណ្តុះបណ្តាលបន្ថែមជាមួយវាគ្មិនជំនាញ និង ៦) ការប្រើប្រាស់កម្មវិធីត្រីវិស័យដើម្បីជួយពួកគេបានស្វែងយល់កាន់តែច្រើនអំពីឱកាសការងារដែលមាននៅក្នុងប្រទេសកម្ពុជា។

ការប្រជុំនេះបានធ្វើឱ្យសិស្សយល់ដឹងកាន់តែច្បាស់អំពីសកម្មភាពសិក្សាពីចម្ងាយ រៀនរៀបចំផែនការជិវិត ជាពិសេសពួកគាត់ចេះកំណត់គោលដៅយ៉ាងជាក់លាក់ក្នុងការជ្រើសរើសជំនាញណាមួយឱ្យសមស្របទៅនឹងចរិតលក្ខណៈផ្ទាល់ខ្លួន។




*សកម្មភាពប្រជុំស្តីពី សេវាប្រឹក្សាអាជីព ថ្នាក់ទី៩ តាមប្រព័ន្ធអនឡាញ។*

# ការប្រឹក្សាអាជីពជាយន្តការជម្រើសជំនាញត្រឹមត្រូវសម្រាប់សិស្ស

នៅថ្ងៃទី២៨-២៩ ខែកក្កដា ឆ្នាំ២០២១ គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា (KYLA) បានរៀបចំការបណ្តុះបណ្តាលស្តីពី **"ការប្រឹក្សាអាជីព"** តាមប្រព័ន្ធអនឡាញដល់សិស្សនៅសាលារៀនគោលដៅចំនួនពីរ រួមមាន៖ វិទ្យាល័យ ហ៊ុន សែន ពញាក្រែក និងវិទ្យាល័យ កិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន មានជ័យ ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ ដែលមានសិស្សចូលរួមសរុបចំនួន ៣៦ នាក់។ ការបណ្តុះបណ្តាលនេះមានគោលបំណងផ្តោតសំខាន់ទៅលើ៖ ១) ការបង្ហាញពីសកម្មភាពគម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា។ ២) ការផ្តល់ព័ត៌មានអំពីប្រភេទមុខរបរ និងគ្រឹះស្ថានសិក្សានានាដល់សិស្ស។ ៣) កំណត់គោលដៅអាជីពនាពេលអនាគត។ ៤) ទស្សនាវីដេអូពីរបៀបទាញយកកម្មវិធីត្រីវិស័យ (Trey Visay App)។

សិស្សស្ម័គ្រចិត្តរបស់គម្រោងបានយល់ដឹងកាន់តែច្បាស់អំពីអាជីពការងារ ក៏ដូចជាការរៀបចំសរសេរកំណត់គោលដៅជីវិតរបស់ខ្លួនកាន់តែល្អប្រសើរ គឺពួកគាត់អាចស្វែងយល់បន្ថែមតាមរយៈកម្មវិធីត្រីវិស័យ។

ដំណើរការបណ្តុះបណ្តាលបានប្រព្រឹត្តទៅដោយរលូន មានការចែករំលែកយោបល់យ៉ាងផុសផុលក្រោមកិច្ចសហការពីនាយកសាលា លោកគ្រូអ្នកគ្រូ និងក្រុមតំណាងប្រឹក្សាអាជីព៕



*ការបណ្តុះបណ្តាលសិស្សនៅវិទ្យាល័យ ហ៊ុន សែន ពញាក្រែក និងកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែនមានជ័យ តាមប្រព័ន្ធអនឡាញ។*

# ការប្រឹក្សាអាជីពតាមរយៈកម្មវិធីត្រីវិស័យមានភាពងាយស្រួល

នៅថ្ងៃទី២៩-៣០ ខែកក្កដា ឆ្នាំ២០២១ គម្រោងលើកកម្ពស់ការអប់រំ និងការការងារនៅកម្ពុជា (ស៊ិក/SEEK) ក្រោមជំនួយហិរញ្ញប្បទានពីសហភាពអឺរ៉ុប និងប្រតិបត្តិដោយអង្គការ ខេប បានរៀបចំការបណ្តុះបណ្តាលស្តីពី **"ការប្រឹក្សាអាជីពតាមរយៈកម្មវិធីត្រីវិស័យ"** តាមរយៈប្រព័ន្ធអនឡាញដល់សិស្សវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន រលាប្អៀរ និងអនុវិទ្យាល័យ តាំងក្រសាំង ដែលមានសិស្សចូលរួមសរុប ៧៤នាក់។ ការបណ្តុះបណ្តាលនេះមានគោលបំណងផ្តោតលើចំណុចសំខាន់ៗចំនួន ៤ គឺ ១) ការយល់ពីគម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (SEEK) ដែលកំពុងអនុវត្តន៍សកម្មភាពនៅក្នុងសាលារៀន។ ២) ការបង្ហាញអំពីប្រភេទមុខរបរ និងគ្រឹះស្ថានសិក្សា។ ៣) ការកំណត់គោលដៅអាជីពនាពេលអនាគត និង ៤) ទស្សនាវីដេអូពីរបៀបទាញយកកម្មវិធីត្រីវិស័យ។

ក្នុងការបណ្តុះបណ្តាលនេះ សិស្ស និងលោកគ្រូអ្នកគ្រូទាំងអស់បានចូលរួមគាំទ្រសកម្មភាព ការចូលរួមលើកជាគំនិតយោបល់ និងសំណួរដេញដោលយ៉ាងសកម្មពាក់ព័ន្ធនឹងការប្រើប្រាស់កម្មវិធីត្រីវិស័យសម្រាប់សិក្សាស្វែងរកជំនាញដែលត្រូវនឹងខ្លួន៕


*សិស្សនៅអនុវិទ្យាល័យ តាំងក្រសាំងចូលរួមប្រជុំជាមួយគម្រោងតាមអនឡាញក្នុងសាលារៀន*

# តើមានកត្តាអ្វីខ្លះដែលសិស្សត្រូវត្រៀមខ្លួនសិក្សានៅសកលវិទ្យាល័យ?

នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ កម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន កំពង់ចាម បានរៀបចំសិក្ខាសាលាស្តីពី **"ការត្រៀមខ្លួនបន្តការសិក្សានៅសាកលវិទ្យាល័យ"** តាមរយៈប្រព័ន្ធអនឡាញ (Google Meet) ដែលមានអ្នកចូលរួមសរុបចំនួន ១០០នាក់ ដូចជា លោកគ្រូអ្នកគ្រូ និងសិស្សថ្នាក់ទី១០-១២ មកពីសាសារៀនជំនាន់ថ្មីជាច្រើនរួមមាន វិទ្យាល័យ ហ៊ុន សែន ពាមជីកង វិទ្យាល័យ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ព្រែកអញ្ចាញ និង វិទ្យាល័យ ព្រែកលៀប។

សិក្ខាសាលានេះ មានគោលបំណង ធ្វើឱ្យប្អូនៗសិស្សថ្នាក់ទី១០ ដល់ទី១២ បានស្វែងយល់អំពីឱកាសក្នុងការដាក់ពាក្យស្នើសុំអាហារូបករណ៍ និងទទួលបានបទពិសោធន៍ថ្មីៗអំពីការរៀបចំខ្លួនឱ្យបានកាន់តែប្រសើរ សម្រាប់បន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា ដោយភាពជឿជាក់។



*លោក សឿង វណ្ណ នាយកវិទ្យាល័យហ៊ុន សែន កំពង់ចាម បានជំរុញ និងលើកទឹកចិត្តសិស្សក្នុងការកំណត់គោលដៅ*

លោក **សឿង វណ្ណ** នាយកវិទ្យាល័យ ហ៊ុន សែន កំពង់ចាម បានមានប្រសាសន៍ថា *"ប្អូនៗកុំគិតថាខ្លួនឯងមិនពូកែ ព្រោះមនុស្សម្នាក់ៗមានភាពខ្លាំង និងមានសក្តានុពលខុសៗគ្នា សំខាន់ប្អូនៗត្រូវចេះរៀបចំគោលដៅជីវិតឱ្យបានត្រឹមត្រូវ។ មនុស្សម្នាក់ៗមិនពូកែទាំងអស់ទេ អ្នកខ្លះពូកែខាងភាសា តែខ្សោយខាងគណិតវិទ្យា។ ដូច្នេះ សូមប្អូនៗកុំអស់សង្ឃឹមការសិក្សា និងការប្រឡង គឺជាផ្នែកមួយនៃជីវិត ហើយដើម្បីទទួលបានជោគជ័យមួយ វាត្រូវការធាតុផ្សំជាច្រើន រាប់បញ្ចូលទាំងជំនាញរឹង និងជំនាញទន់ដែលប្អូនៗត្រូវខិតខំប្រឹងប្រែងអភិវឌ្ឍន៍ខ្លួនឱ្យទាន់សម័យកាល។ ប្រសិនបើប្អូនៗមិនស្វះស្វែងរកឱកាសក្នុងការអភិវឌ្ឍខ្លួនឱ្យទាន់សម័យនោះទេ ប្អូនៗនឹងក្លាយទៅជាមនុស្សបុរាណក្នុងសម័យទំនើបនេះ"*៕

# ការនិយាយជាសាធារណៈជាមាគ៌ាទំនាក់ទំនងល្អសម្រាប់យុវជនកម្ពុជា

កាលពីថ្ងៃទី២៥-២៧ និងថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា (KYLA) បានរៀបចំការបណ្តុះបណ្តាលស្តីពី **"ការនិយាយជាសាធារណៈ"** ដល់សិស្សនៅសាលារៀនគោលដៅចំនួន ៧ ដែលស្ថិតនៅក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ ដោយមានសិស្សសរុបចំនួន៥៨ នាក់ រួមទាំងនាយក និងលោកគ្រូអ្នកគ្រូបានចូលរួមនៅក្នុងការបណ្តុះបណ្តាលនេះតាមរយៈអនឡាញ។ ការបណ្តុះបណ្តាលនេះមានគោលបំណងបង្ហាញអំពីរបៀបរៀបចំការនិយាយជាសាធារណៈ និងផ្តល់ឱកាសដល់សិស្សបានអនុវត្តនិយាយជាក់ស្តែងចំគោលដៅឱ្យមានប្រសិទ្ធភាព។

**ស៊ូត ណូរ៉ានី** ជាសិស្សថ្នាក់ទី១០ A មកពីវិទ្យាល័យតេជោ ហ៊ុនសែន កំពង់ទ្រាសបាន លើកឡើងថា *"ការបណ្តុះបណ្តាលនេះ នាងខ្ញុំទទួលបានចំណេះដឹងល្អៗសម្រាប់ជួយពង្រឹងការនិយាយជាសាធារណៈរបស់ខ្ញុំឱ្យកាន់តែល្អប្រសើរ ហើយមានភាពក្លាហានក្នុងការនិយាយ ជាពិសេសវាជាយន្តការនាំផ្លូវឱ្យនាងខ្ញុំមើលឃើញផ្លូវណាដែលឈានទៅរកជោគជ័យនៅថ្ងៃអនាគត។ នាងខ្ញុំនឹងចែករំលែកចំណេះដឹងពីការបណ្តុះបណ្តាលនេះទៅកាន់មិត្តភក្តិ និងមនុស្សនៅជុំវិញខ្លួនរបស់ខ្ញុំ ដោយពន្យល់ណែនាំអំពីកម្មវិធីសិក្សា និងប្រាប់ពីអត្ថប្រយោជន៍ដែលពួកគាត់នឹងទទួលបាន។ នាងខ្ញុំពិតជាពេញចិត្តចំពោះការបណ្តុះបណ្តាលនេះណាស់ ព្រោះការនិយាយជាសាធារណៈ គឺជាជំនាញមួយពិតជាមានសារៈសំខាន់ក្នុងការទំនាក់ទំនងជាមួយមនុស្សជាប្រចាំថ្ងៃនៅក្នុងជីវិត"*។



*វគ្គសិស្ស លោកនាយក និងលោកគ្រូអ្នកគ្រូនៅក្នុងការបណ្តុះបណ្តាលស្តីពី និយាយជាសាធារណៈ*

លទ្ធផលវាយតម្លៃ សិស្សចូលរួមទាំងអស់មានសេចក្តីរីករាយជាមួយការបណ្តុះបណ្តាលនេះ ហើយពួកគាត់បានយល់ដឹងលើខ្លឹមសារមេរៀនដែលបានចែករំលែកពី ៦០% ទៅដល់ ៨០%៕

# នីតិវិធីក្នុងការចុះបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម និងភាពជាសហគ្រិនជាមូលដ្ឋានគ្រឹះសម្រាប់សិស្សសិក្សាចង់បង្កើតអាជីវកម្មនៅថ្ងៃមុខ

គម្រោងសហគ្រិនវ័យក្មេង (YEP) បានរៀបចំសិក្ខាសាលាស្តីពី **“នីតិវិធីក្នុងការចុះបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម និងភាពជាសហគ្រិន”** នៅថ្ងៃទី២២ ខែសីហា ឆ្នាំ ២០២១ សម្រាប់សិស្សគោលដៅនៅក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប សម្រាប់ផ្តល់ចំណេះដឹងថ្មីៗបន្ថែមអំពីភាពជោគជ័យក្នុងការធ្វើអាជីវកម្ម។ មានសិស្សចូលរួមសរុបមានចំនួន ៥៥នាក់ រាប់បញ្ចូលទាំងលោកគ្រូអ្នកគ្រូ និងបុគ្គលិកគម្រោង។

លោកគ្រូ **ជឹង ទូច** ជំនួយការអគ្គនាយិកាទទួលបន្ទុកកិច្ចការគតិយុត្តិ និងទំនាក់ទំនងសាធារណៈនៃក្រុមហ៊ុនសោម៉ោ គ្រុប បានមានប្រសាសន៍ថា **“*ដើម្បីឱ្យក្រុមហ៊ុនមានភាពស្របច្បាប់នឹងយូរអង្វែង ក៏ដូចជាការធ្វើអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងស្វែងរកដៃគូសហការដ៏ល្អ គឺយើងត្រូវការចុះបញ្ជីក្រុមហ៊ុនដើម្បីបញ្ជាក់ពីភាពស្របច្បាប់ ជាពិសេសការពារនូវម៉ាកសញ្ញារបស់ក្រុមហ៊ុន*”**។

លោកស្រី **លឹម វិរិយា** សាស្ត្រាចារ្យធុរកិច្ច និងជាភាគទុនិកនៃក្រុមហ៊ុនអិលអិម លីម៉ាអង្គរហ្វិត បានមានប្រសាសន៍ថា **“*សហគ្រិនគឺជាអ្នកហ៊ានចាប់យកការប្រថុយប្រថាន និងហ៊ានចាប់យកហានិភ័យ។ ហានិភ័យគឺមានន័យថាទទួលយកលទ្ធផលពីរ គឺមួយចានទឹកមួយចានគោក ខាត និងចំណេញស្លាប់ឬរស់។ បើប្អូនៗជាសិស្សចង់ប្រឡូកក្នុងវិស័យជំនួញនៅពេលអាយុខ្ទង់ ២០ ឬ ៣០ឆ្នាំ ប្អូនៗត្រូវវិនិយោគលើចំណេះដឹងពីថ្នាក់ទី១២ នឹងទៅ។ ប្អូនៗត្រូវចាប់យកជំនាញរឹងឱ្យបានរឹងមាំជាមុនសិន ចាំទៅរៀនជំនាញទន់ ព្រោះជំនាញរឹង ប្អូនៗអាចផលិតចេញមកបានឱ្យឃើញជាលទ្ធផល។ ជំនាញរឹងនេះមិនមែនទាល់តែចូលសាកលវិទ្យាល័យនោះទេ ប្អូនៗអាចចូលរួមរៀនវគ្គខ្លីៗនៅតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ក្រសួងអប់រំ យុវជន និងកីឡាបាន។ ដូច្នេះ ប្អូនៗត្រូវកសាងសមត្ថភាពចំណេះដឹង និងបង្កើតទំនាក់ទំនងឱ្យបានទូលំទូលាយមុននឹងឈានដើរចូលក្នុងវិស័យជំនួញ*”**។

លោកគ្រូ **យក់ សោភ័ណ** នាយករងកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប បានបង្ហាញចំណាប់អារម្មណ៍ចំពោះវាគ្មិនទាំងពីរដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចែករំលែកចំណេះដឹងល្អៗ និងបទពិសោធន៍ផ្ទាល់ខ្លួនដល់សិក្ខាកាម។ លោកមានប្រសាសន៍ថា **“*ចំណេះដឹងទាំងនេះពិតជាមានអត្ថប្រយោជន៍សម្រាប់សិស្ស លោកគ្រូអ្នកគ្រូដែលមានបំណងចង់បើកអាជីវកម្ម ក្រុមហ៊ុន និងសហគ្រាស ហើយវានឹងដឹកនាំ និងណែនាំផ្លូវទៅរកការសម្រេចចិត្តឱ្យបានត្រឹមត្រូវមុននឹងប្រឡូកចូលក្នុងវិស័យជំនួញ ព្រមទាំងត្រៀមខ្លួនហ៊ានចាប់យកហានិភ័យ។ មុននឹងចង់បើកក្រុមហ៊ុន ឬអាជីវកម្ម ប្អូនៗត្រូវ កសាងសមត្ថភាព បណ្តាញឱ្យបានរឹងមាំ ត្រូវយល់ដឹងអំពីដំណើរការបើក ដូចវាគ្មិនយើងបានលើកឡើងហើយថា ការបើកអាជីវកម្មមួយស្រួលទេ ប៉ុន្តែការបិទទៅវិញទើបជាការលំបាក។ ដូច្នេះ មុននឹងសម្រេចចិត្តបើកអាជីវកម្ម ប្អូនៗត្រូវពិចារណាឱ្យបានល្អ ដឹងពីនីតិវិធីក្នុងការបើកអាជីវកម្ម ត្រូវមានទស្សនវិស័យឱ្យបានវែងឆ្ងាយ និងមានផែនការអាជីវកម្មឱ្យបានច្បាស់លាស់ នោះវានឹងដំណើការបានយូរអង្វែងតទៅ*”**។



*លោកស្រី លឹម វិរិយា សាស្ត្រាចារ្យធុរកិច្ច និងជាភាគទុនិកនៃក្រុមហ៊ុនអិលអិម លីម៉ាអង្គរហ្វិត*

សិក្ខាសាលានេះបានផ្តល់ចំណេះដឹងល្អៗច្រើនបន្ថែមទៅលើនិតិវិធីក្នុងការចុះបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម និងភាពជាសហគ្រិន។ ដូច្នេះ មុននឹងចង់ប្រឡូកចូលក្នុងវិស័យជំនួញ សិក្ខាកាមទាំងអស់ត្រូវអភិវឌ្ឍន៍ចំណេះដឹង និងសមត្ថភាពឱ្យបានរឹងមាំជាមុនសិន ដើម្បីត្រៀមខ្លួនប្រឈមមុខនឹងហានិភ័យដែលនឹងកើតមានឡើងដោយយថាហេតុ៕

# ១០

# កម្មវិធីឆ្លើយតបនឹង
# វិស័យអប់រំក្នុងបរិបទ
# ជំងឺកូវីដ-១៩

## Covid19 Response & Recovery Programming



# ជំនួយស្បៀងអាហារធ្វើឱ្យកុមារក្រីក្រមានកំលាំងចិត្តខិតខំសិក្សាបន្ត




*គណៈអធិបតីជានាយក នាយករង និងតំណាងអាជ្ញាធរមូលដ្ឋានក្នុងកម្មវិធីចែកស្បៀងអាហារនៅសាលាបឋមសិក្សាពុកក្នុងខេត្តក្រចេះ*



*ទិដ្ឋភាពឪពុកម្តាយ និងកូនមកទទួលស្បៀងអាហារនៅក្នុងសាលាបឋមសិក្សាច្រករំដេង ខេត្តត្បូងឃ្មុំ។*



*កុមារីងាយរងគ្រោះនៅសាលាបឋមសិក្សាហាន់ជ័យក្នុងខេត្តកំពង់ចាមទទួលបានស្បៀងអាហារពីគម្រោង HCC។*

នៅដើមខែមិថុនា ចាប់ពីថ្ងៃទី០២-០៨ ឆ្នាំ២០២១ គម្រោងកុមារកម្ពុជារីករាយ (HCC) បានរៀបចំកម្មវិធីចែកស្បៀងអាហារដល់គ្រួសារកុមារក្រីក្រនៅក្នុងសាលាគោលដៅចំនួន ៤០ ក្នុងខេត្តចំនួន៥ គឺ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ រតនៈគិរី និងសៀមរាប។ គម្រោងនេះគាំទ្រហិរញ្ញប្បទានពីមូលនិធិ គីនឆាន ស្ទីហ្វទុង និងប្រតិបត្តិការដោយអង្គការខេប។

កម្មវិធីចែកស្បៀងអាហារនេះមានគោលបំណងជួយសង្គ្រោះ និងឆ្លើយតបបន្ទាន់ដល់គ្រួសារកុមារគោលដៅដែលកំពុងជួបការលំបាកក្នុងអំឡុងពេលឆ្លងរីករាលដាលជំងឺកូវីដ-១៩។ ក្នុងកម្មវិធីនេះមានអ្នកចូលរួមជាគ្រួសារក្រីក្រ នាយកសាលា គ្រូបង្រៀន មេភូមិ ក្រុមប្រឹក្សាឃុំ តំណាងការិយាល័យអប់រំ យុវជន និងកីឡាស្រុក តំណាងសាលាស្រុក តំណាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងអ្នកពាក់ព័ន្ធដទៃទៀត។ គ្រួសារកុមារក្រីក្រចំនួន ១១៥៦ ទទួលបានស្បៀងអាហារពីគម្រោង ដោយក្នុងមួយគ្រួសារទទួលបានអង្ករ ៣០គីឡូ ទឹកត្រី ១យួរ ទឹកស៊ីអ៊ីវ ១យួរ ប្រេងឆា ១ដប អំបិល ១កញ្ចប់ មី ១កេស គ្រាប់ពូជត្រកួនកន្លះគីឡូ និងគ្រាប់ស្ពៃ ១ខាំ ព្រមទាំងត្រីខ ១យួរ។

ជំនួយនេះគឺជាការចូលរួមចំណែកសម្រួលបន្ទុកក្នុងគ្រួសារបានមួយផ្នែកក្នុងអំឡុងពេលដ៏លំបាកនេះ។ ការរក្សាគម្លាត ១ម៉ែត្រកន្លះពីគ្នាដោយគោរពតាមគោលការណ៍ណែនាំរដ្ឋាភិបាល និងក្រសួងសុខាភិបាលសម្រាប់អ្នកចូលរួមទាំងអស់ត្រូវបានអនុវត្តដោយយកចិត្តទុកដាក់បំផុត៕

**អ្នកស្រី ធឹម ឈុនលី** ជាអាណាព្យាបាលសិស្ស ពេជ្រពិសី រៀននៅមត្តេយ្យសហគមន៍ក្រូចសើច ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានបង្ហាញការចាប់អារម្មណ៍នៅក្នុងកម្មវិធីចែកស្បៀងនេះថា ***“វាពិតជាមានតម្លៃសម្រាប់ពួកយើងដែលកំពុងរងផលប៉ះពាល់ដោយសារការឆ្លងរីករាលជំងឺកូវីដ-១៩នេះ ធ្វើឱ្យការរកស៊ីរបស់ពួកយើងជួបការលំបាក។ ទោះបីស្ថិតក្នុងស្ថានភាពលំបាកយ៉ាងណាក៏ដោយនាងខ្ញុំនឹងខិតខំរកស៊ីដើម្បីបញ្ជូនកូនទៅសាលារៀន និងគាំទ្រការរៀនសូត្រទាំងនៅផ្ទះ និងនៅសាលា។ នាងខ្ញុំសូមថ្លែងអំណរអរគុណចំពោះទឹកចិត្តសប្បុរធម៌នេះដល់អង្គ*** (អានបន្តទំព័រ ៥១...)

( ...តពីទំព័រ ៥០ ) *ការកុមារកម្ពុជារីករាយ អាជ្ញាធរមូលដ្ឋាន និងគណៈគ្រប់គ្រងសាលារៀនដែលបានរៀបចំកម្មវិធីនេះឡើង"*។

**លោក ទូន ផល្លា** ជាប្រធានការិយាល័យអប់រំ ស្រុកសំបូរបានមានប្រសាសន៍ថា **"***តាំងពីសាលារៀនបានសហការយ៉ាងល្អជាមួយគម្រោងកុមារកម្ពុជារីករាយមក គឺគម្រោងតែងតែយកចិត្តទុកជួយអភិវឌ្ឍន៍ដល់សាលារៀនគោលដៅ ជាពិសេសគម្រោងបានធ្វើកម្មវិធីចែកស្បៀងអាហារនេះចំពេលដែលជំងឺកូវីដ-១៩កំពុងឆ្លងរីករាលដាលជាសកល។ នេះជាផ្នែកមួយសំខាន់ក្នុងការជួយសម្រាលបន្ទុកដល់គ្រួសារសិស្សដែលខ្វះខាតស្បៀងអាហារសម្រាប់ការបរិភោគ។ ខ្ញុំសំណូមពរដល់ក្រុមគ្រួសារក្រីក្រដែលទទួលបានស្បៀងអាហារនៅថ្ងៃនេះ គឺ ១) ចូលរួមគាំទ្រសកម្មភាពគម្រោង និងសកម្មភាពសាលារៀន ២) គាំទ្រការសិក្សារបស់កូនៗទាំងនៅសាលា និងនៅផ្ទះ ៣) បន្តអនុវត្តន៍តាមគោលការណ៍របស់ក្រសួងសុខាភិបាល ៣កុំ ៣ការពារ និង ៤) យកគ្រាប់ពូជដំណាំ (ស្ពៃ និងត្រកួន) ទៅដាំផ្ទះបានផលទាំងអស់គ្នា*"។


អាណាព្យាបាលបានបង្ហាញអារម្មណ៍រីករាយ និងបានថ្លែងអំណរអរគុណដល់គម្រោងដែលបានផ្តល់ស្បៀងអាហារនេះដល់ពួកគាត់នៅសាលាបឋមសិក្សាមាក់កណ្តាល។

គម្រោងកុមារកម្ពុជារីករាយបានយកចិត្តយ៉ាងសំខាន់លើការគាំទ្រដល់ការអប់រំកុមារនៅតាមសហគមន៍ជនបទ និងដាច់ស្រយាលក្នុងតំបន់គោលដៅ ដោយធ្វើសហការយ៉ាងល្អជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងបេសកកម្មធ្វើយ៉ាងណាជួយជំរុញឱ្យកុមារទទួលបានការសិក្សាអប់រំពីចម្ងាយ និងផ្ទាល់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងគោលបំណងចូលរួមអភិវឌ្ឍន៍ធនធានមនុស្សជាមួយក្រសួងអប់រំ យុវជន និងកីឡា ធ្វើឱ្យវិស័យអប់រំនៅកម្ពុជាមានការរីកចម្រើន និងឆ្លើយតបនឹងតម្រូវការជាក់ស្តែង៕


សកម្មភាពវាស់កម្តៅ បាញ់អាកុលជូនឪពុកម្តាយ និងអាណាព្យាបាលសិស្សមុនពេលចូលរួមទទួលយកស្បៀងអាហារនៅបឋមសិក្សាកសាង។

# កម្មវិធីចែកស្បៀងអាហារជួយដោះបញ្ហារបស់កុមារងាយរងគ្រោះ

នៅពាក់កណ្តាល ខែមិថុនា ឆ្នាំ២០២១ គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (រីកIV/ REACH IV) ក្រោមជំនួយហិរញ្ញប្បទានពីអង្គការវើលវីលបានរៀបចំចែកស្បៀងអាហារជូនដល់កុមារងាយរងគ្រោះចំនួន ៥២១នាក់ ដែលកំពុងសិក្សានៅសាលាបឋមសិក្សាគោលដៅចំនួន ៤១ ក្នុងខេត្តស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ និងព្រៃវែង។

កម្មវិធីនេះមានគោលបំណងចូលរួមជួយសម្រាលបន្ទុកដល់គ្រួសារកុមារងាយគ្រោះ ដែលកំពុងចួបប្រទះការលំបាកអំឡុងពេលសាលារៀនបិទទ្វារដោយការឆ្លងរីករាលដាលជំងឺកូវីដ-១៩។ គម្រោងបានធ្វើការសហការយ៉ាងល្អជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក អាជ្ញាធរមូលដ្ឋាន លោកមេភូមិ គណៈកម្មការទ្រទ្រង់សាលា តំណាងក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ។

កុមារម្នាក់ៗទទួលបានអង្ករ ២០គីឡូ ទឹកត្រី ១យួរ មីជាតិ ១កេះ ទឹកស៊ីអ៊ីវ ១យួរ ត្រីខកំប៉ុង ១យួរ និងប្រេងឆាចំណុះ ១លីត្រ ១ដប។ ជំនួយនេះបានជួយដោះបន្ទុករបស់គ្រួសារកុមារងាយរងគ្រោះក្នុងអំឡុងពេលដ៏លំបាកនេះ។

**លោក ប៊ូ សំអូន** ជាអភិបាលរងស្រុកស្វាយជ្រំ បានមានប្រសាសន៍ណែនាំដល់កូនៗក្មួយៗ ឪពុកម្តាយ និងអាណាព្យាបាលថា ***“សូមឪពុកម្តាយ និងអាណាព្យាបាលទាំងអស់រក្សាអនាម័យខ្លួនប្រាណ និងអនាម័យហូបចុក ជាពិសេសជួយបង្រៀនកូនៗនៅផ្ទះអំឡុងពេលសាលារៀនកំពុងបិទទ្វារ។ សូមតាមដានការសិក្សាកូន និងកិច្ចការផ្ទះដែលគ្រូបានផ្ញើឱ្យកុមារធ្វើនៅផ្ទះ និងផ្ញើមកគ្រូតាមក្រុមរយៈ Telegram វិញ”។***

គម្រោងរីក IV បន្តផ្តោតការយកចិត្តទុកដាក់លើកកម្ពស់ការចូលរៀន គុណភាព និងការគ្រប់គ្រងការអប់រំដែលមានសកម្មភាពសំខាន់ៗ ដូចជា ការពង្រឹងជំនាញអាន ការពង្រឹងថ្នាក់មត្តេយ្យ ការពង្រឹងការការពារកុមារ ការពង្រឹងបរិស្ថានសិក្សា និងការចូលរួមពីសហគមន៍។

កម្មវិធីចែកស្បៀងអាហារនេះបានប្រព្រឹត្តិទៅដោយរលូន និងទទួលបានការសាទរពីអ្នកចូលរួមទាំងអស់គ្នា។ ពួកគាត់បានថ្លែងអំណរគុណដល់ម្ចាស់ជំនួយ (អង្គការវើលវីល) តាមរយៈការសម្របសម្រួលពីអង្គការ ខេប និងសូមឱ្យគម្រោងបន្តជួយបន្ថែមទៀត៕



*ពិធីចែកស្បៀងអាហារនៅសាលាបឋមសិក្សាគ្រួសដល់កុមារងាយរងគ្រោះចំនួន១០នាក់ ដោយមានការសហការយ៉ាងល្អពីអាជ្ញាធរមូលដ្ឋាន។*



*កុមារងាយរងគ្រោះនៅសាលាបឋមសិក្សាឯកលីផលទទួលបានជំនួយស្បៀងអាហារពីគម្រោង។*



*កុមារងាយរងគ្រោះនៅសាលាបឋមសិក្សាភូមិថ្មីមកទទួលស្បៀងអាហារពីគម្រោង។*

# ការពិគ្រោះយោបល់ ស្ដីពី ការប្រើប្រាស់កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមសម្រាប់ដាក់បញ្ចូលទៅក្នុងការបង្រៀន និងរៀន



សកម្មភាពប្រជុំកម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ-១៩ ជាមួយប្រធានគម្រោងដទៃៗទៀត។

នៅថ្ងៃទី២២-២៣ ខែមិថុនា ឆ្នាំ២០២១ កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ-១៩ (CERRP) បានរៀបចំកិច្ចប្រជុំមួយដើម្បីពិគ្រោះយោបល់ជាមួយប្រធានគម្រោងដទៃៗទៀតរបស់អង្គការ ខេប អំពីការប្រើប្រាស់កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមសម្រាប់ដាក់បញ្ចូលទៅក្នុងការបង្រៀន និងរៀនតាមភូមិ ឬសហគមន៍នានានៅទូទាំងប្រទេសកម្ពុជា។ ការប្រជុំនេះមានសមាសភាពចូលរួមសរុបចំនួន ១៤នាក់ នៅការិយាល័យកណ្តាលរបស់អង្គការ ខេប ក្នុងក្រុងកំពង់ចាម។ ការប្រជុំនេះមានគោលបំណងណែនាំអំពីកញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែម (ចាប់ពីថ្នាក់ទី១ ដល់ទី៩) និងបន្តជំរុញសកម្មភាពរៀនពីចម្ងាយទៅដល់គម្រោងផ្សេងៗទៀត។

កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមនេះត្រូវបានបង្កើតដោយកម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំនៅកម្ពុជាក្នុងបរិបទជំងឺកូវីដ-១៩ គាំទ្រដោយភាពជាដៃគូសកលដើម្បីការអប់រំ (CERRP-GEP ) ដែលជាកម្មវិធីថ្មីមួយទៀតរបស់អង្គការ ខេប ហើយទទួលបានជំនួយហិរញ្ញប្បទានពីអង្គការយូនីសេហ្វ (UNICEF)៕

# ការផ្តល់សម្ភារៈសិក្សាបន្ថែមដល់កុមារនៅសាលារៀនគោលដៅ

ក្នុងខែមិថុនា ឆ្នាំ២០២១ កម្មវិធីសាលាមត្តេយ្យរបស់គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRACIII) បានផ្តល់ល្បែងសិក្សា និងសៀវភៅមត្តេយ្យសិក្សាដែលមានរូបភាពបន្ថែមសម្រាប់កុមារខ្ចីទៅប្រើប្រាស់នៅផ្ទះ និងបានចែកជូនសៀវភៅម៉ុនតេស្សូរីសម្រាប់ឱ្យកុមារធ្វើកិច្ចការនៅតាមផ្ទះមានចំនួន ២២៨ឈុត និងគូល័រផាត់ពណ៌ចំនួន ២២៨ប្រអប់សម្រាប់កុមារគូរ ឬផាត់ពណ៌លើកិច្ចការក្នុងសៀវភៅ សន្លឹកកិច្ចការ និងសម្ភារៈសិក្សាមួយចំនួនទៀតដល់សាលារៀនគោលដៅចំនួន៦ក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំក្នុងបរិបទកូវីដ-១៩។ គម្រោងនៅតែបន្តគាំទ្រសកម្មភាពជួយអន្តរាគមន៍ដល់សាលា ជាសិក្ខាសាលា ការប្រជុំ ការផ្តល់បច្ចេកទេសបង្រៀនដើម្បីធ្វើយ៉ាងណាឱ្យសិស្សអាចសិក្សាបានយ៉ាងស្រួលនៅតាមផ្ទះ ទោះបីស្ថិតក្នុងស្ថានភាពសាលារៀនកំពុងបិទទ្វារក៏ដោយ៕



សៀវភៅម៉ុនតេស្សូរីសម្រាប់ឱ្យកុមារសរសេរ និងផាត់ពណ៌លើរូបភាព។



# ព្រឹត្តិការណ៍ ចំណេះដឹង កំណាព្យ និងការសិក្សាស្រាវជ្រាវផ្សេងៗ

*"ការអភិវឌ្ឍតាមរយៈបណ្ដាញ និងនៅថ្នាក់មូលដ្ឋាន"។*

# Events, Knowledge, Poems, and Other Researches

*"Development through Networking and Outreach."*



# អង្គការ ខេប ចូលរួមថវិកាជួយគ្រួសាររងគ្រោះដោយសារភ្លើងឆេះផ្ទះ

អង្គការ ខេប និងសហការី ព្រមទាំងលោកវរសេនីយ៍ទោ អ៊ឹង ប៊ុន ជាអធិការនគរបាលក្រុងកំពង់ចាម បានផ្តល់ជំនួយថវិកាមូលនិធិចំនួន ២.៥០០.០០០ រៀល ជួយដល់សិស្សឈ្មោះ ដួងច័ន្ទ ភេទស្រី អាយុ១៤ឆ្នាំ រស់នៅជាមួយម្តាយជាស្ត្រីមេម៉ាយ ដែលរងគ្រោះដោយសារភ្លើងឆេះផ្ទះកាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ ស្ថិតក្នុងភូមិកាឡៃ ២ ឃុំកាឡៃ ស្រុកអូរជុំ ខេត្តរតនគិរី។ កុមារី ដួងច័ន្ទ កំពុងសិក្សានៅថ្នាក់ទី៦ នៅសាលាបឋមសិក្សា កាឡៃ ដែលជាសាលាគោលដៅរបស់គម្រោងកុមារកម្ពុជារីករាយ (HCC)។ ជំនួយថវិកានេះនឹងបានចូលរួមចំណែកជួយសម្រួលដោះបន្ទុកគ្រួសាររបស់កុមារីរងគ្រោះ។ ម្តាយកុមារី ដួងច័ន្ទ ក្នុងទឹកមុខមានក្តីសង្ឃឹម បានសម្តែងនូវសេចក្តីអំណរគុណចំពោះអង្គការ ខេប និងបុគ្គលិក ជាពិសេសលោកវរសេនីយ៍ទោ អ៊ឹង ប៊ុន ដែលបានផ្តល់ជំនួយជួយដល់គ្រួសាររបស់គាត់ដែលបានរងគ្រោះដោយសារភ្លើងឆេះផ្ទះ៕



*តំណាងអង្គការ ខេប និងអាជ្ញាធរមូលដ្ឋានបាននាំជំនួយថវិកាចំនួន ២.៥០០.០០០ រៀលជូនដល់គ្រួសារកុមារីរងគ្រោះផ្ទាល់ដៃ។*

---

# កុមារ ម៉ាន់ត្រា បានជួបរងគ្រោះថ្នាក់ចរាចរណ៍ក្នុងស្រុកអូរជុំ

អង្គការ ខេប និងសហការី ព្រមទាំងលោកវរសេនីយ៍ទោ. អ៊ឹង ប៊ុន ជាអធិការនគរបាលក្រុងកំពង់ចាម បានផ្តល់ថវិកាមូលនិធិចំនួន ៣.០០០.០០០ រៀល ជួយដល់កុមារឈ្មោះ ម៉ាន់ត្រា ភេទប្រុស អាយុ ៦ឆ្នាំ រៀននៅថ្នាក់មត្តេយ្យកម្រិតខ្ពស់នៅសាលាបឋមសិក្សា កាឡៃ ដែលជាសាលាគោលដៅរបស់គម្រោងកុមារកម្ពុជារីករាយ (HCC) បានជួបគ្រោះថ្នាក់ចរាចរណ៍កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០២១ នៅភូមិកាឡៃ ១ ឃុំកាឡៃ ស្រុកអូរជុំ ខេត្តរតនគិរី ដោយសាររត់តាមម្តាយឆ្លងថ្នល់បណ្តាលឱ្យបាក់ភ្លៅទាំងសងខាង និងត្រូវក្បាលយ៉ាងធ្ងន់ធ្ងរ។ ថវិកាជំនួយនេះនឹងជួយសម្រួលបន្ទុកបានខ្លះដល់គ្រួសារកុមាររងគ្រោះ។



*កុមារម៉ាន់ត្រាកំពុងទទួលបានការព្យាបាល*

ឪពុកម្តាយរបស់កុមាររងគ្រោះបានថ្លែងនូវអំណរគុណចំពោះអង្គការ ខេប និងសហការី ព្រមទាំងអធិការក្រុងកំពង់ចាមចំពោះទឹកចិត្តដ៏ល្អប្រពៃជួយដល់គ្រួសាររបស់ពួកគាត់ដែលកំពុងជួបការខ្វះអំឡុងពេលជំងឺកូវីដ-១៩ កំពុងរីករាលដាលរីករាលដាល៕

# ការធ្វើផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេល៥ឆ្នាំ ២០២០-២០២៤

នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ក្រុមថ្នាក់គ្រប់គ្រងជាន់ខ្ពស់របស់អង្គការ ខេប និងប្រធានគម្រោងសំខាន់ៗបានរៀបចំការប្រជុំលើកទីបី ស្តីពី **“ការធ្វើផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេល៥ឆ្នាំ ២០២០-២០២៤”** ដើម្បីបង្កើនឱកាសសម្រាប់ការអភិវឌ្ឍអង្គភាព និងត្រួតពិនិត្យទៅលើផែនការយុទ្ធសាស្ត្រឆ្នាំចាស់ ២០១៤-២០១៩ និងអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រឆ្នាំថ្មី។

បន្ទាប់ពីបានពិភាក្សាយ៉ាងសកម្មលើផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ កន្លងមកស្តីពី ធនធានមនុស្ស ការគ្រប់គ្រងស្ថាប័ន គោលនយោបាយរបស់អង្គភាព បញ្ហាប្រឈមផ្សេងៗ លទ្ធផលពីការសិក្សាស្រាវជ្រាវរបស់ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) បានរកឃើញថា សិស្សនៅតែមានការបោះបង់ចោលការសិក្សា និងមិនទាន់បានចុះឈ្មោះចូលរៀនគ្រប់គ្នានៅឡើយ។ កិច្ចប្រជុំស្តីពីផែនការយុទ្ធសាស្ត្រនេះបានស្នើឡើងនូវទិសដៅថ្មីៗជាច្រើនសម្រាប់បន្តលើកកម្ពស់ការអប់រំសម្រាប់កុមារ និងយុវជន ដែលត្រូវបានចាត់ថ្នាក់ចំនួន ១២ ចំណុចដូចខាងក្រោម៖ ១) ការអប់រំស្ទែម (STEM: វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) ២) ការសិក្សាតាមអេឡិចត្រូនិច (E-Learning)/ការសិក្សាតាមអនឡាញ ឬបែបនិម្មិត។ ៣) ការអប់រំពីចម្ងាយ។ ៤) កម្មវិធីអប់រំមត្តេយ្យសិក្សាជំនាន់ថ្មី។ ៥) បន្តការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន (ឯកទេសប្រឹក្សាគរុកោសល្យ)។ ៦) កម្មវិធីអប់រំជំនាញទន់/សហគ្រិនភាព។ ៧) ការអភិវឌ្ឍនិងការគាំពារកុមារតូច (មានអាយុពី ១០០ថ្ងៃដល់អាយុ៤ឆ្នាំ)។ ៨) ការពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មី។ ៩) សាលាគរុកោសល្យជំនាន់ថ្មី។ ១០) កម្មវិធីសិក្សាស្រាវជ្រាវអប់រំតាមរយៈមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC)។ ១១) ការពង្រឹងកម្មវិធីអប់រំបរិយាប័ន្ន។ ១២) ការសុសសាយនៅក្នុងថ្នាក់ជាតិ និងការតស៊ូមតិផ្នែកប្រតិបត្តិល្អ មូលដ្ឋានគ្រឹះគ្រប់គ្រងសាលារៀន បញ្ហាយុវជនក្រៅសាលារៀន ការផ្តល់សេវាកម្មវិធីប្រឹក្សាអាជីព និងបច្ចេកទេស។

ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ អង្គការខេប នសម្រេចសមិទ្ធផលផ្នែកការងារអប់រំច្រើន ជាពិសេសបានពង្រីកខ្លួនកាន់តែធំ និងមានទំនួលខុសត្រូវខ្ពស់ក្នុងការធ្វើឱ្យកុមារ និងយុវជនទទួលបាននូវជម្រើសជីវិតដ៏ល្អបំផុតផ្អែកលើសក្តានុពលរបស់ពួកគេដែលជាលទ្ធផលនៃការអប់រំល្អ និងការផ្តល់អំណាចដល់កុមារ ព្រមទាំងយុវជនងាយរងគ្រោះឱ្យទទួលបាននូវសិទ្ធិផ្ទាល់ខ្លួនក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីសាស្ត្រច្នៃប្រឌិតថ្មីៗ៕




*ក្រុមថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងប្រធានគម្រោងសំខាន់ៗរបស់អង្គការ ខេប បានរៀបចំប្រជុំធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេល ៥ឆ្នាំ ២០២០-២០២៤ បន្តទៀត។*

# កុំចាំខ្ចីស្មាគេផ្អែក


រូបភាព #Pinterest

កុំបង្រៀនខ្លួនឯងឱ្យក្លាយជាមនុស្សដែលចាំតែផ្អែកស្មាលើគេព្រោះបើថ្ងៃណាមួយគ្មានគេ នោះយើងនឹងវេទនា។ យើងត្រូវចេះរស់នៅដោយយកខ្លួនជាទីពឹងផ្អែក ទើបវេលាក្រោយយើងមិនសូវនឿយចិត្ត ព្រោះហេតុពឹងរកគេមិនបាន។ តាំងពីតូចក្រូចឆ្មារមក យើងរស់ដោយពឹងលើកម្លាំងរបស់ឪពុកម្តាយទាំងស្រុងក្នុងការចិញ្ចឹមបីបាច់រក្សា ទម្រាំដល់យើងធំដឹងក្តី ដើរបាន រត់បាន និយាយបាន និងអាចធ្វើអ្វីៗដោយខ្លួនឯង។ ប៉ុន្តែដល់ពេលយើងធំអាត្មា ពេញរូបពេញរាងកាលណា ពេលយើងចេញពីសង្គមគ្រួសារទៅចូលក្នុងសង្គមខាងក្រៅ យើងត្រូវរៀនរស់ដោយពឹងលើខ្លួនឯង។ ជាបុរសក្តី ឬជាស្ត្រីក្តី ប្រសិនបើក្នុងថ្ងៃអនាគតយើងបានជួបគូជីវិតល្អម្នាក់ នោះចាត់ទុកថា ជាសំណាងរបស់យើងក្នុងជីវិតអាពាហ៍ពិពាហ៍ ប៉ុន្តែក្រៅពីដេកស្រមៃចង់បានមនុស្សល្អមករួមដំណើរជីវិតជាមួយ យើងត្រូវកសាងដុសខាត់ខ្លួនឯងឱ្យបានដើរក្នុងគន្លងជាមនុស្សល្អដូចជាមនុស្សដែលយើងចង់បាននៅក្នុងក្តីស្រមៃរបស់យើងជាមុនសិន។

ថ្វីបើសម្ផស្សដ៏ផូរផង់របស់ស្ត្រីអាចទាក់ចិត្តបុរសឱ្យធ្លាក់ក្នុងសេចក្តីស្នេហាលើរូបនាងបាន ប៉ុន្តែអ្វីដែលរក្សាវត្តមានបុរសនោះបានយូរអង្វែងនៅក្នុងជីវិតរបស់នាងគឺចរិយាសម្បត្តិ ចរិតឫកពារ មារយាទ សមត្ថភាព ចំណេះដឹង ចិត្តគំនិតខាងក្នុងរបស់នាងឯណោះទៅវិញទេ។ ដ្បិតថាបុរសសង្ហា មានសេចក្តីក្លាហានអង់អាច អាចទាក់ចិត្តនារីឱ្យលង់ស្រឡាញ់បាន ប៉ុន្តែអ្វីដែលធ្វើឱ្យនាងផ្តល់ការគោរព កោតក្រែង និងមានភក្តីភាពជាមួយ គឺអត្តចរិតដ៏ស្ញប់ស្ងាត់របស់បុរសនោះទៅវិញទេ ហើយបុរសដែលអាចរក្សាភាពស្ញប់ស្ងៀម តែមានចិត្តមោះមុតក្លាហានគឺមានតែបុរសអ្នកមានចំណេះដឹង ហើយស្រោបដោយគុណធម៌ខ្ពង់ខ្ពស់តែប៉ុណ្ណោះ៕

*(អត្ថបទដកស្រង់ចេញពីសៀវភៅដើរចេញពីអតីតកាល)*

# ជំនួបជាមួយ លោក W. Partick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក

ក្នុងខែមិថុនា ឆ្នាំ២០២១ លោក W. Partick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅប្រទេសកម្ពុជា បានឆ្លៀតពេលវេលាដ៏មានតម្លៃជួបសំណេះសំណាលជាមួយអតីតបេក្ខជនដែលធ្លាប់បានចូលរួមកម្មវិធីផ្លាស់ប្តូរការសិក្សាភាពជាអ្នកដឹកនាំទៅសហរដ្ឋអាមេរិក ក្រោមការរៀបចំកម្មវិធីដោយស្ថានទូតអាមេរិក។

លោកស្រី ហ៊ឹម ម៉ារី ជាប្រធានសម្របសម្រួលកម្មវិធីអប់រំបរិយាប័ន្ន និងគម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (SEEK) របស់អង្គការ ខេប និងបុគ្គលិកអប់រំដទៃទៀតបានជជែកពិភាក្សាជាមួយលោក W.Partick Murphy អំពីវប្បធម៌ បរិបទរស់នៅរបស់ប្រជាជនកម្ពុជា និងសកម្មភាពការងារអប់រំក្នុងខេត្តកំពង់ចាម។

លោកស្រីបានមានប្រសាសន៍បានថា "*កិច្ចជជែកពិភាក្សានេះពិតជាមានផ្លែផ្កា និងខ្លឹមសារណាស់ ជាពិសេសការចែករំលែកបទពិសោធន៍ជាច្រើនដែលអង្គការ ខេប កំពុងតែប្រតិបត្តិក្នុងពេលបច្ចុប្បន្ន ដើម្បីឱ្យវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈល្អប្រសើរប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ លោអង្គការ ខេប គឺជាអង្គភាពមួយដែលបានជួយលើកកម្ពស់វិស័យអប់រំចាប់ពីកម្រិតមត្តេយ្យសិក្សារហូតដល់កម្រិតឧត្តមសិក្សា។ ម៉្យាងវិញទៀត ខេបក៏ធ្លាប់ទទួលបានកញ្ចប់ថវិកាពី USAID និង FHI ក្នុងការជួយគាំទ្រសាលារៀន អ្នកគ្រូលោកគ្រូ និងសិស្សជាច្រើនរយនាក់នៅក្នុងវិស័យអប់រំ។*"

លោកឯកអគ្គរដ្ឋទូត W. Partick Murphy បានបង្ហាញការពេញចិត្តយ៉ាងខ្លាំងចំពោះការខិតខំប្រឹងប្រែងធ្វើការរបស់អតីតបេក្ខជនម្នាក់ៗ ដែលបានជួយពង្រឹងទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជា៕


*លោកឯកអគ្គរដ្ឋទូត W. Partick Murphy និងអ្នកស្រី ហ៊ឹម ម៉ារី បានពិភាក្សាអំពីវប្បធម៌ និងបរិបទរស់នៅរបស់ប្រជាជនក្នុងខេត្តកំពង់ចាម។*

# រឿងតម្លៃនៃការអាន

## (បទពាក្យ៧)

១. លើកដៃប្រណមផ្ងង់សម្ពារៈ ឱនអង្គវន្ទាគ្រូអាចារ្យ
សុំចូលចាត់ចែងចារកថា កំណាព្យអក្ខរាជារឿងខ្លី។
២. នេះនឹងថ្លាថ្លែងចែងសេចក្តី ជីវិតក្មេងស្រីមិនសូវស្ដី
នាងមានឈ្មោះថាសុមាតី វ័យវៃឆ្លាតពិសីគួរសប្បាយ។
៣. ប៉ុន្តែគ្រួសារទ្ទននាងខ្សត់ រស់នៅកំសត់កំព្រាម្ដាយ
គ្មានទីលំនឹងមិនសប្បាយ ខ្វះម្ហូបខ្វះបាយខ្វះក្ដីសុខ។
៤. រស់នៅមណ្ឌលក្មេងកំព្រា ក្នុងចិត្តវេទនាមិនស្រណុក
ភាពអវិជ្ជាចង់អុកឡុក អង្គុយសំកុកគិតឡើងយូរ។
៥. ក្នុងចិត្តចង់រៀនមានប្រាជ្ញា សុំរៀនភាសាជាមួយគ្រូ
នាងសន្យាថានឹងតស៊ូ មិនឱ្យលោកគ្រូខកចិន្តា។
៦. ដោយចិត្តចង់បានចំណេះដឹង នាងខំនាងប្រឹងនាងឧស្សាហ៍
មិនដែលត្អែរត្អូញរាល់កិច្ចការ ធ្វើសព្វប្រការដែលគ្រូចែង។
៧. រៀនសូត្ររៀនអានទាំងសំណេរ កំណាព្យកាព្យកេរក៏រៀនស្វែង
រៀនកត់ចំណាំ និងតាក់តែង មិនឱ្យខ្វះខ្វែងភ្លាវខ្លឹមសារ។
៨. មិនយូរប៉ុន្មានក្នុងសកល កើតក្តីកង្វល់ពេញលោកា
កូវីដមេរោគនាំបញ្ហា គ្រប់ៗសាលាត្រូវបិទទ្វារ។
៩. លោកគ្រូអ្នកគ្រូក៏ប្រឹងប្រែង លោកខំស្វះស្វែងប្រជុំគ្នា
ធ្វើវីដេអូសមសោភា ឱ្យសិស្សសួនភ្នាបានសិក្សា។
១០.ចំពោះស្រីសួនសុមាតី នួននាងពិសីខំខ្លាំងក្លា
ទោះខកខានរៀនក្នុងសាលា នាងស្វ័យសិក្សាគ្មានខកខាន។
១១.អានឥតទំនេរទាំងថ្ងៃយប់ អានក្នុងបន្ទប់ទោះលាងចាន
ស្រាវជ្រាវបន្ថែមប្រុងប្រៀបប្រាណ តាមដោយលំអានអ៊ិនធឺណិត។
១២.អានហើយអានទៀតឥតមានខ្ជិល ដក់អស់មន្ទិលមិនចេះឆ្អែត
កំណាព្យរឿងរ៉ាវក្នុងកាសែត ព័ត៌មានទាន់ហេតុចេះចាំស្ទាត់។
១៣.បំណងប្រាថ្នាសម្រេចបាន នាងខំរុញច្រានប្រែមុខមាត់
សេចក្ដីល្ងង់ល្ងិតខ្ចាត់ខ្ចាយព្រាត់ ឧបសគ្គឃាំងឃាត់លែងរានរុក។
១៤.នាងជាក្មេងស្រីចូលចិត្តអាន រំដោះឱ្យបានស៊កគ្រលុក
ឆ្ងល់ត្រង់ណាសួរគ្រូមិនទុក ពុទ្ធិស្រគុកកើតក្នុងប្រាណ។
១៥.អានច្រើនចេះច្រើនកើនចំណេះ គ្មានអ្នកមកបេះប្រឡេះបាន
ធ្លាប់លិចលង់ទឹកប្រែសុខសាន្ត ជីវិតប្រៀបបានដូចឡើងគោក។
១៦.សៀវភៅគឺជាមគ្គុទេសក៍ ជាបរមេស្វកំណត់ជោគ
ជាឱសថទិព្វព្យាបាលរោគ កើនផលកើនភោគពណ្ណរាយ។
១៧.ដោយសារចំណេះនាងខំរៀន ប្រិតប្រៀនរៀនរៀនជាសម្ដាយ
យកទៅតាមខ្លួនមិនរាយមាយ ត្រួសត្រាយវេចស្ពាយផុតកំព្រា។
១៨. សុមាតីស្រីជ័យលាភី រៀនទីដប់ពីរក៏ក្លាយជា
ម្ចាស់ពានលេខមួយនៃទិវា អំណានមាគ៌ាត្រួសត្រាយផ្លូវ។
១៩. ម្ចាស់ពានកំណាព្យកាព្យរឿងខ្លី កើតមកពីស្រីដើរផ្លូវត្រូវ
ខំអានតស៊ូគ្រប់រដូវ ផលហុចឥឡូវព្រោះអំណាន។
២០. ក្រោយមកក៏ក្លាយជាកវី នៅលើទឹកដីខេមរាស្ថាន
មានឈ្មោះល្បាញល្បីសុខក្សេមក្សាន្ត សាងកេរ្តិ៍ឈ្មោះបានផុតវេទនា។
២១.ចំណេះជំនាញជាមង្គល ស្ថិតស្ថាងនិមលដោយវិជ្ជា
អ្នករៀនបានច្រើនតែងក្លាយជា អ្នកមានព័ស្តុភារមួយជីវិត។
២២.មិត្តអើយយើងជាកម្ពោជិក គឺជាស្ថាបនិកត្រូវតែគិត
សាងគ្រឹះពុទ្ធិថ្កើនគំនិត សមត្ថភាពពិតកើតពីអាន។



និពន្ធដោយៈ កុសល ស្រីមាស

សិស្សថ្នាក់ទី១១ P2

សាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប

**សេចក្តីព្យាយាមមិនធ្លាប់ក្បត់ក្រោយខ្នង មនុស្សដែលមានការតាំងចិត្ត**

*(ដកស្រង់ចេញ Page Proverb+)*



# កក្រ្សណាប្រល័យការសិក្សាខ្ញុំ

( បទ កាកគតិ )

ឱកម្ពុជាអើយ
វីរុសចម្លង
គ្រប់អ្នកសិក្សា
សាលាក៏បិទ
ទោះបីយ៉ាងណា
ខិតខំរៀនសូត្រ
រៀននៅឯផ្ទះ
សិក្សាស្វែងយល់
រៀនហើយរៀនទៀត
រៀនទាំងអក្សរ

តើថ្ងៃណាស្បើយ
ឬកូវីដថ្មី
ការសិក្សាខ្ញុំ។
ស្វះស្វែងកាយា
លែងបានជំនុំ
ទាំងគ្រូទាំងមិត្ត។
សិស្សតាំងចិន្តា
នៅផ្ទះត្រូវគិត
មិនចាញ់គ្រូណា។
ត្រូវមិនខ្វាយខ្វះ
ដោយខ្លួនអាត្មា
នូវសុខភាពផង។
រៀនកុំឱ្យឃ្លាត
រៀនទាំងលេខផ្ទង់
ដែលយើងត្រូវការ។

មេរោគចង្រៃ
មេរោគប្រល័យ
ស្វែងរកសមរម្យ
លែងបានជួបជុំ
ខិតខំតាំងចិត្ត
សួរម៉ែពិនិត្យ
ត្រូវខំសិក្សា
ថែមទាំងរក្សា
រៀនជាចម្បង
រៀនតាមចំណង់

“ប្រសិនបើអ្នកមិនដឹងពីប្រវត្តិសាស្ត្ររបស់ជាតិ អ្នកនឹងមានចក្ខុវិស័យក្នុងរយៈពេលខ្លី ប៉ុន្តែបើអ្នកដឹងពីប្រវត្តិសាស្ត្រជាតិ អ្នកនឹងចេះគិតពិចារណា និងមានទស្សនៈវិស័យវែង សម្រាប់អភិវឌ្ឍន៍ប្រទេស”។ លី ក្វាន់យូ

**“If you do not know history, you think short term. If you know History, you think medium and long term”** Lee Kuan Yew

និពន្ធដោយ **ថា លីដា**
សិស្សពូកែភាសាខ្មែរថ្នាក់ទី៩
សាលារៀនជំនាន់ថ្មី វិទ្យាល័យហ៊ុន សែន ពាមជីកង



# មតិអ្នកអាន



*លោក គង់ ណារិន នាយកសាលារៀនជំនាន់ថ្មី វិទ្យាល័យគោកព្រីង*

គម្រោងអង្គការ ខេប បានជួយដល់វិស័យអប់រំជាច្រើន ជាពិសេសគម្រោងសាលារៀនជំនាន់ថ្មី។ ការទទួលបានអន្តរាគមន៍ពីគម្រោងសាលារៀនជំនាន់ថ្មីតាំងពីឆ្នាំ២០១៦មក សាលារៀនរបស់ខ្ញុំបាទមានចំណុចផ្លាស់ប្ដូរយ៉ាងល្អប្រសើរ ដូចជា ទទួលបានវគ្គបណ្ដុះបណ្ដាលការប្រើប្រាស់បច្ចេកវិទ្យា ពង្រឹងសមត្ថភាពដល់គ្រូជាមួយវិធីសាស្ត្របង្រៀនថ្មីៗ កសាងកម្រិតសំណួរ កម្មវិធីសិក្សា ការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាលារៀនឱ្យទាន់សម័យ ការបំពាក់សម្ភារៈបង្រៀន និងរៀនឆ្លើយតបតម្រូវការនាបច្ចុប្បន្ន យល់ដឹងបន្ថែមពីរបៀបការគ្រប់គ្រង របៀបដឹកនាំក្នុងអង្គភាព ជួយសម្រួលការងាររដ្ឋបាល ចេះពិនិត្យផែនការគន្លងអាជីព ធ្វើផែនការអភិវឌ្ឍ និងការធ្វើផែនការប្រចាំដែលងាយស្រួលដល់ការតាមដានសកម្មភាពបង្រៀន ។

សូមអរគុណដល់អង្គការខេប ដែលបានបង្កើតសាលារៀនជំនាន់ថ្មីនេះ ដែលជាសាលារៀនគម្រូមួយដ៏ល្អសម្រាប់សាលារៀនទូទៅនៅក្នុងប្រទេសកម្ពុជាយកគម្រូតាម និងសង្ឃឹមថាសាលារៀនជំនាន់ថ្មីនឹងពង្រីកកាន់តែច្រើនបន្ថែមទៀតនាពេលអនាគត៕